## ព្រះរាជាណាចក្រកម្ពុជា

### ជាតិ សាសនា ព្រះមហាក្សត្រ




# ផែនទីបង្ហាញផ្លូវអភិវឌ្ឍន៍បៃតងជាតិ

**ខែមីនា ឆ្នាំ២០១០**


UNITED NATIONS
ESCAP
Economic and Social Commission for Asia and the Pacific

Green Growth

# សេចក្តីថ្លែងអំណរគុណ

ផែនទីបង្ហាញផ្លូវអភិវឌ្ឍន៍បៃតងជាតិ គឺជាឧបករណ៍ដ៏មានសារៈសំខាន់បំផុត ក្នុងការរួមចំណែកអនុវត្ត គោលនយោបាយ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិប្រកបដោយចីរភាព ទាំងនៅថ្នាក់ជាតិ និងមូលដ្ឋាននៅក្នុងព្រះរាជាណាចក្រកម្ពុជាយើង ។

ការរៀបចំបង្កើតផែនទីបង្ហាញផ្លូវអភិវឌ្ឍន៍បៃតងជាតិ បានឆ្លងកាត់កិច្ចប្រជុំក្រុមការងារបច្ចេកទេសអន្តរក្រសួង ស្តីពីការអភិវឌ្ឍន៍បៃតង ក្នុងដំណើរការសិក្សាវិភាគ ធ្វើអត្តសញ្ញាណកម្មតម្រូវការចាំបាច់ កំណត់បញ្ហាក្របខ័ណ្ឌ សំពាធ ស្ថានភាព និងបង្កើតឱកាសរួមគ្នា សម្រាប់អនុវត្តគោលនយោបាយអភិវឌ្ឍន៍បៃតង ដោយលើកជាអន្តរាគមន៍រយៈពេលខ្លី អន្តរាគមន៍រយៈពេលមធ្យម និងអន្តរាគមន៍រយៈពេលវែង ដើម្បីស្វែងរកដំណោះស្រាយនូវកង្វល់បរិស្ថាន សំដៅអភិវឌ្ឍសេដ្ឋកិច្ចជាតិដោយចីរភាព និងសុខុមាលភាពសង្គម ជារៀងនិរន្តន៍ ។

ក្នុងនាមខ្ញុំបាទ ជាអ្នកសំរបសំរួលការរៀបចំផែនទីបង្ហាញផ្លូវអភិវឌ្ឍន៍បៃតងជាតិ ខ្ញុំបាទសូមសំដែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា** ដែលតែងតែផ្តល់ការដឹកនាំដ៏ខ្ពង់ខ្ពស់ប្រកបដោយការប្តេជ្ញា និងការណែនាំខាងផ្នែកគោលនយោបាយ ដើម្បីធានាឱ្យមានការអភិវឌ្ឍជាតិប្រកបដោយភាពរុងរឿងដោយរួមបញ្ចូលនិរន្តរភាពបរិស្ថានទៅក្នុងរបៀបវារៈអភិវឌ្ឍន៍ជាតិ ដើម្បីអភិរក្សបរិស្ថានសំដៅកាត់បន្ថយភាពក្រីក្រ និងបង្កើនឱកាសការងារដល់ប្រជាជនលើកស្ទួយជីវភាព និងធានាបាននូវលទ្ធភាពប្រើប្រាស់ធនធានដោយសមធម៌ ។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះឯកឧត្តមបណ្ឌិត **ម៉ុក ម៉ារ៉េត** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន ដែលបានផ្តល់ការគាំទ្រដ៏មោះមុត និងផ្តល់អនុសាសន៍ដឹកនាំប្រកបដោយគតិបណ្ឌិត ធ្វើឱ្យបានសំរេចគោលដៅក្នុងការរៀបចំផែនទីបង្ហាញផ្លូវអភិវឌ្ឍន៍បៃតងជាតិ នេះឡើង ។

ខ្ញុំសូមឆ្លៀតឱកាសនេះ ដើម្បីសំដែងអំណរគុណ ចំពោះឯកឧត្តម **ខុង សំអួន** រដ្ឋលេខាធិការក្រសួងបរិស្ថាន និងជាប្រធានក្រុមការងារបច្ចេកទេសអន្តរក្រសួងស្តីពីការអភិវឌ្ឍបៃតង ដែលបានផ្តល់ការគាំទ្រដ៏មោះមុតនិងការសម្របសម្រួលដ៏មានប្រសិទ្ធិភាព ដើម្បីរៀបចំផែនទីបង្ហាញផ្លូវសម្រាប់ការអភិវឌ្ឍបៃតងជាតិ ។ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងស្មោះស្ម័គ្រ ចំពោះលោកស្រី Aneta Nikolova មន្ត្រី កិច្ចការបរិស្ថាន លោក Simon Hoiberg Olsen មន្ត្រីជំនួយការបរិស្ថានខាងផ្នែកបរិស្ថាន និងអភិវឌ្ឍន៍នៃគណៈកម្មការសេដ្ឋកិច្ច និងសង្គម សម្រាប់តំបន់អាស៊ីនិងប៉ាស៊ីហ្វិក របស់អង្គការសហប្រជាជាតិ និងលោក ហាក់ ម៉ៅ ទីប្រឹក្សាជាតិ និងមន្ត្រីព័ត៌មានថ្នាក់តំបន់ទទួលបន្ទុកការប្រើប្រាស់ និងផលិតកម្មដោយនិរន្តរភាព ដែលបានផ្តល់យោបល់បច្ចេកទេសគាំទ្រ និងគំនិតជាច្រើនដើម្បីរៀបចំ

ផែនទីបង្ហាញផ្លូវនេះដែលជាយុទ្ធសាស្ត្រ និងកម្មវិធីការងារសម្រាប់កសាងគោលនយោបាយជាតិ និងសកម្មភាពអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយចីរភាពបរិស្ថាន និងការ អភិវឌ្ឍដែលបញ្ចេញកាបូនតិចនៅកម្ពុជា ។

សូមថ្លែងអំណរគុណយ៉ាងស្មោះស្ម័គ្រចំពោះរដ្ឋាភិបាលនៃសាធារណរដ្ឋកូរ៉េ ដែលបានផ្តល់ការគាំទ្រហិរញ្ញវត្ថុតាមរយៈទីភ្នាក់ងារ សហប្រតិបត្តិការអន្តរជាតិនៃប្រទេសកូរ៉េ ដើម្បីរៀបចំផែនទីបង្ហាញផ្លូវនេះ។ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះអ្នករួមវិភាគទាន ផ្សេងទៀតផងដែរ ដូចជាទាំងអ្នកពាក់ព័ន្ធទាំងអស់ និងក្រសួងនានា ដែលបានផ្តល់ ការគាំទ្រដ៏មានតម្លៃក្នុងការរៀបចំផែនទីបង្ហាញផ្លូវនេះ។ លើសពីនេះ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះក្រុមការងារបច្ចេកទេសអន្តរក្រសួងស្តីពីការអភិវឌ្ឍបៃតង ដែលបានផ្តល់កិច្ចសហប្រតិបត្តិការ និងវិភាគទានដ៏សប្បុរសក្នុងការរៀបចំផែនទីបង្ហាញផ្លូវនេះ ដែលជាគុណប្រយោជន៍សំរាប់ប្រជាជនកម្ពុជា និងពិភពលោក ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែមីនា ឆ្នាំ ២០១០

អគ្គនាយករងបច្ចេកទេស នៃក្រសួងបរិស្ថាន

ប្រធានលេខាធិការដ្ឋានអភិវឌ្ឍន៍បៃតង

ឃុច សុខាន

# បុព្វកថា



ក្នុងបណ្ដាទសវត្សរ៍កន្លងទៅនេះសន្ទុះនៃការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមនៅតំបន់អាស៊ី និងប៉ាស៊ីហ្វិក បានដាក់នូវសម្ពាធបន្ថែមទៀត មកលើធនធានធម្មជាតិ និងបរិស្ថាន ហើយជាមួយគ្នានោះ ការប្រែប្រួលអាកាសធាតុបានក្លាយទៅជាបញ្ហាប្រឈម ដ៏ចំបង ដែលតម្រូវឱ្យរដ្ឋាភិបាលគ្រប់ប្រទេសលើពិភពលោកធ្វើការគិតគូរពិចារណា និងស្វែងរកដំណោះស្រាយរួមគ្នា សំដៅធានាបាននូវការអភិវឌ្ឍន៍ប្រកបដោយចីរភាព។

ឆ្លើយតបទៅនិងភាពចាំបាច់នេះ សន្និសីទថ្នាក់រដ្ឋមន្ត្រីលើកទី ៥ ស្ដីពីបរិស្ថាន និងការអភិវឌ្ឍ របស់បណ្ដាប្រទេសនៅអាស៊ី និងប៉ាស៊ីហ្វិក កាលពីខែមីនា ឆ្នាំ ២០០៥ នៅទីក្រុងសេអ៊ូល បានអនុម័តគោលគំនិតស្ដីពីការអភិវឌ្ឍបៃតង ក្នុងគោលបំណងធ្វើអោយប្រសើរឡើងដល់ សុខុមាលភាពប្រជាពលរដ្ឋទាំងអស់ក្នុងពិភពលោក ។

ទន្ទឹមនឹងនេះ ដោយការខិតខំប្រឹងប្រែងរបស់ក្រសួងបរិស្ថាន និងមានកិច្ចសហការជាមួយស្ថាប័នជាតិ និងអន្តរជាតិជាដៃគូ អភិវឌ្ឍន៍បៃតង ខ្ញុំមានសេចក្ដីសោមនស្សរីករាយជាពន់ពេក សូមបង្ហាញជូននូវផែនទីបង្ហាញផ្លូវអភិវឌ្ឍន៍បៃតងជាតិ ដែលជាសមិទ្ធិផលការងារ ថ្មីមួយ ផ្ដើមចេញពីកិច្ចសហការដ៏ល្អរវាងស្ថាប័នរដ្ឋាភិបាលគ្រប់ជាន់ថ្នាក់ អង្គការមិនមែនរដ្ឋាភិបាល ក្រុមហ៊ុនឯកជន គំរោង និងកម្មវិធីនានា ជាដៃគូអភិវឌ្ឍន៍បៃតង និងបានអនុម័តក្នុងកិច្ចប្រជុំអន្តរក្រសួងស្ដីពីការអភិវឌ្ឍន៍បៃតង កាលពី ថ្ងៃទី ០៨ ខែកុម្ភៈ ឆ្នាំ ២០១០ នៅទីក្រុង សៀមរាប។

ចក្ខុវិស័យនៃផែនទីបង្ហាញផ្លូវអភិវឌ្ឍន៍បៃតងជាតិ សំដៅធ្វើឱ្យប្រជាពលរដ្ឋកម្ពុជា រស់នៅប្រកបដោយវិបុលភាព និងនិរន្តរភាពនៃ ការចិញ្ចឹមជីវិត ដោយបានធ្វើការពិចារណាយ៉ាងល្អិតល្អន់នូវគោលបំណង នៃកំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍ សុខុមាលភាពប្រជាពលរដ្ឋ និងគុណភាពបរិស្ថាន សំដៅការអភិវឌ្ឍសេដ្ឋកិច្ចជាតិមានការបញ្ចេញកាបូនតិចបំផុត ដើម្បីឱ្យកូនចៅជំនាន់ក្រោយអាចទទួលយកបាន ទាំង កំណើនសេដ្ឋកិច្ច និងបរិស្ថានល្អ សម្រាប់ការរស់នៅប្រកបដោយភាពរុងរឿង។

ក្នុងន័យនេះ ផែនទីបង្ហាញផ្លូវអភិវឌ្ឍបៃតងជាតិ បានស្នើឱ្យបង្កើតនូវស្ថានភាព ឈ្នះ-ឈ្នះ-ឈ្នះ រវាងសេដ្ឋកិច្ច បរិស្ថាន និងសង្គម ដើម្បីបង្ហាញថា ការអភិវឌ្ឍសេដ្ឋកិច្ច និរន្តរភាពបរិស្ថាន និងសុខុមាលភាពសង្គម ពិតជាអាចសម្រេចទៅបានក្នុងពេលទន្ទឹមគ្នា ដូចមានចែង ក្នុងអន្តរាគមន៍រយៈពេលខ្លី អន្តរាគមន៍រយៈពេលមធ្យម និងអន្តរាគមន៍រយៈពេលវែង នៃផែនទីបង្ហាញផ្លូវនេះ។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមវាយតំលៃខ្ពស់ និងកោតសរសើរចំពោះ ក្រុមការងារបច្ចេកទេសអន្តរក្រសួង ស្ដីពីការអភិវឌ្ឍបៃតង និងទីប្រឹក្សាបច្ចេកទេសទាំងអស់ ដែលបានរួមចំណែកក្នុងការរៀបចំផែនទីបង្ហាញផ្លូវអភិវឌ្ឍន៍បៃតងជាតិ ប្រកបដោយជោគជ័យ។

ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ គណៈកម្មការសេដ្ឋកិច្ច និងសង្គមសម្រាប់តំបន់អាស៊ី និងប៉ាស៊ីហ្វិក នៃអង្គការ សហប្រជាជាតិ និងរដ្ឋាភិបាលនៃសាធារណរដ្ឋកូរ៉េ តាមរយៈទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិ

កូរ៉េ ដែលបានផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេសក្នុងការរៀបចំផែនទីបង្ហាញផ្លូវនេះឡើង ជាគុណប្រយោជន៍សំរាប់ប្រជាជនកម្ពុជា និងពិភពលោក ។

ទីបញ្ចប់ ខ្ញុំសូមធ្វើការអះអាង និងប្តេជ្ញាអនុវត្តផែនទីបង្ហាញផ្លូវអភិវឌ្ឍបៃតងជាតិ ឱ្យទទួលបានជោគជ័យជាស្ថាពរ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែមីនា ឆ្នាំ ២០១០

**ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងបរិស្ថាន**

**បណ្ឌិត មុំ ម៉ារ៉ែត**

## ក្រុមការងារបច្ចេកទេសអន្តរក្រសួងស្តីពីការអភិវឌ្ឍបៃតង

១. ក្រសួងបរិស្ថាន

- ឯកឧត្តម ខុង សំនួន រដ្ឋលេខាធិការ និងជាប្រធាន ក្រុមការងារបច្ចេកទេសអន្តរក្រសួងស្តីពីការអភិវឌ្ឍបៃតង
- លោក កុច សុវាទ អគ្គនាយករងបច្ចេកទេស និងជាប្រធានលេខាធិការដ្ឋានអភិវឌ្ឍន៍បៃតង
- លោកបណ្ឌិត ជ្រិន សុខា អគ្គនាយករងបច្ចេកទេស
- លោកបណ្ឌិត អ៊ុំ ពិសី អគ្គនាយករងបច្ចេកទេស
- លោក ជួន ច័ន្ទឫទ្ធី ប្រធាននាយកដ្ឋានវាយតម្លៃធនធានធម្មជាតិ និងគ្រប់គ្រងទិន្នន័យបរិស្ថាន
- លោក ជា ស៊ីណា អនុប្រធាននាយកដ្ឋានត្រួតពិនិត្យការបំពុលបរិស្ថាន
- លោក យឹន សំរ៉ាយ អនុប្រធាននាយកដ្ឋានផែនការ និងកិច្ចការច្បាប់

២. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- ឯកឧត្តម អ៊ុង សំអាត អនុប្រធានរដ្ឋបាលព្រៃឈើ និងជាសមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច-សង្គមនិងវប្បធម៌

៣. ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

- លោកបណ្ឌិត ទឹង ស៊ីនី អគ្គនាយករង ឧស្សាហកម្ម
- លោក រ៉ែន គាហាក់ អនុប្រធាននាយកដ្ឋានបច្ចេកទេសឧស្សាហកម្ម

៤.ក្រសួងផែនការ

- ឯកឧត្តម ម៉ម ម៉ារ៉ាឌី ទីប្រឹក្សា និងជាប្រធាននាយកដ្ឋានផែនការទូទៅ

៥. ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

- លោកបណ្ឌិត ម៉េង ប៊ុណ្ណារិទ្ធ ប្រធាននាយកដ្ឋានគ្រប់គ្រងដីធ្លី

៦. ក្រសួងសាធារណការ និងដឹកជញ្ជូន

- លោក សឿន សុគង់ ប្រធាននាយកដ្ឋានផែនការ

៧. ក្រសួងសុខាភិបាល

- លោកស្រី ប្រាក់ ពិសិដ្ឋវង្សី ប្រធាននាយកដ្ឋានការពារសុខភាព

៨. ក្រសួងអប់រំ យុវជន និងកីឡា

- លោក ស៊ុន ប៊ុណ្ណា អនុប្រធាននាយកដ្ឋានអភិវឌ្ឍន៍កម្មវិធីសិក្សា

៩. ក្រសួងកិច្ចការនារី

- លោកស្រី តែ វូចលីម អនុប្រធាននាយកដ្ឋានផែនការ និងស្ថិតិ
- លោក ទីម ភីយ៉ារី អនុប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ

១០. ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- កញ្ញា យុត គីមលាង អនុប្រធាននាយកដ្ឋានផែនការ ស្ថិតិ និងនីតិកម្ម
- លោកស្រី ជុំ កាលីន អនុប្រធាននាយកដ្ឋានផែនការ ស្ថិតិ និងនីតិកម្ម

១១. ក្រសួងទេសចរណ៍

- លោក ប៊ូ ចន្ទសិរី អនុប្រធាននាយកដ្ឋានផែនការ និងអភិវឌ្ឍន៍

១២. ក្រសួងអភិវឌ្ឍន៍ជនបទ

- លោក ស្រ៊ុន ពិធូ អនុប្រធាននាយកដ្ឋានផែនការ និងទំនាក់ទំនងសាធារណៈ

១៣. ក្រសួងមហាផ្ទៃ

- លោកបណ្ឌិត សុខ ចំរើន អនុប្រធាននាយកដ្ឋានរដ្ឋបាលមូលដ្ឋាន

១៤. ក្រសួងធនធានទឹក និងឧតុនិយម

- លោក ម៉ែន មួយបុណ្យ អនុប្រធាននាយកដ្ឋានសហគមន៍កសិករប្រើប្រាស់ទឹក

១៥. ក្រសួងពាណិជ្ជកម្ម

- លោក គង់ កែវមុន្នី អនុប្រធាននាយកដ្ឋានពាណិជ្ជកម្មពហុភាគី

១៦. ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- លោក យូ ភិរម្យ អនុប្រធាននាយកដ្ឋានវិនិយោគ និងសហប្រតិបត្តិការ
- លោក ជា សេងយី អនុប្រធានការិយាល័យសហប្រតិបត្តិការទ្វេភាគី

១៧. សភាពាណិជ្ជកម្មកម្ពុជា

- ឯកឧត្តម ងួន ម៉េងតិច អគ្គនាយក

១៨. សាលាក្រុងភ្នំពេញ

- ឯកឧត្តម ម៉ាន់ ឈឿន អភិបាលរង

១៩. មន្ទីរបរិស្ថានក្រុងភ្នំពេញ

- លោក ជៀក អាង ប្រធានមន្ទីរ

២០. លោកបណ្ឌិត ទិន ពន្លក មន្ត្រីជាតិសម្របសម្រួលគម្រោងរៀបចំរបាយការណ៍ជាតិលើកទី ២

## <u>អ្នករួមវិភាគទានក្នុងការរៀបចំផែនទីបង្ហាញផ្លូវអភិវឌ្ឍច្រកតែមួយជាតិ</u>

-**លោកស្រី សុខ សុទ្ធារី** ប្រធានរដ្ឋបាលនៃសភាពាណិជ្ជកម្មកម្ពុជា

-**លោកស្រី គីមសួរ សុធីរ៉ា** អនុប្រធានការិយាល័យសហប្រតិបត្តិ ការទ្វេភាគីនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-**លោក យីន យ៉ាណូ** ប្រធានការិយាល័យអង្គការពាណិជ្ជកម្មអន្តរជាតិកម្ពុជា នៃក្រសួងពាណិជ្ជកម្ម

-**លោក ចុង ប៊ូ** ការិយាល័យសុវត្ថិភាពឧស្សាហកម្ម នៃនាយកដ្ឋានបច្ចេកទេសឧស្សាហកម្ម

- **លោក នួន រដ្ឋា** អធិការនៃអគ្គាធិការ នៃក្រសួងបរិស្ថាន

-**លោក ជ្រៀង ផល្លា** ប្រធានការិយាល័យទំនាក់ទំនងសាធារណៈនៃក្រសួងសាធារណការ និង ដឹកជញ្ជូន

-**លោក ជា សេងយី** អនុប្រធាន ការិយាល័យសហប្រតិបត្តិការទ្វេភាគីនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-**លោក ជិន សុធន** អនុប្រធានការិយាល័យ គ្រប់គ្រងសំណល់រឹងនៃនាយកដ្ឋានត្រួតពិនិត្យការបំពុលបរិស្ថាន

-**លោក** Nikolai Sermine ទីប្រឹក្សាជាន់ខ្ពស់ ផ្នែកសេវាកម្ម និងបច្ចេកវិជ្ជាបរិស្ថាន នៃមជ្ឈមណ្ឌលពាណិជ្ជកម្មអន្តរជាតិ

-**លោក បណ្ឌិត** David Ness សាស្ត្រាចារ្យនៅសាកលវិទ្យាល័យអូស្ត្រាលីខាងត្បូង

-**លោក** Nigel Stedman នាយកផ្នែក ទីប្រឹក្សាជំនួញអន្តរជាតិ

# មាតិកាអត្ថបទ

ផែនទីបង្ហាញផ្លូវសម្រាប់ការអភិវឌ្ឍបៃតងជាតិ ........ ០
សេចក្ដីថ្លែងអំណរគុណ ........ ១
បុព្វកថា ........ ៣
ក្រុមការងារបច្ចេកទេសអន្តរក្រសួងស្ដីពីការអភិវឌ្ឍបៃតង ........ ៥
មាតិកាអត្ថបទ ........ ៨
ពាក្យបំព្រួញ ........ ១១
សេចក្ដីសង្ខេបសម្រាប់អ្នកធ្វើសេចក្ដីសម្រេច ........ ១៣
និយមន័យការអភិវឌ្ឍបៃតង ........ ១៣
ការធ្វើអត្តសញ្ញាណតម្រូវការចាំបាច់ ........ ១៤
វិធានគ្រប់ជ្រុងជ្រោយ ........ ១៥
ផែនទីបង្ហាញផ្លូវ ........ ១៥
អនុសាសន៍ ........ ១៦
១. សេចក្ដីផ្ដើម ........ ១៧
១.១ ស្ថានភាពសេដ្ឋកិច្ចបច្ចុប្បន្ន ........ ១៨
១.២ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (២០០៦-២០១០) ........ ១៩
១.៣ យុទ្ធសាស្ត្រចតុកោណ ........ ២០
២. ទិដ្ឋភាពរួមនៃផែនទីបង្ហាញផ្លូវសម្រាប់ការអភិវឌ្ឍបៃតងជាតិ ........ ២២
២.១ ចក្ខុវិស័យ : វិបុលភាព និងនិរន្តរភាពនៃការចិញ្ចឹមជីវិត ........ ២២
២.២ គោលដៅ : ធ្វើឱ្យការអភិវឌ្ឍមានលក្ខណៈបៃតង ........ ២២
២.៣ គោលបំណង ........ ២២
៣. ការគំរាមកំហែង ........ ២៣
៣.១ កំណើនចំនួនប្រជាជន ........ ២៣
៣.២ ស្ថានភាពក្រីក្រ ........ ២៤
៣.៣ ក្របខ័ណ្ឌច្បាប់ និងគោលនយោបាយ ........ ២៥
៣.៤ សម្ពាធមកលើបរិស្ថាន ........ ២៥
៣.៥ ឱកាសនានា ........ ២៦
៣.៦ កត្តាជម្រុញឱ្យមានការអភិវឌ្ឍបៃតង ........ ២៧

**៤. មាគ៌ាទៅរកការអភិវឌ្ឍសេដ្ឋកិច្ចបៃតង** ..... ២៧
៤.១ អន្តរាគមន៍សម្រាប់រយៈពេលខ្លី (២-៥ ឆ្នាំ) ..... ២៨
៤.២ អន្តរាគមន៍សម្រាប់រយៈពេលមធ្យម(៥-១០ ឆ្នាំ) ..... ២៨
១) ការអភិវឌ្ឍភូមិបៃតង ..... ២៨
២) និរន្តរភាពនៃធនធានទឹក ..... ៣២
៣) និរន្តរភាពនៃវិស័យថាមពល កសិកម្ម និងព្រៃឈើ ..... ៣៤
៤) និរន្តរភាពនៃការគ្រប់គ្រងសំណល់ ..... ៣៨
៥) និរន្តរភាពនៃការដឹកជញ្ជូន ..... ៤០
៤.៣ អន្តរាគមន៍សម្រាប់រយៈពេលវែង(១០-២០ ឆ្នាំ) ..... ៤២
៤.៣.១ កិច្ចផ្តួចផ្តើមខាងសារពើពន្ធ ..... ៤៣
៤.៣.២ ការធ្វើកសិកម្មតាមគោលការណ៍ធម្មជាតិ ..... ៤៣
៤.៣.៣ កំណែលម្អហេដ្ឋារចនាសម្ព័ន្ធ និងពាណិជ្ជកម្ម ..... ៤៤
៤.៣.៤ និរន្តរភាពថាមពល ..... ៤៦
៤.៣.៤ ការអភិវឌ្ឍវិស័យអប់រំ ..... ៤៧
៤.៣.៥ ការកែលម្អសុខភាព ..... ៤៧
៤.៣.៦ ការបញ្ចូលសមធម៌យេនឌ័រទៅក្នុងការអភិវឌ្ឍបៃតង ..... ៤៨
៤.៣.៧ ការប្រើប្រាស់ដី និងបរិស្ថានទីក្រុងដែលសមស្របតាមលក្ខខណ្ឌធម្មជាតិ និងដែលផ្តល់សុខភាពល្អ. ៤៨
៤.៣.៨ ការអភិវឌ្ឍសេដ្ឋកិច្ចបៃតង ..... ៤៩
៤.៣.៩ កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ..... ៤៩
៤.៤ កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ..... ៤២
**៥. យន្តការអនុវត្តសម្រាប់ការអភិវឌ្ឍបៃតង** ..... ៥២
៥.១ បរិយាកាសអំណោយផលសម្រាប់ផែនទីបង្ហាញផ្លូវការអភិវឌ្ឍបៃតងជាតិ ..... ៥៣
៥. ២ កិច្ចសហប្រតិបត្តិការរវាងអ្នកពាក់ព័ន្ធនានា ..... ៥៣
៥.៣ ការសម្របសម្រួលលើការអភិវឌ្ឍបៃតង ដោយប្រើប្រាស់ក្របខ័ណ្ឌវាយតម្លៃនិរន្តរភាពចម្រុះ ..... ៥៤
៥.៣.១ ដំណាក់កាលកំណត់វិសាលភាព ..... ៥៥
៥.៣.២ ដំណាក់កាលបង្កើតចក្ខុវិស័យ ..... ៥៦
៥.៣.៣ ដំណាក់កាលដកស្រង់បទពិសោធន៍ ..... ៥៦
៥.៣.៤ ដំណាក់កាលសិក្សាស្វែងយល់ ..... ៥៦

៥.៣.៥ ក្របខ័ណ្ឌអនុវត្តន៍ផែនទីបង្ហាញផ្លូវការអភិវឌ្ឍបៃតងនាពេលអនាគត....................................៥៩
៦. សេចក្តីសន្និដ្ឋាន និងអនុសាសន៍ .................................................................................. ៦០
៧. ឯកសារយោង ............................................................................................................ ៦២
៨. ឧបសម្ព័ន្ធ................................................................................................................. ៦៤

# ពាក្យបំព្រួញ

| | | |
|---|---|---|
| ADB | Asian Development Bank | ធនាគារអភិវឌ្ឍន៍អាស៊ី |
| AIDs | Acquired Immune Deficiency Syndrome | ប្រជុំរោគសញ្ញាការទន់ខ្សោយនៃប្រព័ន្ធការពារ ( អេដស៍) |
| A/R-CDM | Afforestation and Reforestation for Clean Development Mechanism | ការដាំដើមឈើ និងការស្តារព្រៃឈើសម្រាប់យន្តការអភិវឌ្ឍន៍ស្អាត |
| CCọC | Cambodia's Chamber of Commerce | សភាពាណិជ្ជកម្មកម្ពុជា |
| DANIDA | Danish International Development Agency | ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិនៃប្រទេសដាណឺម៉ាក់ |
| D & D | Decentralization and Deconcentration | វិមជ្ឈការ និងវិសហមជ្ឈការ |
| DPs | Development Partners | ដៃគូអភិវឌ្ឍន៍ |
| EDP | Economic Development Plan | ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច |
| ESTs | Environmental Sound Technologies | បច្ចេកវិទ្យាប្រកបដោយប្រសិទ្ធិភាពបរិស្ថាន |
| GDP | Gross Domestic Product | ផលិតផលក្នុងស្រុកសរុប |
| GMS | Greater Mekong Sub-region | មហាអនុតំបន់មេគង្គ |
| GMOs | Genetically Modified Organisms | សារពាង្គកាយកែច្នៃសេនេទិក |
| GTBR | Green Tax and Budget Reform | ពន្ធបៃតង និងកំណែទម្រង់ថវិកា |
| HSP | Health Strategy Plan | ផែនការយុទ្ធសាស្ត្រលើវិស័យសុខាភិបាល |
| IOs | International Organizations | អង្គការអន្តរជាតិ |
| ISA | Integrated Sustainability Assessment | ការវាយតម្លៃនិរន្តរភាពចម្រុះ |
| KOICA | Korea International Cooperation Agency | ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសកូរ៉េ |
| MATISSE | Methods and Tools for Integrated Sustainability Assessment | វិធី និងឧបករណ៍សម្រាប់វាយតម្លៃនិរន្តរភាពចម្រុះ |
| MAFF | Ministry of Agriculture, Forestry and Fisheries | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| MIME | Ministry of Industry, Mines and Energy | ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល |
| MLMUPC | Ministry of Land Management, Urban Planning and Construction | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ |
| MoI | Ministry of Interior | ក្រសួងមហាផ្ទៃ |
| MLVT | Ministry of Labor and Vocational Training | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| MoT | Ministry of Tourism | ក្រសួងទេសចរណ៍ |
| MWA | Ministry of Women's Affairs | ក្រសួងកិច្ចការនារី |
| MoC | Ministry of Commerce | ក្រសួងពាណិជ្ជកម្ម |
| MoE | Ministry of Environment | ក្រសួងបរិស្ថាន |
| MEF | Ministry of Economics and Finance | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| MoP | Ministry of Planning | ក្រសួងផែនការ |
| MoEYS | Ministry of Education, Youth and Sports | ក្រសួងអប់រំ យុវជន និងកីឡា |
| MoWRAM | Ministry of Water Resources And Meteorology | ក្រសួងធនធានទឹក និងឧត្តុនិយម |

| | | |
|---|---|---|
| MPWT | Ministry of Public Works and Transport | ក្រសួងសាធារណការ និងដឹកជញ្ជូន |
| MRD | Ministry of Rural Development | ក្រសួងអភិវឌ្ឍន៍ជនបទ |
| MoRCs | Ministry of Religions and Cults | ក្រសួងធម្មការ និងកិច្ចការសាសនា |
| MTDP | Mekong Tourism Development Project | គម្រោងអភិវឌ្ឍន៍ទេសចរណ៍តំបន់ទន្លេមេគង្គ |
| NAPA | National Adaptation Programme of Action | កម្មវិធីសកម្មភាពជាតិបន្សាំនឹងការប្រែប្រួលអាកាសធាតុ |
| NCDD | National Committee for the Management of the Decentralization and Deconcentration | គណៈកម្មាធិការជាតិគ្រប់គ្រងវិមជ្ឈការនិងសហវិមជ្ឈការ |
| NGOs | Non-Governmental Organizations | អង្គការមិនមែនរដ្ឋាភិបាល |
| NIS | National Institute of Statistics | វិទ្យាស្ថានជាតិស្ថិតិ |
| NSDP | National Strategic Development Plan | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ |
| PCBs | Printed Circuit Boards | បន្ទះសៀគ្វីអេឡិចត្រូនិក |
| PDoE | Provincial Department of Environment | មន្ទីរបរិស្ថានខេត្ត |
| PFM | Public Financial Management | ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ |
| POPs | Persistent Organic Pollutants | សារធាតុបំពុលសរីរាង្គ |
| PIPs | Public Investment Programmes | កម្មវិធីវិនិយោគសាធារណៈ |
| PPP | Private Public Partnership | ភាពជាដៃគូសាធារណៈ |
| REDD | Reducing Emission from Deforestation and Forest Degradation | ការកាត់បន្ថយការបញ្ចេញឧស្ម័នពីការបាត់បង់ព្រៃឈើ និងការរេចរឹលព្រៃឈើ |
| RGC | Royal Government of Cambodia | រាជរដ្ឋាភិបាលកម្ពុជា |
| 3Rs | Reduce Reuse Recycle | កាត់បន្ថយ ប្រើប្រាស់ឡើងវិញ កែច្នៃឡើងវិញ |
| RS | Rectangular Strategy | យុទ្ធសាស្ត្រចតុកោណ |
| SLA | Sustainable Livelihoods Approach | វិធាននិរន្តរភាពនៃការចិញ្ចឹមជីវិត |
| SMEs | Small and Medium Enterprises | សហគ្រាសខ្នាតតូច និងមធ្យម |
| TVET | Technical and Vocational Education and Training | ការអប់រំ និងបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ |
| UNESCAP | United Nations for Economic and Social Commission for Asia and the Pacific | គណៈកម្មការសេដ្ឋកិច្ចនិងសង្គម សម្រាប់តំបន់អាស៊ី និង ប៉ាស៊ីហ្វិក នៃអង្គការសហប្រជាជាតិ |
| UXO | Unexploded Ordnance | យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ |
| WTO | World Trade Organization | អង្គការពាណិជ្ជកម្មពិភពលោក |

## សេចក្តីសង្ខេបសម្រាប់អ្នកធ្វើសេចក្តីសម្រេច

ប្រទេសកម្ពុជាបានរៀបចំផែនទីបង្ហាញផ្លូវសម្រាប់ការអភិវឌ្ឍបៃតងជាតិ ដើម្បីពង្រឹងការអភិវឌ្ឍជាបន្ថែម ក្នុងបំណងផ្តល់ជាប្រយោជន៍ដល់ប្រជាពលរដ្ឋ និងអភិរក្ស ព្រមទាំងស្តារមូលធនធម្មជាតិ សម្រាប់បន្តជម្រុញកំណើនសេដ្ឋកិច្ច នៅក្នុងកម្រិតដែលសមត្ថភាពរបស់បរិស្ថានអាចទ្រទ្រង់បាន។

ផែនទីបង្ហាញផ្លូវនេះ ត្រូវបានរៀបរៀងឡើង តាមរយៈការពិគ្រោះយោបល់ និងការសម្ភាសជាច្រើនជាមួយក្រសួងស្ថាប័នពាក់ព័ន្ធទាំងអស់។ លើសពីនេះ ការពិភាក្សានានា នៅក្នុងកិច្ចប្រជុំរបស់ក្រុមការងារបច្ចេកទេស អន្តរ-ក្រសួង ស្តីពីការអភិវឌ្ឍបៃតង ដែលបានធ្វើឡើងនៅក្រុងភ្នំពេញក្នុងឆ្នាំ ២០០៩ បានផ្តល់គោលគំនិតជាច្រើនសំរាប់បង្កើនកិច្ចសហប្រតិបត្តិការជាមួយអ្នកពាក់ព័ន្ធនានា ដើម្បីបង្កើត និងអនុវត្តគម្រោង ព្រមទាំងកម្មវិធីសំរាប់បង្កើនការអភិវឌ្ឍដោយចីរភាព និងពេញលេញនៅកម្ពុជា ក្នុងគោលដៅពង្រឹងភាពធន់ទ្រាំទៅនឹងឥទ្ធិពលអវិជ្ជមាននានា ទន្ទឹមនឹងការជ្រើសយកជម្រើសសម្រាប់ការបញ្ចេញឧស្ម័នកាបូនតិចបំផុត "ការអភិវឌ្ឍបៃតង" ដើម្បីបន្សាំ និងកាត់បន្ថយការប្រែប្រួលអាកាសធាតុ។

### និយមន័យការអភិវឌ្ឍបៃតង

ការអភិវឌ្ឍបៃតង ត្រូវបានគណៈកម្មការសេដ្ឋកិច្ចនិងសង្គម សម្រាប់តំបន់អាស៊ី និងប៉ាស៊ីហ្វិក នៃអង្គការសហប្រជាជាតិ ឱ្យនិយមន័យថា ជាចំណុចដៅនៃគោលនយោបាយសម្រាប់តំបន់អាស៊ី និងប៉ាស៊ីហ្វិក ដែលផ្តោតលើការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយចីរភាព និងមិនបង្កការខូចខាតចំពោះប្រព័ន្ធអេកូឡូស៊ី ដើម្បីពង្រឹងការអភិវឌ្ឍ ដែលបញ្ចេញកាបូនតិច និងផ្តល់ប្រយោជន៍ដល់សង្គមទាំងមូល។ នៅក្នុងកិច្ចប្រឹងប្រែងនានា ដើម្បីបង្កើតវិធានការឆ្លើយតបដែលបានពីការសម្របសម្រួលរវាងគ្នានៅថ្នាក់តំបន់ អ្នកកសាងគោលនយោបាយនៅក្នុងរដ្ឋាភិបាលនានា បានជួបប្រជុំនៅក្នុងសន្និសីទថ្នាក់រដ្ឋមន្ត្រីលើកទី ៥ នៅទីក្រុងសេអ៊ូល នៃសាធារណរដ្ឋកូរ៉េ នាឆ្នាំ ២០០៥។ នៅក្នុងពេលនោះ ការអភិវឌ្ឍបៃតង ត្រូវបានរដ្ឋនានាចំនួន៥២ ដែលជាសមាជិកគណៈកម្មការសេដ្ឋកិច្ច និងសង្គមនៃអង្គការសហប្រជាជាតិ សម្រាប់តំបន់អាស៊ី និងប៉ាស៊ីហ្វិក បានអនុម័តទទួលយក និងចាត់ទុកថាជាលំនាំផ្លូវរួមមួយ ដើម្បីសម្រេចឱ្យបាននូវការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយចីរភាពបរិស្ថាន។

ក្នុងន័យនេះ ផែនទីបង្ហាញផ្លូវអភិវឌ្ឍបៃតងជាតិ លើកស្នើឱ្យប្រកាន់យកមាគ៌ានៃការអភិវឌ្ឍបៃតង ដែលអាច *អនុវត្ត* បាននៅកម្ពុជា ទាំងនៅក្នុងរយៈពេលខ្លី មធ្យម និងរយៈពេលវែង។ ផែនទីបង្ហាញផ្លូវនេះ បានស្នើឱ្យបង្កើតស្ថានភាព **ឈ្នះ-ឈ្នះ-ឈ្នះ** រវាង**សេដ្ឋកិច្ច បរិស្ថាន និងសង្គម** ដើម្បីបង្ហាញថា **ការអភិវឌ្ឍសេដ្ឋកិច្ច និរន្តរភាពបរិស្ថាន និងសុខមាលភាពសង្គម** ពិតជាអាចសម្រេចទៅបានក្នុងពេលទន្ទឹមគ្នា។ ការប្រកាន់យកវិធានគ្រប់ជ្រុងជ្រោយ នៅក្នុង

ការអភិវឌ្ឍនឹងជួយប្រទេសកម្ពុជាក្នុងការពង្រឹងភាពធន់ទ្រាំ និងកាត់បន្ថយភាពងាយរងគ្រោះ ដោយសារការប្រែប្រួលអាកាសធាតុ។ ដោយផ្អែកជាចំបងលើវិធានរបស់គណៈកម្មការសេដ្ឋកិច្ច និងសង្គម សម្រាប់តំបន់អាស៊ី និង ប៉ាស៊ីហ្វិក នៃអង្គការសហប្រជាជាតិ ស្តីពីការអភិវឌ្ឍបៃតងគ្រប់ជ្រុងជ្រោយ ផែនទីបង្ហាញផ្លូវនេះត្រូវបានរៀបរៀង ដោយទទួលស្គាល់ថា សេដ្ឋកិច្ច បរិស្ថាន និងសង្គម មិនអាចកាត់ផ្តាច់ចេញពីគ្នាបានឡើយ ប៉ុន្តែវាជាសមាសភាគ ដែលត្រូវពឹងផ្អែកគ្នាទៅវិញទៅមក ដោយពាក់ព័ន្ធជាមួយគ្នាយ៉ាងជិតស្និទ្ធិបំផុត។

## ការធ្វើអត្តសញ្ញាណតម្រូវការចាំបាច់

បើទោះជាមានការរីកចម្រើនគួរឱ្យកត់សំគាល់រួចហើយក៏ដោយ ការអភិវឌ្ឍរបស់កម្ពុជា បានស្ថិតលើលំនាំផ្លូវនៃការសាកល្បងលើផ្នែកជាច្រើន : ការប្រែប្រួលមិនទៀងទាត់នៃតម្លៃធនធានធម្មជាតិ វិបត្តិស្បៀង/ឥន្ធនៈ/ហិរញ្ញវត្ថុ ការបាត់បង់ប្រព័ន្ធអេកូឡូស៊ី វត្តមានទឹកមិនគ្រប់គ្រាន់ និងកំណើនភាពងាយរងគ្រោះដោយសារបញ្ហាអាកាសធាតុ។ ការប្រឈមទាំងនេះបានរារាំងការរីកចម្រើនកន្លងមក ក្នុងការឈានទៅសម្រេចគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា។ ភាពក្រីក្រ និងស្ថានភាពជិតធ្លាក់ខ្លួនក្រ នៅមានកម្រិតខ្ពស់នៅឡើយ ហើយសូចនាករផ្សេងទៀត នៃការអភិវឌ្ឍធនធានមនុស្ស នៅតែបន្តឆ្លុះបញ្ចាំងពីលក្ខខណ្ឌរស់នៅយ៉ាងលំបាក ជាពិសេសនៅតាមទីជនបទ ពោលគឺជាកន្លែងដែល ប្រជាជនកម្ពុជាភាគច្រើនរស់នៅ និងធ្វើការ ដែលអាចរកចំណូលបានត្រឹមតែការចិញ្ចឹមជីវិតប៉ុណ្ណោះ។ ភាគច្រើន នៃការអភិវឌ្ឍកម្រិតខ្ពស់ក្នុងទសវត្សរ៍កន្លងទៅ បានកើតមាននៅទីក្រុង និងពឹងផ្អែកជាសំខាន់ទៅលើកំណើន នៃការនាំចេញសម្លៀកបំពាក់ និងការរីកចម្រើនខាងវិស័យទេសចរណ៍ ព្រមទាំងការលូតលាស់នៃឧស្សាហកម្មសំណង់ ដែលអាចជាស្ថានភាពងាយរងគ្រោះ ហើយអ្នកទទួលផលចំបងៗពីការអភិវឌ្ឍនៅក្នុងទសវត្សរ៍កន្លងទៅក៏មានចំនួនតិចតួចដែរ។ ដោយគិតគូរអំពីការប្រឈមទាំងនេះ ផែនទីបង្ហាញផ្លូវនេះផ្តោតលើការធ្វើអត្តសញ្ញាណ និងអធិប្បាយអំពីអន្តរាគមន៍នានា ដែលអាចជួយកែលម្អគុណភាពនៃការរស់នៅ ដោយផ្តោតលើកំណើនលទ្ធភាពក្នុងការ ទទួលផលិតផល និងសេវាកម្មនានា។

ផែនទីបង្ហាញផ្លូវអភិវឌ្ឍន៍បៃតងជាតិ នឹងផ្តោតលើការដោះស្រាយបញ្ហាចំនួនប្រាំពីរ :

- ការទទួលបានទឹកស្អាត និងអនាម័យ
- ការទទួលបានថាមពលកកើតឡើងវិញ
- ការទទួលបានព័ត៌មាន និងចំណេះដឹង
- ការទទួលបានមធ្យោបាយដើម្បីសម្រួលដល់ការធ្វើដំណើរ
- ការទទួលបានហិរញ្ញវត្ថុ និងការវិនិយោគ
- ការទទួលបានសន្តិសុខស្បៀង (កសិកម្ម) និងផលិតផលដែលគ្មានជាតិគីមី និង
- ការទទួលបាននូវការប្រើប្រាស់ដីធ្លីដោយនិរន្តរភាព ។

តម្រូវការសំរាប់ការទទួលបានទាំងនេះនឹងត្រូវដោះស្រាយ តាមរយៈគម្រោង និងកម្មវិធីអភិវឌ្ឍនសេដ្ឋកិច្ចបៃតង ដែលរួមទាំងការផ្តួចផ្តើមថ្មីៗប្រកបដោយប្រសិទ្ធិភាពខ្ពស់ ក្នុងការថែរក្សាប្រព័ន្ធអេកូឡូស៊ី និងប្រសិទ្ធិភាពខ្ពស់

ខាងការប្រើប្រាស់ធនធាន ដែលអាចផ្តល់ឱកាសសម្រាប់"ការងារបៃតង"ថ្មីៗ។ បើទោះជាមិនមានការរំពឹងថានឹងអាចផ្លាស់ប្តូរភ្លាមៗនៃលំនាំអភិវឌ្ឍន៍នេះក៏ដោយ កំណើនការយកចិត្តទុកដាក់លើសិទ្ធិប្រើប្រាស់ និងការអនុវត្តគោលនយោបាយអភិវឌ្ឍន៍បៃតង ដែលបានលើកស្នើដោយគណៈកម្មការសេដ្ឋកិច្ច និងសង្គម សម្រាប់តំបន់អាស៊ី និងប៉ាស៊ីហ្វិក នៃអង្គការសហប្រជាជាតិ នឹងនាំមកជាបណ្តើរៗនូវគំរូនៃការអភិវឌ្ឍសេដ្ឋកិច្ច ដែលផ្តល់នូវលក្ខខណ្ឌអំណោយផលកាន់តែច្រើនឡើង សម្រាប់អភិវឌ្ឍន៍ធនធានមនុស្ស ភាពធន់ទ្រាំ និងនិរន្តរភាពបរិស្ថាន ជាងវិធាននៃការអនុវត្តតាមបែបសព្វថ្ងៃនេះ។

## វិធានគ្រប់ជ្រុងជ្រោយ

បញ្ហាសព្វថ្ងៃខាងផ្នែកបរិស្ថាន និងសង្គម ជាកិច្ចការអន្តរវិស័យ ដែលត្រូវដោះស្រាយតាមរយៈកិច្ចសហប្រតិបត្តិការពហុវិស័យ។ នៅក្នុងការដោះស្រាយចំពោះការប្រឈមនៅក្នុងកម្រិតអ្នកពាក់ព័ន្ធពីវិស័យជាច្រើនបែបនេះ រាជរដ្ឋាភិបាលកម្ពុជាមានឱកាសក្នុងការបង្កើនឥទ្ធិពលជាវិជ្ជមាន ដើម្បីធ្វើឱ្យមានកំណើនសេដ្ឋកិច្ចបន្ថែមនិងប្រកាន់យកលំនាំនៃការអភិវឌ្ឍដែលមាននិរន្តរភាពបរិស្ថាន កាត់បន្ថយភាពក្រីក្រ និងកែលម្អការចិញ្ចឹមជីវិត។ ក្នុងន័យនេះ ក្រុមការងារបច្ចេកទេសអន្តរក្រសួងស្តីពីការអភិវឌ្ឍបៃតង បានលើកស្នើឱ្យមានអន្តរាគមន៍មួយចំនួន នៅក្នុងរយៈពេលខ្លី មធ្យម និងរយៈពេលវែង។ ទោះជាយ៉ាងណាក៏ដោយ ដោយហេតុថា គោលគំនិតអំពីគម្រោងដែលបានបកស្រាយនៅក្នុងឯកសារនេះ អាចអនុវត្តទៅបាន អាស្រ័យលើការផ្តល់មូលនិធិ និងការគាំទ្រពីសហគមន៍ម្ចាស់ជំនួយ ប្រការសំខាន់គឺថា ក្រសួងនានា ត្រូវបង្កើតផែនការការងារ ដើម្បីបង្ហាញពីការប្តេជ្ញាខ្លាំងក្លារបស់ខ្លួន ក្នុងការអនុវត្តផែនទីបង្ហាញផ្លូវនេះ។ ផែនទីបង្ហាញផ្លូវអភិវឌ្ឍន៍បៃតងជាតិ មានន័យថា *ជាការធ្វើឱ្យកម្ពុជាមានការរីកចម្រើនតាមវិធីមួយ ដែលមានប្រសិទ្ធិភាពខ្ពស់ ដោយប្រើប្រាស់ធនធានតិចតួច និងបញ្ចេញសំណល់តិចជាងមុន ដើម្បីឱ្យស្អាតដោយគ្មានការបំពុលបរិស្ថាន និងដើម្បីឱ្យមានលក្ខណៈបៃតង* ដោយថែរក្សាភាពបៃតង រក្សាផ្លូវទឹក និងបេតិកភណ្ឌធម្មជាតិ ព្រមទាំងអភិវឌ្ឍន៍សង្គមតាមរូបភាពមួយ ដែលមានចីរភាព ដើម្បីឱ្យមនុស្សជំនាន់ក្រោយ អាចទទួលបានទាំងកំណើន សេដ្ឋកិច្ច និងបរិស្ថានល្អសម្រាប់ការរស់នៅផងដែរ។

## ផែនទីបង្ហាញផ្លូវ

ផែនទីបង្ហាញផ្លូវនេះ លើកស្នើឱ្យអនុវត្តអន្តរាគមន៍មួយចំនួន ដើម្បីជួយបញ្ជ្រាបកង្វល់អំពីការអភិវឌ្ឍបៃតង ទៅក្នុងក្របខ័ណ្ឌទាំងមូលនៃការអភិវឌ្ឍនៅកម្ពុជា ដែលអន្តរាគមន៍ទាំងនោះ នឹងជួយពង្រឹងដល់កិច្ចសហប្រតិបត្តិការអន្តរក្រសួង និង អ្នកពាក់ព័ន្ធនានា។

នៅក្នុងរយៈពេលខ្លី (២-៥ឆ្នាំ)ខាងមុខ ការអនុវត្តអន្តរាគមន៍នានា ដែលលើកស្នើឡើងនៅក្នុងផែនទីបង្ហាញផ្លូវនេះ នឹងរួមជាវិភាគទានក្នុងការជម្រុញសេដ្ឋកិច្ច សន្សំសំចៃ និងបង្កើតការងារធ្វើ ព្រមទាំងការពារដល់ក្រុមមនុស្ស ដែលងាយរងគ្រោះ ព្រមទាំងកែលម្អនិរន្តរភាពបរិស្ថានផងដែរ។ ជាសង្ខេប អ្នកពាក់ព័ន្ធទាំងអស់ បានលើកស្នើឡើង គួរៈ

ក. បង្កើតក្រុមប្រឹក្សាជាតិ ឬគណៈកម្មាធិការជាតិអភិវឌ្ឍន៍បៃតងថ្នាក់រដ្ឋមន្ត្រី

ខ. បង្កើតការយល់ដឹងជាសាធារណៈ និងដំណើរការពិគ្រោះយោបល់របស់ជាតិ ដោយផ្សព្វផ្សាយសម្ភារៈសម្រាប់ការអប់រំ និងព័ត៌មាននានា ទាក់ទងនឹងការអភិវឌ្ឍបៃតង

គ. ដាក់បញ្ចូលកិច្ចផ្តួចផ្តើមភូមិបៃតង/ទីក្រុងបៃតង ទៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ

ឃ. កសាងយុទ្ធសាស្ត្រជាតិសម្រាប់ឧស្សាហកម្មបៃតង ដោយផ្អែកលើប្រសិទ្ធិភាពនៃធនធាន និងយុទ្ធសាស្ត្រ 3R (កាត់បន្ថយ ប្រើប្រាស់ឡើងវិញ កែច្នៃឡើងវិញ)

ង. បង្កើតវិធានការ ដើម្បីជម្រុញឱ្យមាននិរន្តរភាពកសិកម្ម ដែលរួមទាំង ប្រព័ន្ធធានារ៉ាប់រងដែលផ្អែកលើសន្ទស្សន៍ និង/ ឬ មីក្រូហិរញ្ញប្បទាន និង

ច. បង្កើតប្រព័ន្ធសម្រាប់ការវិនិយោគលើកិច្ចផ្តួចផ្តើមច្នៃប្រឌិត (ដែលអាចបន្តអនុវត្តនៅក្នុងរយៈពេលមធ្យម និងរយៈ ពេលវែង)

ឆ. បង្កើតវិធានការនានា ដើម្បីពង្រឹងវិស័យឧស្សាហកម្មបរិស្ថានជាតិ។

នៅក្នុងរយៈពេលមធ្យម (៥-១០ ឆ្នាំ) គោលគំនិតនៃគម្រោង ត្រូវផ្តោតលើការអភិវឌ្ឍជនបទដោយចីរភាព ដែលស្របជាមួយយុទ្ធសាស្ត្រវិមជ្ឈការ និងសហវិមជ្ឈការរបស់កម្ពុជា អន្តរាគមន៍នានាដើម្បីជម្រុញការអភិវឌ្ឍដោយចីរភាពនៅក្នុងវិស័យ*កសិកម្ម ថាមពល ព្រៃឈើ ទឹក ការគ្រប់គ្រងសំណល់ និងការដឹកជញ្ជូន*។ សម្រាប់រយៈពេលវែង (១០-២០ ឆ្នាំ) អន្តរាគមន៍ដែលបានលើកស្នើឡើង បានផ្តោតលើការជម្រុញឱ្យមានការអភិវឌ្ឍសេដ្ឋកិច្ចដោយចីរភាព និង ទូលំទូលាយ ការសម្រេចគោលដៅអភិវឌ្ឍន៍សេដ្ឋកិច្ចកម្ពុជា សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច ស្ថិរភាពសង្គម និងបរិស្ថាន។ លើសពីនេះប្រការសំខាន់គឺ អន្តរាគមន៍នានានៅក្នុងរយៈពេលវែងត្រូវតែបន្តពង្រឹងសក្តានុពល នៃ អន្តរាគមន៍ដែលបានអនុវត្តនៅក្នុងរយៈពេលមធ្យម ដូចជា តាមរយៈការអនុវត្តបទប្បញ្ញត្តិនានា និងគោលនយោបាយសារពើពន្ធ ដើម្បីបង្កើតឱ្យមានការលើកទឹកចិត្តសម្រាប់ជម្រុញការអភិវឌ្ឍបៃតង។ ការធ្វើបែបនេះ នឹងបង្កើតភាពចុះសម្រុងគ្នានៅក្នុងលំនាំផ្លូវនៃការអភិវឌ្ឍ និង រួមចំណែកកាត់បន្ថយការពឹងផ្អែក របស់កម្ពុជា មកលើសេដ្ឋកិច្ច ដែលបញ្ចេញកាបូនច្រើន និង ការធ្វើឱ្យប្រព័ន្ធអេកូឡូស៊ីរេចរឹល។ ដូច្នេះ ការអភិវឌ្ឍបៃតង និងការអភិវឌ្ឍប្រកបដោយភាពឆ្លាតវៃ នឹងជួយកែលម្អសុខភាព និងគុណភាពនៃការរស់នៅរបស់ប្រជាពលរដ្ឋ រិតតែមានភាពល្អប្រសើរឡើង។

**អនុសាសន៍**

រាជរដ្ឋាភិបាលកម្ពុជា គួរជម្រុញឱ្យសហគ្រាសឯកជនចូលរួមយ៉ាងសកម្ម នៅក្នុងការបង្កើតភាពបៃតង នៃការអភិវឌ្ឍវិស័យឯកជន និង បញ្ជ្រាបកិច្ចផ្តួចផ្តើមអភិវឌ្ឍន៍បៃតង តាមរយៈ ១)បង្កើតការយល់ដឹងជារួម ២) ការអភិវឌ្ឍសមត្ថភាពសម្រាប់វិស័យនានា ដើម្បីបង្កើនប្រសិទ្ធិភាពខាងអេកូឡូស៊ីនៅក្នុងការផលិត និងការប្រើប្រាស់ ៣) ដាក់បញ្ចូលការអភិវឌ្ឍបៃតង ទៅក្នុងយុទ្ធសាស្ត្រអភិវឌ្ឍន៍ដោយចីរភាពរបស់ជាតិ និង ៤)បង្កើនការអនុវត្តគោលនយោបាយអភិវឌ្ឍន៍បៃតង ដើម្បីជម្រុញសកម្មភាពសេដ្ឋកិច្ចបៃតង នៅតាមវិស័យនានា។ នៅទីបំផុត ក្រសួងមហាផ្ទៃគួរចូលរួមឱ្យបានខ្លាំងក្លា ដើម្បីធ្វើឱ្យការអភិវឌ្ឍបៃតង នៅថ្នាក់ខេត្តបានទទួលជោគជ័យ ដោយសំរបសំរួលឱ្យមន្ទីរនានាបានចូលរួម និងផ្តល់សិទ្ធិអំណាចដល់មន្ទីរទាំងនោះក្នុងការធានាថា គម្រោងអភិវឌ្ឍន៍សេដ្ឋកិច្ចបៃតងអាចបញ្ជ្រាបយ៉ាងមានប្រសិទ្ធិភាពទៅក្នុងការកសាងផែនការអភិវឌ្ឍ។

# ១. សេចក្តីផ្តើម

កម្ពុជាគឺជាប្រទេសកសិកម្ម។ សព្វថ្ងៃនេះ មានប្រជាជនប្រមាណជា៨០.២៥% រស់នៅជនបទ ដោយពឹងផ្អែកជាចំបង លើវិស័យកសិកម្មសម្រាប់ការចិញ្ចឹមជីវិត ដែលរួមទាំងការដាំដំណាំ នេសាទ ចិញ្ចឹមសត្វ ការប្រមូលផលព្រៃឈើ និង អនុផលព្រៃឈើ (RGC, 2008a)។ នៅក្នុងទសវត្សរ៍កន្លងមក មានការរីកចម្រើនគួរឱ្យកត់សំគាល់លើវិស័យមួយចំនួន ដែលមានសារៈសំខាន់សម្រាប់ការអភិវឌ្ឍធនធានមនុស្ស សិទ្ធិទទួលបានការអប់រំ និងសេវាកម្មសុខាភិបាល ត្រូវបានកែលម្អ ភាពក្រីក្រត្រូវបានកាត់បន្ថយជាបណ្តើរៗ ព្រមទាំងបានធ្វើឱ្យមានការរីកចម្រើនក្នុងការសម្រេចគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា។ ទោះជាយ៉ាងណាក៏ដោយ ការរីកចម្រើនបានតិចតួចខាងការអភិវឌ្ឍធនធានមនុស្ស នៅតែឆ្លុះបញ្ចាំងអំពីលក្ខខណ្ឌដ៏លំបាកនៃការរស់នៅរបស់ប្រជាជន ជាពិសេស នៅតាមទីជនបទ ដែលប្រជាពលរដ្ឋភាគច្រើនរស់នៅ និងធ្វើការបានសម្រាប់តែការចិញ្ចឹមជីវិត ប៉ុណ្ណោះ។ ភាគច្រើននៃកំណើនសេដ្ឋកិច្ចកម្រិតខ្ពស់នៅក្នុងទសវត្សរ៍កន្លងមក បានកើតមានតែនៅតាមទីប្រជុំជន ហើយបានពឹងផ្អែកលើការនាំចេញសម្លៀកបំពាក់ដែលមានកម្រិតខ្ពស់បំផុត និងការរីកចម្រើនខាងវិស័យទេសចរណ៍ ព្រមទាំងឧស្សាហកម្មសំណង់ (UNDP, 2007)។

យុទ្ធសាស្ត្រចតុកោណដំណាក់កាលទីពីរ របស់រដ្ឋាភិបាល និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ផ្តល់ជាផែនទីបង្ហាញផ្លូវឆ្ពោះទៅកំណែលម្អអភិបាលកិច្ច កំណើនការវិនិយោគសាធារណៈនៅជនបទ និងគាំទ្រដល់ការអភិវឌ្ឍវិស័យឯកជន ដែលជាអ្នកបង្កើតការងារ។ ទន្ទឹមនឹងនេះ នៅក្នុងការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិចុងក្រោយនេះ រាជរដ្ឋាភិបាលកម្ពុជា បានសម្រេចបែរចេញពីវិធានកសាងផែនការលំអិតដែលធ្លាប់ធ្វើកន្លងមក ដោយឈានទៅផ្តោតលើគោលដៅ និងសកម្មភាពជាយុទ្ធសាស្ត្រ។ អាស្រ័យហេតុនេះរាជរដ្ឋាភិបាលកម្ពុជាបានប្រកាសផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិចុងក្រោយនេះ ថាជាឯកសារតម្រង់ទិស និងជាឯកសារយោងតែមួយ ដែលមានលក្ខណៈទូលំទូលាយ សម្រាប់ឈានទៅសម្រេចគោលដៅ ចំណុចដៅ និងសកម្មភាពជាអាទិភាពនានា។ ដោយសារតែសមត្ថភាពខាងស្ថាប័ន ដែលនៅមានលក្ខណៈទន់ខ្សោយនៅឡើយ គេត្រូវចាត់ជាអាទិភាពនូវកិច្ចប្រឹងប្រែងអនុវត្តនានា និងត្រូវផ្តោតលើតំបន់ និងវិស័យនានា ដែលផ្តល់ផលមកវិញជាអតិបរមា សម្រាប់កែលម្អសុខុមាលភាពប្រជាជន ការសម្រេចបាននូវវិបុលភាពរួម និងការធានាឱ្យមានសន្តិភាព និងស្ថិរភាព សម្រាប់រយៈពេលយូរអង្វែង។ *កសិកម្ម ហេដ្ឋារចនាសម្ព័ន្ធ ការអភិវឌ្ឍទីក្រុង ការងារ និង ការអភិវឌ្ឍធនធានមនុស្ស* គឺ ជាវិស័យអាទិភាព ដែលបានធ្វើអត្តសញ្ញាណនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិនេះ។

ការបង្កើតឱកាសខាងសេដ្ឋកិច្ច-សង្គមនៅក្នុងវិស័យទាំងនេះ ត្រូវតែធ្វើឡើងតាមវិធីមួយ ដែលបញ្ចៀសគ្រោះថ្នាក់ជាបន្ថែមទៀត និងការរេចរឹលបរិស្ថាន។ កំណើនសេដ្ឋកិច្ច និងកំណើនចំនួនប្រជាពលរដ្ឋយ៉ាងឆាប់រហ័ស រួមផ្សំជាមួយផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ បាននិងកំពុងមានឥទ្ធិពលអវិជ្ជមានយ៉ាងខ្លាំងមកលើបរិស្ថាន និងសុខភាពមនុស្ស។ បច្ចុប្បន្ននេះ ប្រការចាំបាច់គឺត្រូវបញ្ជ្រាបគោលនយោបាយអភិវឌ្ឍន៍បៃតងទៅក្នុងយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ រួមជាមួយការបង្កើនចំណេះដឹង និងជំនាញរបស់អ្នកកសាងគោលនយោបាយ និងអ្នកធ្វើសេចក្តីសម្រេចនានា ដើម្បីអាច

បញ្ជ្រាបបានដោយជោគជ័យនូវវិធានការនៃគោលនយោបាយសំខាន់ៗ និងឧបករណ៍នានា សម្រាប់ពង្រឹងគុណភាព នៃការអភិវឌ្ឍសេដ្ឋកិច្ចនៅកម្ពុជា។ លើសពីនេះ វិបត្តិសេដ្ឋកិច្ចក្នុងពេលថ្មីៗនេះ តម្រូវឱ្យមានកញ្ចប់ជំនួយសេដ្ឋកិច្ច សម្រាប់ទ្រទ្រង់កំណើនសេដ្ឋកិច្ច ក្នុងករណីដែលពុំមានភាពប្រាកដប្រជា។នៅក្នុងការកសាងផែនការ និងការផ្តេរមូលនិធិសម្រាប់ការគាំទ្របែបនេះ រាជរដ្ឋាភិបាលកម្ពុជា អាចជ្រើសរើសយកវិធានការឆ្លើយតប និងការវិនិយោគនានា ដែលអាចផ្តល់នូវកំណើន និងការអភិវឌ្ឍសេដ្ឋកិច្ចកម្រិតខ្ពស់ ដែលផ្តល់ផលដល់សង្គមទាំងមូល និងមាននិរន្តរភាពបរិស្ថាន សម្រាប់រយៈពេលមធ្យម និងរយៈពេលវែង។

ក្រោមកិច្ចសហការជាមួយស្ថាប័នពាក់ព័ន្ធទាំងអស់ ក្រសួងបរិស្ថានបានរៀបចំ**ផែនទីបង្ហាញផ្លូវអភិវឌ្ឍន៍បៃតង**នេះឡើង ដើម្បី**បញ្ចូលគំនិត និងគម្រោងនានា អំពីការអភិវឌ្ឍបៃតង ទៅក្នុងការអភិវឌ្ឍជាយុទ្ធសាស្ត្ររបស់ជាតិ**។ ផែនទីបង្ហាញផ្លូវនេះនឹងបង្កើតជាមូលដ្ឋានសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច ដែលសមស្របជាមួយបរិស្ថាន តាមរយៈការជម្រុញឱ្យមានការប្រើប្រាស់ និងការផលិតដោយនិរន្តរភាព ការធ្វើឱ្យទីផ្សារនិងជំនួញនានាមានលក្ខណៈបៃតង ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធដែលមាននិរន្តរភាព ពន្ធបៃតង និងកំណែទម្រង់ថវិកា និងការតាមដានសូចនាករណ៍ប្រសិទ្ធិភាពអេកូឡូស៊ី ព្រមទាំងមានគោលដៅសំរបសំរួលដល់ក្រសួង-ស្ថាប័នពាក់ព័ន្ធ អង្គការមិនមែនរដ្ឋាភិបាល អង្គការអន្តរជាតិ ដៃគូរ អភិវឌ្ឍន៍ និងគ្រឹះស្ថានអប់រំទាំងអស់ សហការគ្នា ដើម្បីដោះស្រាយការប្រឈមសព្វថ្ងៃ ឆ្ពោះទៅការអភិវឌ្ឍប្រកបដោយចីរភាព។

## ១.១ ស្ថានភាពសេដ្ឋកិច្ចបច្ចុប្បន្ន

សព្វថ្ងៃនេះ មូលដ្ឋានសេដ្ឋកិច្ចរបស់កម្ពុជា កំពុងងាកចេញពីវិស័យកសិកម្ម ព្រៃឈើ និងជលផល (ដែលមានប្រមាណ ៣១.៤% នៃផលទុនក្នុងស្រុកសរុប (GDP) ទៅរកវិស័យឧស្សាហកម្ម ដែលមានប្រមាណ ២៧% នៃផលទុនក្នុងស្រុក សរុប (MoP, 2008)។ វិស័យសេវាកម្ម (ដែលមានកំណើនយ៉ាងច្រើនលើវិស័យទេសចរណ៍ អចលនទ្រព្យ និងសេវាកម្មដទៃទៀត) គឺ ជាវិស័យមួយក្នុងចំណោមវិស័យធំៗនៅក្នុងការអភិវឌ្ឍសេដ្ឋកិច្ច ដែលមានភាគចំណែក ៣៦% នៃផលទុនក្នុងស្រុកសរុប និងភាគច្រើនបានពីការរីកចម្រើននៃវិស័យឧស្សាហកម្មទេសចរណ៍ (CDRI, 2008)។ ទោះជាយ៉ាងណាក៏ កសិកម្មនៅតែត្រូវបានចាត់ទុកថាមានសារៈសំខាន់យ៉ាងខ្លាំងសម្រាប់ទីជនបទ ដែលភាគច្រើនពឹងផ្អែកលើការធ្វើស្រែសម្រាប់ការចិញ្ចឹមជីវិត។

អត្រាអតិផរណា ត្រូវបានរាយការណ៍ថា បានឈានដល់កម្រិតកំពូល ២៥.៧២% នៅក្នុងត្រីមាសទីពីរឆ្នាំ ២០០៨ ដែលបណ្តាលពីកំណើនថ្លៃប្រេង កំណើនថ្លៃស្បៀង និងការប្រែប្រួលថ្លៃប្រាក់ដុល្លា (MoP, 2008)។ នៅចុងឆ្នាំនោះ អត្រាប្រែប្រួលនេះមានក្នុងរង្វង់ ១៣.៤៦%។ អត្រានេះត្រូវបានគេរំពឹងថានឹងថយចុះមកនៅត្រឹមលេខមួយខ្ទង់

នៅក្នុងឆ្នាំ ២០០៩ (MoP, 2008) ។ អត្រា GDP ក្នុងម្នាក់ៗ បានកើនឡើងពី ១,៨៦ លានរៀល[1] នៅឆ្នាំ ២០០៥ ដល់ ២,៤២ លានរៀល នៅឆ្នាំ ២០០៧ ហើយត្រូវបានគេរំពឹងថាកើនឡើងដល់ ៣,៥០ លានរៀល ។ ទោះជាយ៉ាងណាក៏ដោយ កំណើនយ៉ាងច្រើននៃថ្លៃទំនិញប្រើប្រាស់នៅក្នុងឆ្នាំ២០០៨ ភាគច្រើនកើតឡើងដោយសារ កំណើនយ៉ាងខ្ពស់នៃសន្ទស្សន៍ថ្លៃទំនិញ (CPI) សម្រាប់ស្បៀងអាហារ ថ្លៃប្រេងលើទីផ្សារអន្តរជាតិ និងកត្តាផ្សេងៗទៀត ។ លើសពីនេះ នៅក្នុងពេលថ្មីៗនេះ កម្ពុជាបានពុះពារ ដោះស្រាយបញ្ហារោគផ្តាសាយបក្សី និងមេរោគអេដស៍ ហើយនៅពេលថ្មីៗនេះ ស្ថានភាពទាំងនេះទំនងជាស្ថិតក្រោមការគ្រប់គ្រងឱ្យមានស្ថិរភាព ។ កំណើនចំនួនភ្ញៀវទេសចរ បានកើនឡើងយ៉ាងច្រើន ដែលធ្វើឱ្យមានកំណើនយ៉ាងខ្លាំងដល់ការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធ ដែលមានស្រាប់ ។ហើយការរាលដាលនៅពេលថ្មីៗនេះ នៃជម្ងឺឆ្លងគឺ ផ្តាសាយជ្រូក រួមផ្សំជាមួយវិបត្តិហិរញ្ញវត្ថុពិភពលោក មានឥទ្ធិពលអវិជ្ជមាន មកលើសេដ្ឋកិច្ចកម្ពុជា និងបានរួមចំណែកធ្វើឱ្យមានការអូសបន្លាយការអនុវត្តគោលនយោបាយនានារបស់ជាតិ ។

ជាទូទៅ កំណើនសេដ្ឋកិច្ច បានជម្រុញដោយសារតែវិស័យចំនួនបួនគឺ កសិកម្ម កាត់ដេរ ទេសចរណ៍ និងការសាងសង់ ។ បើទោះជាសេដ្ឋកិច្ចកម្ពុជាបានរងការថយចុះក៏ដោយ សេដ្ឋកិច្ចនេះនៅមានស្ថានភាពល្អនៅឡើយ (MoEF, 2007) ដែលគួសបញ្ជាក់តាមរយៈកំណើនជាបន្តនៃការវិនិយោគលើវិស័យកសិកម្ម ការអភិវឌ្ឍបានទូលំទូលាយនៃវិស័យមិនមែនកសិកម្ម ស្ថិរភាពនយោបាយ ការចូលរួមយ៉ាងសកម្មនៃវិស័យឯកជន កិច្ចប្រឹងប្រែងកែទម្រង់ កំណើនជំនួយអភិវឌ្ឍន៍ផ្លូវការ និងការវិនិយោគដោយផ្ទាល់ពីបរទេស នៅតែមានជាបន្តទៀត ។

ប្រព័ន្ធស្រោចស្រពក្នុងប្រទេសកម្ពុជា មានត្រឹមកម្រិតកំណត់តែប៉ុណ្ណោះ ហើយប្រមាណ ៨០% នៃដីកសិកម្មនៅពឹងផ្អែកតែលើទឹកភ្លៀង (MoEF, 2007) ។

យុទ្ធសាស្ត្រចតុកោណដំណាក់កាលទីពីរ របស់រាជរដ្ឋាភិបាលកម្ពុជា យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បានផ្អែកលើជំហរនយោបាយនៃកំណើនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ ។ របៀបវារៈកំណែទម្រង់របស់រាជរដ្ឋាភិបាលកម្ពុជា នៅតែផ្តោតជាសំខាន់លើកំណែទម្រង់សេដ្ឋកិច្ចកាន់តែស៊ីជម្រៅ និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ដែលរួមទាំង កំណែទម្រង់សារពើពន្ធ និងសាច់ប្រាក់ ការជម្រុញពាណិជ្ជកម្ម និងការវិនិយោគ កំណែទម្រង់រដ្ឋបាល ការរំសាយទ័ព និងកំណែលម្អការគ្រប់គ្រងព្រៃឈើ និងជលផល ។

## ១.២ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (២០០៦-២០១០)

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (២០០៦-២០១០) មានគោលដៅធានាថា ដីធ្លី និងធនធានធម្មជាតិ ត្រូវបានប្រើប្រាស់ តាមរូបភាពដែលអាចធានាប្រសិទ្ធិភាព ដើម្បីទ្រទ្រង់ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមដោយចីរភាព និងសមធម៌សម្រាប់ពលរដ្ឋកម្ពុជាគ្រប់រូប ។ នេះជាឯកសារសំខាន់មួយរបស់រាជរដ្ឋាភិបាល ដែលនឹងផ្តល់សេចក្តីលំអិតអំពីសកម្មភាពកម្មវិធី និងគម្រោងលំអិតដែលនឹងត្រូវអនុវត្តដោយក្រសួង និងស្ថាប័នពាក់ព័ន្ធ ក្នុងការសម្រេចគោលដៅអាទិភាពជាតិ ។

[1] យោងតាមអត្រាប្តូរប្រាក់នៅលើទីផ្សារគឺ 1USD= ៤000 រៀល (ខែ កញ្ញា ឆ្នាំ ២០០៩) ។

ឯកសារផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បង្ហាញពីគោលដៅ និងចំណុចដៅនានា ដែលមានចែងក្នុងផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមប្រាំឆ្នាំលើកទីពីរ សម្រាប់ឆ្នាំ ២០០១-២០០៥ យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រសម្រាប់ឆ្នាំ ២០០៣-២០០៥ និងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍។ ក្រសួង និងស្ថាប័ននានារបស់រដ្ឋាភិបាល ម្ចាស់ជំនួយ និងសង្គមស៊ីវិល អង្គការនានា បានពាក់ព័ន្ធនៅក្នុងការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងនៅក្នុងការរៀបចំសេចក្ដីព្រាងផែនទីបង្ហាញផ្លូវអភិវឌ្ឍន៍បៃតងជាតិ ដើម្បីធានាឱ្យមានការរួមបញ្ចូលគ្នា និងការបន្សុីគ្នានូវកិច្ចប្រឹងប្រែងនានា។

សព្វថ្ងៃនេះ រាជរដ្ឋាភិបាលកម្ពុជា បានរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្មឆ្នាំ២០០៩-២០១៣ ដើម្បីផ្ដល់សេចក្ដីលំអិតអំពីសកម្មភាព កម្មវិធី និងគម្រោងលំអិតនានា ដែលត្រូវអនុវត្តដោយក្រសួង និងស្ថាប័នពាក់ព័ន្ធក្នុងការសម្រេចគោលដៅអាទិភាពជាតិ ដូចមានចែងនៅក្នុងយុទ្ធសាស្ត្រចតុកោណ។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម (២០០៩-២០១៣) ចែងអំពីគោលដៅបឋមចំនួនពីរ : *ទីមួយ* ការបន្សុីគ្នានៃរយៈកាលដែលមានចែងនៅក្នុង ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ជាមួយអាណត្តិទីបួននៃរាជរដ្ឋាភិបាល និង *ទីពីរ* ដើម្បីបញ្ចូលនូវឥទ្ធិពល ដែលអាចកើតចេញពីការថយចុះនៃសេដ្ឋកិច្ចពិភពលោក មកលើសេដ្ឋកិច្ចកម្ពុជា។

## ១.៣ យុទ្ធសាស្ត្រចតុកោណ

យុទ្ធសាស្ត្រចតុកោណ ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធិភាព គឺជាឯកសារទូលំទូលាយ និង ចម្រុះមួយ ដែលប្រកាសដោយរាជរដ្ឋាភិបាលកម្ពុជា នៅក្នុងដំណាក់កាលដំបូងនៃអាណត្តិទីបី នៅក្នុងឆ្នាំ ២០០៤។ យុទ្ធសាស្ត្រនេះត្រូវបានដាក់ឱ្យបន្តអនុវត្តសម្រាប់អាណតត្តិទីបួន (២០០៨-២០១៣)។ រាជរដ្ឋាភិបាលកម្ពុជា បានចាត់ទុកយុទ្ធសាស្ត្រ ចតុកោណថាជា **"របៀបវារៈគោលនយោបាយសេដ្ឋកិច្ច-សង្គម"**។ យុទ្ធសាស្ត្រនេះនៅតែមានការពាក់ព័ន្ធនៅក្នុងអាណត្តិទីបួន ដែលក្នុងនោះមានវាក្យខ័ណ្ឌទី(៤០)ចែងអំពី "ការធានាឱ្យមានកំណើនសេដ្ឋកិច្ចដោយចីរភាព ដែលប្រសិនបើ គ្មានយុទ្ធសាស្ត្រនេះទេ គេមិនអាចបង្កើតការងារ និងការរកប្រាក់ចំណូលបានឡើយ ហើយរាជរដ្ឋាភិបាលនឹងបន្តបង្កើន ពិពិធកម្ម និងពង្រឹងភាពប្រកួតប្រជែងនៃសេដ្ឋកិច្ចរបស់កម្ពុជា ដោយធានាឱ្យមានបរិយាកាសអំណោយផលកម្រិតខ្ពស់ សម្រាប់ការវិនិយោគសាធារណៈ និងឯកជន (ក្នុងស្រុក និងមកពីបរទេស) សម្រាប់អភិវឌ្ឍន៍វិស័យសំខាន់ៗដូចតទៅ : (១) កសិកម្ម (២) ទឹក និងប្រព័ន្ធស្រោចស្រព (៣) ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន (៤) អគ្គិសនី (៥) ការអភិវឌ្ឍធនធានមនុស្ស (៦) ឧស្សាហកម្មអតិពលកម្ម និងឧស្សាហកម្មកែច្នៃស្បៀងសម្រាប់ការនាំចេញ (៧) ទេសចរណ៍ (៨) ការធ្វើអាជីវកម្មប្រេង ឧស្ម័នធម្មជាតិ និងរ៉ែដទៃទៀត (៩) បច្ចេកវិទ្យាព័ត៌មាន និងការប្រាស្រ័យឆ្លើយឆ្លង និង (១០) ពាណិជ្ជកម្ម" (RGC, 2008)។ ស្របជាមួយវិស័យអាទិភាពទាំងនេះ ផែនទីបង្ហាញផ្លូវនេះផ្ដោតលើវិស័យនានាទាំងអស់ ដែលមាន លក្ខណៈអំណោយផលសម្រាប់*កំណើនសេដ្ឋកិច្ច និង និរន្តរភាពបរិស្ថាន*។

លើសពីនេះ រាជរដ្ឋាភិបាលកម្ពុជា បានបង្កើតយុទ្ធសាស្ត្រចតុកោណ ជាឧបករណ៍គាំទ្រមួយ ដើម្បីអនុវត្តកំណែទម្រង់នយោបាយរបស់ខ្លួននៅក្នុងអាណត្តិទីបីនៃសភាជាតិ និងបន្តទៅជំហានទីពីរនៃយុទ្ធសាស្ត្រនេះ ដើម្បីសម្រេចបាននូវការកាត់បន្ថយភាពក្រីក្រ ការអភិវឌ្ឍ ការរីកចម្រើន វិបុលភាព ភាពចុះសម្រុងគ្នានៃប្រទេសជាតិ និងសុភមង្គលរបស់ប្រជាពលរដ្ឋកម្ពុជា។ យុទ្ធសាស្ត្រចតុកោណ គឺជារចនាសម្ព័ន្ធចម្រុះមួយនៃចតុកោណដែលមានទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធ (សូមអានខាងក្រោមនេះ)។

## យុទ្ធសាស្ត្រចតុកោណ



# ២. និដ្ឋភាពរួមនៃផែនទីបង្ហាញផ្លូវការអភិវឌ្ឍបៃតងជាតិ

## ២.១ ចក្ខុវិស័យ ៖ វិបុលភាព និងនិរន្តរភាពនៃការចិញ្ចឹមជីវិត

ផែនទីបង្ហាញផ្លូវអភិវឌ្ឍន៍បៃតងជាតិ ប្រមើលមើលនូវគោលបំណងរួមនៃកំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍ សុខុមាលភាពប្រជាពលរដ្ឋ និងគុណភាពបរិស្ថាន ដែលនឹងជម្រុញឱ្យមានការកែលម្អរបរចិញ្ចឹមជីវិតរបស់ពលរដ្ឋកម្ពុជា។ ស្របគ្នានឹងកំណើនសេដ្ឋកិច្ច ដែលត្រូវបានចាត់ទុកថាជាលក្ខខណ្ឌដំបូងសម្រាប់ការអភិវឌ្ឍមនុស្ស និរន្តរភាពបរិស្ថាន គឺជាផ្នែករួមនៃកំណើនសេដ្ឋកិច្ច និងសុខុមាលភាពរបស់ប្រជាជាតិកម្ពុជាទាំងមូល។ ចក្ខុវិស័យរួមនៃផែនទីបង្ហាញផ្លូវអភិវឌ្ឍន៍បៃតងជាតិ មានគោលដៅ ធ្វើឱ្យកម្ពុជាក្លាយជាប្រទេសដែលមានលក្ខខណ្ឌងាយស្រួលសម្រាប់រស់នៅយ៉ាងរស់រវើក ដែលជនកម្ពុជាគ្រប់រូបស្រឡាញ់ និងមានមោទនភាពក្នុងការហៅថា មាតុភូមិ។

នៅក្នុងបរិបទនេះ ផែនទីបង្ហាញផ្លូវអភិវឌ្ឍន៍បៃតងជាតិ បានលើកស្នើឱ្យមានជម្រើសមួយចំនួនសម្រាប់ស្ថានភាព ឈ្នះ-ឈ្នះ-ឈ្នះ រវាងសេដ្ឋកិច្ច បរិស្ថាន និងសង្គម ដើម្បីបង្ហាញថា ការអភិវឌ្ឍសេដ្ឋកិច្ចឆាប់រហ័ស និរន្តរភាពបរិស្ថាន និងសុខុមាលភាពរបស់ប្រជាពលរដ្ឋ អាចសម្រេចបានដោយគ្មានការបង់ខាតឡើយនៅក្នុងរយៈពេលវែង។ ដោយផ្អែកលើវិធានគ្រប់ជ្រុងជ្រោយរបស់គណៈកម្មការសេដ្ឋកិច្ច និងសង្គមសម្រាប់តំបន់អាស៊ី និងប៉ាស៊ីហ្វិកនៃអង្គការសហប្រជាជាតិស្ដីពីការអភិវឌ្ឍបៃតង ផែនទីបង្ហាញផ្លូវនេះ ត្រូវបានរៀបរៀងឡើងដោយទទួលស្គាល់ថា សេដ្ឋកិច្ច បរិស្ថាន និងសង្គម មិនអាចកាត់ផ្ដាច់ចេញពីគ្នាបានឡើយ ប៉ុន្តែជាសមាសភាគ ដែលពឹងផ្អែកគ្នាទៅវិញទៅមក និងពាក់ព័ន្ធគ្នាយ៉ាងជិតស្និទ្ធ។

## ២.២ គោលដៅ ៖ ធ្វើឱ្យការអភិវឌ្ឍមានលក្ខណៈបៃតង

ជារួម កិច្ចផ្ដួចផ្ដើមអភិវឌ្ឍន៍បៃតង អាចពង្រឹងនិរន្តរភាពនៃកំណើនសេដ្ឋកិច្ច តាមរយៈការបង្កើននិរន្តរភាពនៃការប្រើប្រាស់ និងការផលិត ដោយធ្វើឱ្យទីផ្សារ និងជំនួញនានាមានលក្ខណៈបៃតង ដោយបង្កើតបរិយាកាសអំណោយផលសម្រាប់បង្កើតនិរន្តរភាពនៃហេដ្ឋារចនាសម្ព័ន្ធ ដែលអាចធ្វើឱ្យប្រជាពលរដ្ឋមានកំណើនលទ្ធភាពក្នុងការទទួលបានផលិតផល និងសេវាកម្មសំខាន់ៗ និងធានាឱ្យមានសិទ្ធិស្មើគ្នាក្នុងការទទួលបានធនធាន ទាំងសម្រាប់បុរស និងស្ត្រី។ កំណើនការអនុវត្តបរិធានគោលនយោបាយសារពើពន្ធ ដូចជាពន្ធបៃតងនិងកំណែទម្រង់ថវិកា អាចបង្ហាញយ៉ាងច្បាស់លាស់អំពីការកំណត់ថ្លៃ និងមាននាទីជាកត្តាដ៏ខ្លាំងក្លា ដើម្បីបង្កើនប្រសិទ្ធិភាពអេកូឡូស៊ី សម្រាប់កំណើនសេដ្ឋកិច្ចនៅកម្ពុជា។

## ២.៣ គោលបំណង

ផែនទីបង្ហាញផ្លូវនេះ រួមបញ្ចូលនូវគោលបំណងរួមនៃយុទ្ធសាស្ត្រអភិវឌ្ឍន៍ដែលមានពីមុនមក ជាមួយការបង្កើតនិងការធានាឱ្យមានការអភិវឌ្ឍបៃតង ដែលត្រូវបានឱ្យនិយមន័យថា *ការរីកចម្រើនសេដ្ឋកិច្ចដោយនិរន្តរភាពខាងបរិស្ថាន ដោយពង្រឹងការអភិវឌ្ឍដែលបញ្ចេញកាបូនតិចបំផុត និងមានលក្ខណៈពេញលេញខាងផ្នែកសង្គម* ។ នៅកម្ពុជា ការអភិវឌ្ឍបៃតង មានគោលដៅរួម

បញ្ចូលគ្នានូវ គោលបំណងនៃការអភិវឌ្ឍ និងគោលបំណងខាងបរិស្ថាន តាមរយៈការអនុវត្តគោលនយោបាយ ដែលរៀបចំឡើងសម្រាប់ដោះស្រាយ តម្រូវការចាំបាច់សម្រាប់ជនគ្រប់រូប ដែលរួមទាំង ក្រុមអ្នកទន់ខ្សោយ ដើម្បីបង្កើតការងារធ្វើ បង្កើនភាពធន់ទ្រាំរបស់បរិស្ថាន និងរបស់ប្រជាពលរដ្ឋ នៅចំពោះមុខនៃឥទ្ធិពលអវិជ្ជមាននានា ដូច្នេះជាការធានាបាននូវកំណើនសេដ្ឋកិច្ច សុខុមាលភាពប្រជាពលរដ្ឋ និងបរិស្ថាន សម្រាប់រយៈពេលវែង ព្រមទាំងលើកកំពស់ស្ថានភាពរបស់ស្ត្រី ដើម្បីធានានូវសង្គមមួយ ដែលមានសមភាពយេនឌ័រ ។

ផែនទីបង្ហាញផ្លូវអភិវឌ្ឍបៃតងជាតិ នឹងផ្តោតលើការដោះស្រាយបញ្ហាចំនួនប្រាំពីរ :

- ការទទួលបានទឹកស្អាត និងអនាម័យ
- ការទទួលបានថាមពលកកើតឡើងវិញ
- ការទទួលបានព័ត៌មាន និងចំណេះដឹង
- ការទទួលបានមធ្យោបាយ ដើម្បីសម្រួលដល់ការធ្វើដំណើរ
- ការទទួលបានហិរញ្ញវត្ថុ និងការវិនិយោគ
- ការទទួលបានសន្តិសុខស្បៀង (កសិកម្ម) និងផលិតផល ដែលគ្មានជាតិគីមី និង
- ការប្រើប្រាស់ដីធ្លីដោយនិរន្តរភាព ។

តម្រូវការចាំបាច់ទាំងនេះ នឹងត្រូវដោះស្រាយ តាមរយៈគម្រោង និងកម្មវិធីកំណើនសេដ្ឋកិច្ចបៃតង មធ្យោបាយអភិវឌ្ឍន៍ដែលបញ្ចេញកាបូនតិចបំផុត ដែលរួមទាំងការផ្តួចផ្តើមថ្មីប្រកបដោយប្រសិទ្ធិភាពខ្ពស់ ក្នុងការថែរក្សាប្រព័ន្ធអេកូឡូស៊ី និង ប្រសិទ្ធិភាពខ្ពស់ ខាងការប្រើប្រាស់ធនធាន ដែលអាចផ្តល់ឱកាសសម្រាប់"ការងារបៃតង"ថ្មីៗ ដល់ប្រជាពលរដ្ឋ។ បើទោះជាមិនមានការរំពឹងថា នឹងមានការផ្លាស់ប្តូរភ្លាមៗនៃនិន្នាការអភិវឌ្ឍនេះក៏ដោយ កំណើនការយកចិត្តទុកដាក់លើសិទ្ធិប្រើប្រាស់ និងការអនុវត្តគោលនយោបាយអភិវឌ្ឍន៍បៃតង នឹងនាំមកជាបណ្តើរៗនូវគំរូនៃកំណើនសេដ្ឋកិច្ច ដែលផ្តល់នូវលក្ខខណ្ឌអំណោយផលកាន់តែច្រើនឡើងសម្រាប់ការអភិវឌ្ឍធនធានមនុស្ស ភាពធន់ទ្រាំ និងនិរន្តរភាពបរិស្ថាន ជាងវិធាននៃការអនុវត្តតាមបែបសព្វថ្ងៃនេះ ។

# ៣. ការគំរាមកំហែង

## ៣.១ កំណើនចំនួនប្រជាជន

ទំនាក់ទំនងរវាងកំណើនចំនួនប្រជាជន និងការអភិវឌ្ឍសេដ្ឋកិច្ច ត្រូវបានសិក្សាយ៉ាងទូលំទូលាយ ។ ការសិក្សាមួយចំនួនបានគូសបញ្ជាក់អំពីសំណុំលក្ខណៈនៃសេដ្ឋកិច្ច-សង្គមនៃប្រទេសកម្ពុជា (MoP, 2008) ។ ទោះជាយ៉ាងណាក៏ដោយ មានការគូសបញ្ជាក់ថាកំណើនយ៉ាងឆាប់រហ័សនៃចំនួនប្រជាជន មានឥទ្ធិពលអវិជ្ជមានមកលើកំណើនសេដ្ឋកិច្ច បណ្តាលពីកង្វះខាតយ៉ាងច្រើននៃហេដ្ឋារចនាសម្ព័ន្ធ កម្រិតកំណត់នៃសមត្ថភាពផលិត ភាពគ្មានការងារធ្វើ និងវត្តមានការងារមិនពេញសក្តានុពល ក៏ដូចជា ការផ្តល់មិនបានសមស្របនូវសេវាសុខភាព និងការអប់រំ (MoP, 2008) ។ ក្នុងពេលនោះដែរ រដ្ឋាភិបាលទទួលស្គាល់ថា អត្រាកំណើនចំនួនប្រជាជនដែល

នៅតែខ្ពស់ បង្កើតឱ្យមានការលំបាកធ្ងន់ធ្ងរនៅក្នុងការអនុវត្តកម្មវិធីសម្រាប់កាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍសេដ្ឋកិច្ច ដោយចីរភាព។ ប្រជាជនដែលមានចំនួនច្រើន មានន័យថា មានតម្រូវការយ៉ាងច្រើននូវស្បៀង និងសេវាកម្មសាធារណៈ ដូចជា ការអប់រំ និងការថែទាំសុខភាព។

កំណើនយ៉ាងឆាប់រហ័សនៅក្នុងទីក្រុង បានបង្កឱ្យមានការរេចរឹលខាងបរិស្ថាន។ លើសពីនេះ កំណើនយ៉ាងឆាប់រហ័សនៃចំនួនប្រជាជន គឺជាកត្តាមួយដែលអាចចាត់ទុកថាជាឧបសគ្គចំពោះការអភិវឌ្ឍបៃតង។ ដូច្នេះ ការប្រឈមនេះ នឹងបង្កើតឱ្យមានលទ្ធភាពគ្រប់គ្រាន់ក្នុងការបង្កើតការងារ នៅក្នុងវិស័យឯកជន ដែលអាចស្រូបយកកម្លាំងពលករវ័យក្មេង ដោយសារនាពេលសព្វថ្ងៃនេះ ប្រជាពលរដ្ឋចំនួនច្រើនជាងពាក់កណ្តាល ជាមនុស្សមានអាយុតិចជាង ២១ ឆ្នាំ (CIA, 2009)។ ទោះជាយ៉ាងណាក៏ដោយ បើទោះជាមានការលំបាកនៅក្នុងការវិនិយោគដំបូង លើសេវាកម្មសុខភាព ការអប់រំ និងហេដ្ឋារចនាសម្ព័ន្ធក៏ដោយ រដ្ឋាភិបាលក៏ទទួលស្គាល់ថា ការវិនិយោគនានាលើមូលធនមនុស្ស គឺជាលក្ខខណ្ឌដើមដំបូងមួយ ក្នុងចំណោមលក្ខខណ្ឌសំខាន់ៗ ដើម្បីធ្វើឱ្យមានកំណើនសេដ្ឋកិច្ចដោយចីរភាព និងទាមទារឱ្យមានការវិនិយោគលើផ្នែកនេះ ទន្ទឹមនឹងការវិនិយោគលើវិស័យនានាផ្សេងទៀត នៃសេដ្ឋកិច្ច។ ការបណ្តុះបណ្តាលអំពីការងារដែលទ្រទ្រង់ដល់ការអភិវឌ្ឍបៃតង និងសមរម្យ អាចកែលម្អការចិញ្ចឹមជីវិតរបស់ប្រជាជន ហើយវិភាគទានជាវិជ្ជមានទៅក្នុងការស្តារ ឬ ការថែរក្សាបរិស្ថាន អាចត្រូវបានចាត់ទុកថាជាឱកាសមួយ ដើម្បីពង្រឹង គោលការណ៍បៃតងនៃសេដ្ឋកិច្ចកម្ពុជា និងដើម្បីកែលម្អមូលធនមនុស្សទាំងមូលនៅកម្ពុជា។

## ៣.២ ស្ថានភាពក្រីក្រ

ភាពក្រីក្រ ត្រូវបានធ្វើអត្តសញ្ញាណថាជា ការប្រឈមធំបំផុតសម្រាប់សង្គមកម្ពុជា។ ក្នុងចំណោមប្រជាជនចំនួន ១៣.០៤ លាននាក់ នៅក្នុងឆ្នាំ ២០០៤ ចំនួនប្រជាជនសរុបដែលរស់នៅក្រោមខ្សែបន្ទាត់នៃភាពក្រីក្រខាងស្បៀងអាហារគឺ ២.៦ លាននាក់ ហើយ ចំនួនប្រជាជនដែលរស់នៅក្រោមខ្សែបន្ទាត់នៃភាពក្រីក្រសរុបគឺ ៤.៧ លាននាក់ (MoP, 2008)។ ក្នុងបរិបទនៃភាពក្រីក្រច្រើនបែបនេះ បានដាក់សម្ពាធកាន់តែធ្ងន់ធ្ងរទៅលើធនធានធម្មជាតិ ដែលជាការប្រឈមយ៉ាងធំក្នុងការបញ្ជ្រាបគោលគំនិត អំពីការអភិវឌ្ឍបៃតង ទៅក្នុងផែនការអភិវឌ្ឍន៍ជាតិ។ មុននឹងប្រជាពលរដ្ឋអាចគិតអំពីបរិស្ថាន ជាបឋម ពួកគេត្រូវគិតគូរអំពី ការចិញ្ចឹមជីវិត។ ទោះជាយ៉ាងណាក៏ដោយ រដ្ឋាភិបាលមានតួនាទីស្នូលក្នុងការសម្របសម្រួលអន្តរាគមន៍នានា ដែលអាចដោះស្រាយទាំងភាពក្រីក្រ និងបរិស្ថាន ក្នុងពេលជាមួយគ្នា។ ប្រការនេះបង្ហាញពីសារៈសំខាន់នៃការអភិវឌ្ឍជនបទ អាស្រ័យហេតុនេះវាបង្កប់អត្ថន័យដែលថា គម្រោងនានា នៅក្នុងផែនទីបង្ហាញផ្លូវនេះ ត្រូវតែពង្រឹងការអភិវឌ្ឍជនបទ ដើម្បីកាត់បន្ថយភាពក្រីក្រដែលកើតមានក្នុងប្រទេសកម្ពុជា។

## ៣.៣ ក្របខ័ណ្ឌច្បាប់ និងគោលនយោបាយ

កម្ពុជា មានបទប្បញ្ញត្តិក្នុងកម្រិតកំណត់ និងបានបណ្ដុះបណ្ដាលបុគ្គលិកនានា អំពីការតាមដានប្រកបដោយប្រសិទ្ធិភាពនូវការអនុវត្តសកម្មភាពអភិវឌ្ឍន៍ដោយចីរភាព។ ច្បាប់ និងបទប្បញ្ញត្តិជាច្រើនត្រូវបានរៀបចំឡើង ប៉ុន្តែពុំទាន់មានច្បាប់ ឬគោលនយោបាយជាក់លាក់ស្ដីពីការអភិវឌ្ឍបៃតងនៅឡើយ ហើយការផ្សព្វផ្សាយអំពីច្បាប់ទាំងនេះដល់ប្រជាជន នៅតែមានកម្រិតកំណត់នៅឡើយ។ អាស្រ័យហេតុនេះ គេត្រូវតែពិនិត្យឡើងវិញ និងកែលម្អច្បាប់ដែលមានស្រាប់ និងដែលទាក់ទងនឹងការអភិវឌ្ឍដោយចីរភាព ដើម្បីសម្រេចបាននូវវិធាននៃការអភិវឌ្ឍបៃតង។ លើសពីនេះ ការយល់ដឹងអំពីឧបករណ៍គោលនយោបាយអភិវឌ្ឍន៍បៃតងក្នុងចំណោមអ្នកពាក់ព័ន្ធនានា ក៏នៅមានកម្រិតកំណត់។ ទោះជាយ៉ាងណាក៏ដោយ ក្រសួងបរិស្ថានមាននាទីទទួលខុសត្រូវ"ស្នូល" ដែលត្រូវអនុវត្ត ជាផ្នែកមួយនៃអាណត្តិរបស់រដ្ឋាភិបាល ដើម្បីបញ្ជ្រាបគោលគំនិតការអភិវឌ្ឍន៍បៃតងទៅក្នុងក្របខ័ណ្ឌច្បាប់ និងគោលនយោបាយ។

## ៣.៤ សម្ពាធមកលើបរិស្ថាន

នៅក្នុងរយៈពេលពីរទសវត្សរ៍ចុងក្រោយនេះ កម្ពុជាបានធ្វើឱ្យមានកំណើនសេដ្ឋកិច្ចយ៉ាងឆាប់រហ័ស ដែលនាំឱ្យមានការកាត់បន្ថយយ៉ាងច្រើននូវភាពក្រីក្រ។ ទោះជាយ៉ាងណាក៏ដោយ បញ្ហាវិបត្តិសេដ្ឋកិច្ចនៅពេលថ្មីៗនេះ រួមជាមួយបញ្ហានៃការផ្គត់ផ្គង់ស្បៀង និងបញ្ហាប្រេងឥន្ធនៈនៅទូទាំងតំបន់ ព្រមទាំងបញ្ហានៃការប្រែប្រួលអាកាសធាតុ បានបង្ហាញថា ភាគច្រើននៃកំណើនបញ្ហាទាំងនេះ បានកើតឡើង ទន្ទឹមនឹងការចំណាយដ៏ធំធេងនៃបរិស្ថាន។ ការបាត់បង់ព្រៃឈើដោយសារបទល្មើសព្រៃឈើ និងការទន្ទ្រានដីព្រៃខុសច្បាប់ ជាការគំរាមកំហែងធ្ងន់ធ្ងរមួយមកលើបរិស្ថាន នៃប្រទេសកម្ពុជា។ ព្រៃឈើនៅកម្ពុជាបានថយចុះពី ៧៣% នៅឆ្នាំ ១៩៦៥ មកត្រឹមតិចជាង ៥0% នៅក្នុងបណ្ដាឆ្នាំកន្លងទៅថ្មីៗនេះ (CDRI, 2008)។ គួរកត់សំគាល់ថា ការបាត់បង់ព្រៃឈើបែបនេះបានជះឥទ្ធិពលអវិជ្ជមានជាច្រើន រួមមាន ផលប៉ះពាល់មកលើជីវៈចម្រុះ ការស្តុកទឹកទុក និងកំណើនការហូរច្រោះដីនៅក្នុងតំបន់ ដែលបាត់បង់ព្រៃឈើ។ ការបាត់បង់ព្រៃឈើ មិនត្រឹមតែនាំឱ្យមានការបាត់បង់ទីជម្រកសម្រាប់សត្វ និង រុក្ខជាតិជាច្រើនប្រភេទប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងធ្វើឱ្យបាត់បង់កាបូន ដែលរួមចំណែកដោយប្រយោលធ្វើឱ្យមានកំណើនការបញ្ចេញ $CO_2$ ផងដែរ (CDRI, 2008)។[2]

សម្ពាធមួយផ្សេងទៀតខាងបរិស្ថាន គឺការចោលសំណល់រឹង ដែលជាបញ្ហាចំបងមួយខាងបរិស្ថាន ជាពិសេស នៅក្នុងខេត្តនានា (M. Sidet, 2008)។ ទោះជាយ៉ាងណាក៏ដោយ ក្រសួងបរិស្ថានបានផ្ទេរសមត្ថកិច្ចទៅមន្ទីរបរិស្ថានខេត្ត ដើម្បីគ្រប់គ្រងសំណល់នៅក្នុងខេត្តរបស់ខ្លួន។ ម្យ៉ាងទៀត ក្រសួងបរិស្ថាន បានចេញគោលការណ៍ណែនាំរួមមួយ អំពីការចោល ការប្រមូល ការដឹកជញ្ជូន ការរក្សាទុក ការកែច្នៃឡើងវិញ ការកាត់បន្ថយ និងការទុកដាក់សំណល់ពីលំនៅស្ថាន នៅតាមខេត្តនានា។

---

[2] ទោះជាយ៉ាងណាក៏ដោយ រដ្ឋាភិបាលបានធ្វើការប្តេជ្ញាមោះមុត ក្នុងការរក្សាគម្របព្រៃឈើឱ្យបានត្រឹម ៦0% នៃគម្របព្រៃឈើសរុប រហូតដល់ឆ្នាំ ២០១៥។

អាជ្ញាធរក្រុងភ្នំពេញ ត្រូវបានដាក់ឱ្យអនុវត្តយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាក់ស្តែងមួយ សម្រាប់គ្រប់គ្រងសំណល់ ដោយចាត់ទុកថា វិស័យទឹក ដី និងខ្យល់ គឺជាកង្វល់ចំបង។ អាជ្ញាធរក្រុង បានជម្រុញឱ្យមានការផ្គត់ផ្គង់ទឹកស្អាត កសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត (ដូចជា ប្រព័ន្ធលូទឹកសំអុយ និងប្រព័ន្ធដោះទឹក) កសាងប្រព័ន្ធទប់ស្កាត់ទឹកជំនន់ ប្តូរទីលានចោលសំណល់ដែលមានស្រាប់ទៅទីតាំងថ្មី និងធំជាងមុន ព្រមទាំងមានមធ្យោបាយប្រសើរជាងមុន ជម្រុញការដឹកជញ្ជូនសាធារណៈ និងកែលម្អស្តង់ដារចិញ្ចើមថ្នល់នៅក្នុង ទីក្រុង។

ការបញ្ចេញសំណល់រាវទៅក្នុងប្រព័ន្ធទន្លេ ជាពិសេស នៅក្នុងខេត្តនានា ដែលស្ថិតនៅតាមដងទន្លេមេគង្គ និងបឹងទន្លេសាប និងដៃធំៗនៃទន្លេនេះ គឺជាកង្វល់មួយផ្សេងទៀត (M. Sidet, 2008)។ ប្រទេសកម្ពុជា នៅពុំទាន់មានផែនការសមស្រប សម្រាប់គ្រប់គ្រង ការប្រមូល ការស្តុកទុក ការធ្វើប្រព្រឹត្តកម្ម និងការបញ្ចេញចោលសំណល់រាវឡើយ។ ការទន្ទ្រានយកដី ការបាត់បង់ព្រៃឈើ និងការប្រើប្រាស់ធនធានធម្មជាតិនៅក្នុងតំបន់ការពារធម្មជាតិសម្រាប់គោលបំណងសេដ្ឋកិច្ចបានកើនឡើង ដែលនាំឱ្យមានកង្វល់ខាងបរិស្ថាន (M. Sidet, 2008)។

## ៣.៥ ឱកាសនានា

តាមរយៈការពិគ្រោះយោបល់ជាមួយតំណាងក្រសួង ស្ថាប័ននានានៃរដ្ឋាភិបាល នៅក្នុងកិច្ចប្រជុំក្រុមការងារបច្ចេកទេសអន្តរក្រសួងស្តីពីការអភិវឌ្ឍបៃតង អ្នកពាក់ព័ន្ធនានាបានឯកភាពថា ការបង្កើតលក្ខខណ្ឌអំណោយផល មានសារៈសំខាន់ណាស់សម្រាប់ការវិនិយោគបៃតង ដើម្បីជម្រុញសេដ្ឋកិច្ចក្នុងស្រុក និងពង្រឹងកំណើនការងារថ្មីៗ ដែលស្របតាមគោលការណ៍អភិវឌ្ឍន៍បៃតង។ រាជរដ្ឋាភិបាលគួរតែ ជម្រុញសហគ្រាសឯកជនឱ្យចូលរួមយ៉ាងសកម្មនៅក្នុងការធ្វើឱ្យការអភិវឌ្ឍវិស័យឯកជន ស្របជាមួយគោលការណ៍អភិវឌ្ឍន៍បៃតង។ សកម្មភាពអភិវឌ្ឍន៍បៃតង គួរត្រូវបានលើកទឹកចិត្តនៅក្នុងវិស័យនេះ តាមរយៈ ១) បង្កើនការយល់ដឹង ២) ការអភិវឌ្ឍសមត្ថភាពក្នុង វិស័យនានា ដើម្បីបង្កើនប្រសិទ្ធិភាពអេកូឡូស៊ីនៃការផលិត និងការប្រើប្រាស់ (គួរតែពាក់ព័ន្ធជាមួយស្ថាប័ន ក្រសួង អង្គការមិនមែន រដ្ឋាភិបាល និងគ្រឹះស្ថានអប់រំនានា ដើម្បីបញ្ជ្រាបគោលគំនិតអំពីការអភិវឌ្ឍបៃតង) ៣) ការបញ្ចូលការអភិវឌ្ឍបៃតងទៅក្នុងផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ និង ៤) បង្កើនការអនុវត្តឧបករណ៍គោលនយោបាយអភិវឌ្ឍន៍បៃតង ដើម្បីបង្កើតការលើកទឹកចិត្តខាងហិរញ្ញវត្ថុ និងធ្វើឱ្យវិស័យឯកជនអភិវឌ្ឍន៍ស្របតាមគោលការណ៍អភិវឌ្ឍន៍បៃតង។

បញ្ហាបរិស្ថាន និងសង្គម គឺជាបញ្ហាអន្តរវិស័យ អាស្រ័យហេតុនេះ គួរមានកិច្ចសហប្រតិបត្តិការជាមួយវិស័យនានា។ ប្រសិនបើក្រសួងនានាធ្វើការជិតស្និទ្ធជាមួយគ្នា រាជរដ្ឋាភិបាលមានឱកាសដើម្បីដោះស្រាយកង្វល់ខាងបរិស្ថាន និងការអភិវឌ្ឍនៅក្នុងវិស័យទាំងអស់។ ក្នុងន័យនេះ ក្រុមការងារបច្ចេកទេសអន្តរក្រសួងស្តីពីការអភិវឌ្ឍបៃតង បានលើកស្នើឱ្យមានគម្រោងមួយចំនួន ដែលការអនុវត្តគម្រោងទាំងនេះអាចធ្វើឡើងបានអាស្រ័យលើវត្តមានមូលនិធិ និងការគាំទ្រពីម្ចាស់ជំនួយ។ ក្រោយមានការអនុម័តលើផែនទីបង្ហាញផ្លូវនេះ ក្រសួង ស្ថាប័ននានាត្រូវកសាងផែនការការងារ ដើម្បីបង្ហាញពីការប្តេជ្ញាមោះមុតចំពោះការអភិវឌ្ឍបៃតង។ ដូចដែលគូសបញ្ជាក់ខាងលើ ការបង្កើនការយល់ដឹងមាន សារៈសំខាន់ណាស់ ក្នុងការលើកកំពស់សកម្មភាពអភិវឌ្ឍន៍បៃតង នៅកម្ពុជា។ ក្រសួងធម្មការ និងកិច្ចការសាសនា អាចជួយបញ្ជ្រាបចំណេះដឹងអំពីបរិស្ថាន តាមរយៈការជម្រុញការអភិវឌ្ឍបៃតង

សម្រាប់ជាជម្រើសគុណភាព ដើម្បីទប់ស្កាត់ការប្រើប្រាស់ខ្ជះខ្ជាយ។ ក្រសួងនេះ អាចដាក់បញ្ចូលគោលគំនិតអំពីការអភិវឌ្ឍបៃតង សម្រាប់ការអភិវឌ្ឍដោយចីរភាពទូលំទូលាយ ជាមួយក្រមសីលធម៌ និងស្មារតីរបស់ខ្មែរ ដែលមានពីមុនមក។

លើសពីនេះ ការបង្កើតគម្រោង និងការពិភាក្សាតាមបែបផែននៃការចូលរួម ជាមួយអ្នកពាក់ព័ន្ធនានានៅថ្នាក់មូលដ្ឋាន គឺជាប្រការចាំបាច់ដើម្បីធ្វើឱ្យគម្រោងមាននិរន្តរភាព និងបញ្ចូលគោលគំនិតអំពីការអភិវឌ្ឍបៃតង នៅថ្នាក់ស្រុក។ ការចូលរួមរបស់ក្រសួងមហាផ្ទៃ នឹងផ្ដល់ជាលក្ខខណ្ឌអំណោយផលសម្រាប់ការអនុវត្តដោយជោគជ័យនូវការអភិវឌ្ឍបៃតងនៅថ្នាក់មូលដ្ឋាន ដោយសារក្រសួងនេះកំពុងអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ។ ក្រសួងនានា អាចជួយក្រសួងមហាផ្ទៃ តាមរយៈការបង្កើតក្រុមការងារនៅក្នុងក្រសួងរៀងៗខ្លួន ដោយមានសមាសភាពមកពីនាយកដ្ឋាននានាក្នុងក្រសួងសាម៉ី ហើយជួបធ្វើការជាមួយក្រុមការងារនៃក្រសួងផ្សេងទៀត ដើម្បីបង្កើនភាពខ្លាំង និងកិច្ចសហប្រតិបត្តិការសម្រាប់ការអភិវឌ្ឍបៃតង ដោយក្រសួងបរិស្ថាននៅតែដើរតួក្នុងការសម្របសម្រួល។ លើសពីនេះ អ្នកពាក់ព័ន្ធដទៃទៀតនៅក្នុងប្រទេស (អង្គការមិនមែនរដ្ឋាភិបាល គ្រឹះស្ថានអប់រំ និងវិស័យឯកជន) គួរតែចូលរួមនៅក្នុងគម្រោងនានា ដូចមានចែងនៅក្នុងផែនទីបង្ហាញផ្លូវនេះ។

### ៣.៦ កត្តាជម្រុញឱ្យមានការអភិវឌ្ឍបៃតង

ការចំណាយសាធារណៈ គឺជាកត្តាជម្រុញដំបូងនៃកំណើនសេដ្ឋកិច្ច។ ដូច្នេះ ការថយចុះនៃសេដ្ឋកិច្ចក្នុងពេលសព្វថ្ងៃនេះ មិនគួរត្រូវបានចាត់ថាជាឥទ្ធិពលអវិជ្ជមានឡើយ ព្រោះថា កំណើនការចំណាយរបស់រដ្ឋាភិបាលលើហេដ្ឋារចនាសម្ព័ន្ធ និងការបង្កើតការងារ ពិតជាមានសារៈសំខាន់។ តម្រូវការឱ្យបង្កើនការចំណាយសាធារណៈ តំណាងឱ្យឱកាសដ៏ធំមួយ ដោយសារនៅក្នុងការចាត់ចែងចំណាយសាធារណៈ រាជរដ្ឋាភិបាលអាចធ្វើអត្តសញ្ញាណវិស័យសមស្រប សម្រាប់ការវិនិយោគបៃតង និងធានាឱ្យមានការប្រើប្រាស់មូលនិធិនានាសម្រាប់ការអភិវឌ្ឍដោយចីរភាពបរិស្ថាន ដែលមានសក្ដានុពលសម្រាប់បង្កើតការងារ។ គោលនយោបាយវិមជ្ឈការ និងសហវិមជ្ឈការរបស់រដ្ឋាភិបាលកម្ពុជា ជាកត្តាចំបងមួយសម្រាប់អនុវត្តការអភិវឌ្ឍបៃតងនៅថ្នាក់មូលដ្ឋាន តាមរយៈវិធានការសមស្របនានា ដែលអាចជម្រុញឱ្យមានការអភិវឌ្ឍកសិកម្មសមស្របនៅតាមទីជនបទ។

## ៤. មាគ៌ាទៅរកការអភិវឌ្ឍសេដ្ឋកិច្ចបៃតងជាតិ

មានភស្តុតាងច្បាស់លាស់ ដែលបង្ហាញថា កម្ពុជាបានបន្តសេដ្ឋកិច្ចរបស់ខ្លួន សម្រាប់កាត់បន្ថយភាពក្រីក្រ និងដើម្បីសម្រេចបាននូវការរីកចម្រើនខាងសង្គម។ កំណើនការអភិវឌ្ឍសេដ្ឋកិច្ច ក៏ពិតជានឹងរួមចំណែកធ្វើឱ្យមានការឡើងនូវភាពរេចរឹលបរិស្ថាន ការប្រែប្រួលអាកាសធាតុ និងការបាត់បង់ធនធានធម្មជាតិផងដែរ។ ក្នុងន័យនេះ ដើម្បីអនុវត្តវិធានអភិវឌ្ឍន៍បៃតងប្រការសំខាន់គឺ ត្រូវធ្វើការកែប្រែរបៀបនៃការអភិវឌ្ឍតាមភាពធម្មតា "ការអភិវឌ្ឍជាមុន សម្អាតជាក្រោយ" មករកភាពទទួលខុសត្រូវខ្ពស់សម្រាប់រយៈពេលវែង។ ផែនទីបង្ហាញផ្លូវសម្រាប់អភិវឌ្ឍបៃតងជាតិនេះ បានកំណត់កិច្ចការចំនួនប្រាំពីរសំខាន់ៗ ដូចមានអធិប្បាយនៅក្នុងផ្នែកគោលបំណង ដើម្បីឈានទៅរកការអភិវឌ្ឍដោយចីរភាព និងបន្សាំបានទៅនឹងការប្រែប្រួលអាកាសធាតុ

ដោយការឆ្លុះបញ្ចាំងកិច្ចការទាំង៧ នោះ ត្រូវបានធ្វើអត្តសញ្ញាណក្នុងអន្តរាគមន៍ចំបង៧ចំនួនបីៈ អន្តរាគមន៍រយៈពេលខ្លី (២-៥ឆ្នាំ) អន្តរាគមន៍រយៈពេលមធ្យម(៥-១០ឆ្នាំ) និង អន្តរាគមន៍រយៈពេលវែង(១០-២០ឆ្នាំ)។

## ៤.១ អន្តរាគមន៍សម្រាប់រយៈពេលខ្លី (២-៥ឆ្នាំ)

នៅក្នុងរយៈពេលខ្លី(២-៥ឆ្នាំ) ក្រុមការងារបច្ចេកទេសអន្តរក្រសួងស្តីពីការអភិវឌ្ឍបៃតងបានធ្វើអត្តសញ្ញាណ ទស្សនៈ និងសកម្មភាពមួយចំនួន ដែលត្រូវអនុវត្តឱ្យមានប្រសិទ្ធិភាព ដើម្បីឈានទៅអនុវត្តសកម្មភាពអភិវឌ្ឍន៍បៃតង នៅក្នុងរយៈពេលមធ្យម និងរយៈពេលវែងឱ្យបានជោគជ័យ ដោយអន្តរាគមន៍ដូចខាងក្រោមនេះ ត្រូវបានចាត់ទុកជាអាទិភាព :

ក. បង្កើតក្រុមប្រឹក្សាជាតិ ឬគណៈកម្មាធិការជាតិអភិវឌ្ឍន៍បៃតងថ្នាក់រដ្ឋមន្ត្រី

ខ. បង្កើតការយល់ដឹងជាសាធារណៈ និងដំណើរការពិគ្រោះយោបល់របស់ជាតិ ក្នុងចំណោមសកម្មភាពដទៃទៀត ដោយផ្សព្វផ្សាយសម្ភារៈអប់រំ និងផ្ទាំងព័ត៌មានស្តីពី "កន្លែងធ្វើការបៃតង" និង "លំនៅស្ថានបៃតង" ។

គ. ដាក់បញ្ចូលកិច្ចផ្តួចផ្តើមភូមិបៃតង/ទីក្រុងបៃតង ទៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ

ឃ. កសាងយុទ្ធសាស្ត្រជាតិសម្រាប់ឧស្សាហកម្មបៃតង ដោយផ្អែកលើប្រសិទ្ធិភាពនៃធនធាន និងយុទ្ធសាស្ត្រ 3R

ង. បង្កើតវិធានការដើម្បីជម្រុញកសិកម្មឱ្យមាននិរន្តរភាព ដែលរួមទាំង ប្រព័ន្ធធានារ៉ាប់រងដែលផ្អែកលើសន្ទស្សន៍ និង/ឬ មីក្រូហិរញ្ញប្បទាន ដើម្បីបង្កើនភាពធន់នៅក្នុងសហគមន៍ជនបទ

ច. បង្កើតប្រព័ន្ធដើម្បីជម្រុញការវិនិយោគ ដែលអាចនឹងបន្តអនុវត្តនៅក្នុងរយៈពេលមធ្យម និង រយៈពេលវែង រួមមានៈ

១. ការបង់ថ្លៃសម្រាប់សេវាកម្មប្រព័ន្ធអេកូឡូស៊ី

២. ពន្ធបៃតង និងកំណែទម្រង់ថវិកា និង

៣. ប្រព័ន្ធទូទាត់បំណុលជាមួយវិនិយោគិនអន្តរជាតិ និង

ឆ. បង្កើតវិធានការនានា ដើម្បីពង្រឹងវិស័យឧស្សាហកម្មបរិស្ថានជាតិ។

## ៤.២ អន្តរាគមន៍សម្រាប់រយៈពេលមធ្យម (៥-១០ ឆ្នាំ)

*នៅក្នុងដំណាក់កាលនេះ មានគម្រោងជាអាទិភាពធំៗចំនួនប្រាំដែលបានលើកស្នើឡើង ដែលគម្រោងទាំងនេះនឹងអាចបន្តអនុវត្តនៅក្នុងអន្តរាគមន៍សម្រាប់រយៈពេលវែង។*

### ១) ការអភិវឌ្ឍភូមិបៃតង

ភូមិបៃតង គឺជាសហគមន៍នៅទីក្រុង ឬទីជនបទ ដែលពុះពារដើម្បីដាក់បញ្ចូលលក្ខខ័ណ្ឌអំណោយផលបរិស្ថានសង្គមជាមួយនឹងរបៀបរស់នៅមួយ ដែលមានផលប៉ះពាល់កម្រិតទាបបំផុត។ ដើម្បីសម្រេចបែបនេះបាន គេគួរបញ្ចូលទិដ្ឋភាពនៃគំរូ

សមស្របនានា ខាងអេកូឡូស៊ី ការដាំដំណាំរួមផ្សំ អាគារសាងសង់តាមគោលការណ៍អេកូឡូស៊ី ផលិតកម្មបៃតង ប្រភពថាមពលជំនួស (ដែលបំលែងពីទឹក ខ្យល់ ពន្លឺព្រះអាទិត្យ ឬ ហ្គាសពីសំណល់សត្វ) ការកែប្រែនិងពង្រឹងទម្លាប់ការអនុវត្តន៍សហគមន៍ និងលក្ខខណ្ឌនានាដទៃទៀត។ ការអនុវត្តសកម្មភាពភូមិបៃតង អាចកាត់បន្ថយបានច្រើននូវសម្ពាធមកលើបរិស្ថាន ដែលចាំបាច់ទាមទារឱ្យមានកិច្ចសហប្រតិបត្តិការរវាងក្រសួង និងស្ថាប័ននានា រួមមានៈ ក្រសួងបរិស្ថាន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល សភាពាណិជ្ជកម្មកម្ពុជា ក្រសួងរៀបចំដែនដី នគរូប នីយកម្ម និងសំណង់ ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងមហាផ្ទៃ ក្រសួងកិច្ចការនារី ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងធម្មការ និងកិច្ចការសាសនា ក្រសួងសុខាភិបាល ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងទេសចរណ៍ ។ល។ ក្នុងបរិបទខាងលើនេះ ក្រសួងបរិស្ថានដើរតួនាទីស្នូលក្នុងការជម្រុញការអប់រំបរិស្ថានដល់សហគមន៍មូលដ្ឋាន ដើម្បីពង្រឹងសមត្ថភាពឆ្ពោះទៅរកការគ្រប់គ្រងបរិស្ថានប្រកបដោយនិរន្តរភាព និងបង្កើនការយល់ដឹងអំពីផលប៉ះពាល់នៃសំណល់គ្រោះថ្នាក់ផ្សេងទៀតមកលើសុខភាពប្រជាជន។ដើម្បីអនុវត្តកិច្ចការនេះឱ្យបានជោគជ័យដែលជាប្រយោជន៍អ្នកពាក់ពន្ធ័នានា ក្រសួងទាំងឡាយជាដៃគូគួរតែចូលរួមគាំទ្រការអនុវត្តន៍គោលគំនិតភូមិបៃតងនេះ។

ក្រសួងបរិស្ថាន គួរពិចារណាអំពីការផ្តល់ប្រព័ន្ធទង់បៃតងក្នុងក្របខណ្ឌការអនុវត្តន៍ភូមិបៃតង ដើម្បីទាក់ទាញការប្តេជ្ញារបស់សហគមន៍មូលដ្ឋាន ក្នុងការចូលរួមកិច្ចការពារបរិស្ថាន តាមរយៈសកម្មភាពគ្រប់គ្រងសំណល់ អនាម័យដែលស្របតាមគោលការណ៍បរិស្ថាន ការប្រើប្រាស់ធនធានធម្មជាតិ ដែលមានប្រសិទ្ធិភាពខ្ពស់ខាងអេកូឡូស៊ី។ល។ ដែលការអនុវត្តន៍នេះ រួមចំណែកកែលម្អវិសាលភាព នៃសកម្មភាពសេដ្ឋកិច្ច ដែលមាននិរន្តរភាពខាងបរិស្ថាន។

បន្ថែមលើប្រព័ន្ធផ្តល់ទង់បៃតង ក្រសួងបរិស្ថានគួរបន្តពង្រឹង និងអនុវត្តផែនការយុទ្ធសាស្ត្រគ្រប់គ្រងតំបន់ឆ្នេរ ដើម្បីធានាថាតំបន់ទេសចរណ៍មិនរងការខូចខាត និងនៅតែផ្តល់ភាពទាក់ទាញភ្ញៀវទេសចរ។ ក្រសួងក៏ត្រូវតែបន្តធ្វើការតាមដានលើការអនុវត្តរាល់គម្រោងហេដ្ឋារចនាសម្ព័ន្ធសាធារណៈផងដែរ ដើម្បីធានាថា ការអនុវត្តគម្រោងទាំងនោះសមស្របតាមគោលការណ៍បរិស្ថាន។ លើសពីនេះ ក្រសួងបរិស្ថាន គួរតែបន្តលើកកំពស់ការចូលរួមនៅក្នុងកិច្ចការពារ និងគ្រប់គ្រងធនធានធម្មជាតិ ដើម្បីអាចឱ្យប្រជាជនបានទទួលព័ត៌មាន និងអាចចូលរួមនៅក្នុងដំណើរការធ្វើសេចក្តីសម្រេច ដែលទាក់ទងនឹងបរិស្ថានរស់នៅរបស់ពួកគេ។

អាជ្ញាធរក្រុងភ្នំពេញ និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ផ្សេងៗទៀតចាំបាច់ត្រូវបន្តអនុវត្ត និងពង្រឹងជាបន្ថែមនូវយុទ្ធសាស្ត្រអភិវឌ្ឍន៍របស់ខ្លួន ដើម្បីជម្រុញការផ្គត់ផ្គង់ ទឹកស្អាត កសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត (ដូចជា ប្រព័ន្ធលូទឹកសំអុយ និងប្រព័ន្ធ ដោះទឹក) បង្កើតប្រព័ន្ធទប់ស្កាត់ទឹកជំនន់ និងកែលម្អទីលានចោលសម្រាម ដោយបំពាក់បរិក្ខារប្រសើរជាងមុន សម្រាប់ការញែក សំណល់បានប្រសើរជាងមុនផងដែរ។ លើសពីនេះ អាជ្ញាធរក្រុងគួរបន្តពង្រឹងការអនុវត្តឱ្យបានហ្មឹងម៉ាត់នូវចរាចរក្នុងក្រុង ជម្រុញ ការដឹកជញ្ជូនសាធារណៈ និងកែលម្អចិញ្ចើមផ្លូវសម្រាប់អ្នកថ្មើរជើង។ អាជ្ញាធរក្រុង-ខេត្តក្រុងផ្សេងទៀត គួរបន្តជម្រុញការដាំដើមឈើ និងកែលម្អកន្លែងលំហែកាយ ដើម្បីបង្កើតទីកន្លែងបៃតងសម្រាប់ការសម្រាក និងសកម្មភាពកំសាន្ត។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គួរបន្តចូលរួម និងសហការអនុវត្តគម្រោងភូមិបៃតង ដោយបន្តលើកទឹកចិត្តការដាំដើមឈើនៅតាមដងផ្លូវ និងវិថីនានានៅក្នុងភូមិ ទីធ្លាវត្តអារ៉ាម និងសាលារៀន និងទីសាធារណៈនានា។ ប្រជាពលរដ្ឋនៅជនបទ ក៏ត្រូវរួមចំណែកយ៉ាងច្រើនក្នុងការស្តារ

កែលម្អបរិស្ថាន និងបង្កើតការងារបៃតងសម្រាប់បង្កើតទេសភាព និងសួនកំសាន្ត ដែលជាផ្នែកមួយនៃការអនុវត្តភូមិបៃតង។ ពាក់ព័ន្ធនឹងការប្រើប្រាស់ជី និងថ្នាំកសិកម្ម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គួរបន្តជម្រុញបន្ថែមឱ្យកសិករប្រើប្រាស់ជីធម្មជាតិ និង ជម្រើសក្រៅពីថ្នាំគីមី ដើម្បីពួកគេអាចចាប់ផ្តើមបង្កើតផលិតផលសរីរាង្គ និងអាចធានាឱ្យមានការប្រើប្រាស់ដីដោយនិរន្តរភាព។ ជាជំនួស រដ្ឋាភិបាល អាចយកពន្ធលើការប្រើប្រាស់ធនធាន ដើម្បីបង្កើតឱ្យមានប្រព័ន្ធធានារ៉ាប់រងនៅកម្រិតមីក្រូ ដោយផ្អែកលើសន្ទស្សន៍ ដែលផ្តល់ឱ្យកសិករនូវជម្រើសសម្រាប់គ្រប់គ្រងហានិភ័យនៃធាតុអាកាស។ ប្រព័ន្ធទាំងនេះអាចបង្កើតឡើង ដែលផ្តល់ការអនុគ្រោះដល់កសិកម្មសរីរាង្គ ដើម្បីបង្កើតការលើកទឹកចិត្តនានា ដើម្បីឱ្យមានកំណើនជំនួញបៃតងនៅក្នុងវិស័យនេះ និងពង្រឹងសន្តិសុខស្បៀង ដែលមាននិរន្តរភាពខាងបរិស្ថាន។

ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល គួរតែបន្តអនុវត្តគោលនយោបាយ ដែលមានស្រាប់របស់ខ្លួន ដើម្បីជម្រុញ និងគាំទ្រសហគ្រាសខ្នាតតូច និងមធ្យម ដើម្បីធ្វើការពង្រីក និងបង្កើនល្បឿននៃការអនុវត្តកម្មវិធី "ភូមិមួយ ផលិតផលមួយ" ការធានាឱ្យមានការកែលម្អជាបន្ត នូវផលិតផលនៅមូលដ្ឋាន/ក្នុងស្រុក ការជួយសហគ្រាសខ្នាតតូច និងមធ្យម ក្នុងការកែលម្អផលិតភាពរបស់ពួកគេ និងកាត់បន្ថយថ្លៃចំណាយលើការផលិត លើកកំពស់ជំនាញវិជ្ជាជីវៈ និងការបណ្តុះបណ្តាល ការគាំទ្រដល់ឧស្សាហកម្មដែលទើបបង្កើតថ្មីនៅក្នុងដំណាក់កាលចាប់ផ្តើមរបស់ខ្លួន ការជម្រុញចំណងទាក់ទងរវាងសហគ្រាសខ្នាតតូច និងមធ្យម និងសហគ្រាសខ្នាតធំក្នុងការប្រើប្រាស់ចង្វាក់ផ្គត់ផ្គង់នៅក្នុងទីផ្សារធំ ការពង្រឹងយន្តការ ដើម្បីការពារកម្មសិទ្ធិបញ្ញានៅក្នុងឧស្សាហកម្ម ការកាត់បន្ថយនីតិវិធីចុះបញ្ជី និងដំណើរការចាប់ផ្តើមនៃក្រុមហ៊ុន និងការដាក់ឱ្យសហគ្រាសខ្នាតតូច និងមធ្យម អនុវត្ត និងការសាកល្បងផលិតកម្មស្អាត។ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល គួរតែបន្តធ្វើការបណ្តុះបណ្តាល និងបង្កើនការយល់ដឹងដើម្បី បង្កើនផលិតភាព និង កែលម្អគុណភាពនៃផលិតកម្ម ដើម្បីកែលម្អភាពប្រកួតប្រជែងនៅក្នុងស្រុក និងលើឆាកអន្តរជាតិ ព្រមទាំងបន្តជម្រុញផលិតផលស្អាត និងការគ្រប់គ្រងសារធាតុគីមីដោយប្រុងប្រយ័ត្ន។ ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ និងក្រសួងឧស្សាហកម្មរ៉ែ និងថាមពល គួរបន្តសហការជាមួយសភាពាណិជ្ជកម្មកម្ពុជា ដើម្បីបង្កើតឱ្យមានផលិតផលសមស្របសម្រាប់ផ្គត់ផ្គង់នៅក្នុងទីផ្សារ។ ហេតុដូចនេះ សភាពាណិជ្ជកម្មកម្ពុជា គួរតែបន្តដើរតួជាតំណាងសហគមន៍ពាណិជ្ជកម្ម ឧស្សាហកម្ម កសិកម្ម សិប្បកម្ម និង សេវាកម្ម ដើម្បីជម្រុញឱ្យមានការសម្របសម្រួលជាមួយអាជ្ញាធរជាតិ និងជម្រុញការអភិវឌ្ឍវិស័យឯកជន ឱ្យបានសមស្របតាមគោលការណ៍បរិស្ថាន។ លើសពីនេះ គួរតែបង្កើនការជម្រុញឱ្យប្រើប្រាស់ឡជីវៈឧស្ម័ន និងថាមពលកកើតឡើងវិញនៅតាមជនបទ ដែលអាចផ្តល់ប្រយោជន៍ទាំងអគ្គិសនី និងជីសរីរាង្គ សម្រាប់កសិកម្ម។

ការគ្រប់គ្រងដីធ្លី ក៏មានតួនាទីស្នូលនៅក្នុងភូមិបៃតង ដើម្បីធានានូវនិរន្តភាពបរិស្ថាន និងការគ្រប់គ្រងដីធ្លីដោយនិរន្តភាព។ កម្មសិទ្ធិដីនៅទីជនបទ អាចផ្តល់ផលដល់ការអភិវឌ្ឍជនបទ តាមរយៈការបង្កើតគោលការណ៍ណែនាំសម្រាប់ការប្រើប្រាស់ដី បង្កើនកម្មសិទ្ធិ និងសន្តិសុខ ព្រមទាំងបង្កើនតម្លាភាពនៃទីផ្សារដីធ្លី។ រដ្ឋាភិបាលអាចជម្រុញគោលគំនិតអំពីទីក្រុងបៃតង និង/ឬ ភូមិបៃតង ដើម្បីបង្កើតប្រភពចម្រុះនៃប្រាក់ចំណូល ដែលអាចបង្កើនចលករ ដែលបង្កើតឡើងតាមរយៈកម្មសិទ្ធិដី។ កិច្ចប្រឹងប្រែងនេះគួរអនុវត្តរួមគ្នាដោយ ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ក្រសួងបរិស្ថាន ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ ដើម្បីពង្រឹងកិច្ចការពារបរិស្ថាន និងកែលម្អការសម្របសម្រួល

និងកិច្ចសហប្រតិបត្តិការជាបន្ថែមរវាងក្រសួងនានា គេគួរតែពិចារណាលើការអនុវត្តអនុក្រឹត្យ និង គោលនយោបាយខ្លះៗឱ្យមានប្រសិទ្ធិភាព : ១) អនុក្រឹត្យស្តីពីនីតិវិធីសម្រាប់កសាងផែនការប្រើប្រាស់ដី ដែលបានអនុម័ត នៅក្នុងឆ្នាំ ២០០៩ ក្នុងបំណងធ្វើអត្តសញ្ញាណគោលការណ៍ យន្តការ និងនីតិវិធីនានា សម្រាប់កសាងផែនការប្រើប្រាស់ដីសម្ហភាព ២) អនុក្រឹត្យស្តីពីនីតិវិធីចុះបញ្ជីដីសហគមន៍ជនជាតិដើម ឆ្នាំ២០០៩; ៣) គោលនយោបាយស្តីពី ការចុះបញ្ជី និងសិទ្ធិប្រើប្រាស់ដីសហគមន៍ជនជាតិដើម ឆ្នាំ ២០០៩ និង ៤) សេចក្តីថ្លែងការណ៍របស់ រាជរដ្ឋាភិបាលស្តីពីគោលនយោ បាយដីធ្លី។ កំណែទម្រង់ដីធ្លីមានតួនាទីស្នូល ក្នុងការបង្កើនផលិតកម្មកសិកម្ម និងសន្តិសុខស្បៀង នៅក្នុងប្រទេស។ កំណែទម្រង់នេះ បានផ្តោតលើផ្នែកនានា ដែលទាក់ទងនឹងសន្តិសុខលើកម្មសិទ្ធិដីធ្លីជាពិសេសស ក្នុងចំណោម ដីកសិកម្ម និងក្រុមជនភាគតិច ដែលងាយរងគ្រោះ (CBNRM, 2009)។ លើសពីនេះ ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ដើរតួយ៉ាងសំខាន់នៅក្នុងការកសាងផែនការសម្រាប់ការអភិវឌ្ឍដីធ្លី ជាពិសេស ក្នុងការកសាងផែនការអភិវឌ្ឍន៍ភូមិបៃតង ដើម្បីបញ្ចៀសផលប៉ះពាល់អវិជ្ជមានទាំងអស់ ដែលបង្កដោយសកម្មភាព ដែលទាក់ទងនឹងការអភិវឌ្ឍដីធ្លី។

ដើម្បីពង្រឹងការអនុវត្តភូមិបៃតង ក្រសួងអភិវឌ្ឍន៍ជនបទ ត្រូវបន្តអភិវឌ្ឍន៍វិស័យផ្គត់ផ្គង់ទឹក និងអនាម័យនៅជនបទជាបន្ថែមទៀត ដើម្បីផ្តល់ទឹកដែលស្របជាមួយស្តង់ដារសមស្របសម្រាប់ការប្រើប្រាស់តាមគ្រួសារ ទៅដល់ប្រជាពលរដ្ឋទាំងអស់នៅជនបទ។ ក្រសួងក៏ត្រូវតែធ្វើអត្តសញ្ញាណវិធីនានា ដើម្បីគ្រប់គ្រងសំណល់ពីមនុស្សប្រកបដោយសុវត្ថិភាពផងដែរ ដើម្បីកាត់បន្ថយការចម្លងជម្ងឺដែលទាក់ទងនឹងការប្រើប្រាស់ទឹក។ ម្យ៉ាងទៀត ក្រសួងអប់រំ យុវជន និងកីឡា ក៏ជាអ្នកដើរតួយ៉ាងសំខាន់ សម្រាប់ការគ្រប់គ្រងប្រព័ន្ធអេកូឡូស៊ីរបស់ប្រទេស និងកាត់បន្ថយការរេចរឹលបរិស្ថាន។ ក្រសួងនេះអាចពាក់ព័ន្ធនឹងការជម្រុញ និងការផ្តល់បច្ចេកវិទ្យាសមស្របតាមគោលការណ៍បរិស្ថាន និងកែលម្អលទ្ធភាពទទួលបានទឹកស្អាត និងបរិក្ខារអនាម័យគ្រប់គ្រាន់ ទាំងនៅជនបទ និងទីក្រុង។ ម៉្យាងវិញទៀត ដើម្បីធានាឱ្យមានការផ្សព្វផ្សាយបានទូលំទូលាយ ការរួមបញ្ចូលគោល គំនិតអំពីភូមិបៃតងទៅក្នុងគោលនយោបាយ និងកម្មវិធីអប់រំ ជាប្រការសំខាន់ណាស់។ គេអាចបញ្ជ្រាបគោលគំនិតអំពីភូមិបៃតង ទៅដល់សិស្ស និស្សិតទាំងអស់ចាប់ពីថ្នាក់បឋមសិក្សា ដល់សកលវិទ្យាល័យ។ តាមរយៈផ្នែកជាក់ស្តែងចំនួនពីរ ដែលមានស្រាប់ : ផ្នែកការងារ ការអប់រំ និងបណ្តុះបណ្តាលបច្ចេកទេស-វិជ្ជាជីវៈ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ គួរតែបន្តធ្វើឱ្យប្រាកដថា សមត្ថភាព និងជំនាញបៃតងអាចកសាងបានក្នុងចំណោមប្រជាពលរដ្ឋនៅជនបទ។ទន្ទឹមនឹងនេះ អាជ្ញាធរនៅថ្នាក់ខេត្ត អាចអនុវត្តពន្ធ ដែលមានស្រាប់ (ពន្ធបៃតង) និងអាចប្រើប្រាស់ផលចំណូល ដើម្បីជួយទ្រទ្រង់ដល់ ការអប់រំ និងបណ្តុះបណ្តាល បច្ចេកទេស វិជ្ជាជីវៈ លើជំនាញបៃតង ដូចជាការធ្វើកសិកម្មឱ្យមាននិរន្តរភាព ឬ ផ្តល់ប្រាក់កំចីដែលគាំទ្រដោយរដ្ឋាភិបាល ដើម្បីអាចទទួលបានបច្ចេកវិទ្យាសមស្របខាងបរិស្ថានដល់ពលរដ្ឋនៅជនបទ។

តាំងពីមុនមក កម្ពុជាគឺជាប្រទេសមួយដែលកាន់ព្រះពុទ្ធសាសនា ដោយមានពុទ្ធសាសនិកជនច្រើនជាង ៨០% នៃចំនួនប្រជាជនសរុប។ អាស្រ័យហេតុនេះ ការបញ្ចូលគោលគំនិតអំពីភូមិបៃតង ទៅក្នុងចំណោមប្រជាជនអាចទទួលប្រយោជន៍ពីការចូលរួមរបស់ក្រសួងធម្មការ និងកិច្ចការសាសនា។ ក្រសួងនេះអាចជម្រុញបដិវត្តបៃតង សម្រាប់ជាជម្រើសជំនួសនៅក្នុងយុទ្ធសាស្រ្តកំណើនសេដ្ឋកិច្ចដែលពឹងផ្អែកខ្លាំងក្លាលើធនធាន។ ក្រសួងនេះអាចបន្សុីគ្នារវាងគោលគំនិតស្តីពីបដិវត្តបៃតង នៅក្នុងការអភិវឌ្ឍដោយចីរភាព ជាមួយក្រមសីលធម៌ និងស្មារតី ដែលមានស្រាប់របស់ប្រជាជនខ្មែរ តាមរយៈព្រះធម៌។

ក្នុងស្ថានភាពជាក់ស្តែង ក្រសួងទេសចរណ៍ (២០០៨) បានរាយការណ៍ថា វិស័យទេសចរណ៍ បានក្លាយជាកម្លាំងជម្រុញចំបងមួយនៃកំណើនសេដ្ឋកិច្ច ដោយមានភ្ញៀវទេសចរចំនួន ២,១២៥,៤៦៥ នាក់ ដែលបានមកទស្សនាកម្ពុជានៅឆ្នាំ ២០០៨ ហើយគេរំពឹងថាតួលេខនេះនឹងកើនឡើងនៅក្នុងរយៈពេលប៉ុន្មានឆ្នាំខាងមុខនេះ។ ដើម្បីធានាឱ្យមានកំណើនចំនួនភ្ញៀវទេសចរក្រសួងទេសចរណ៍ គួរបន្តអនុវត្តចំណាត់ថ្នាក់រមណីយដ្ឋាន និងទីតាំងទេសចរណ៍ កន្លែងស្នាក់នៅតាមគោលការណ៍អេកូឡូស៊ី និងគួរតែបង្កើនបន្ថែមទៀត នូវហេដ្ឋារចនាសម្ព័ន្ធតូចៗដទៃទៀតនៅទីជនបទ ដែលបានធ្វើឡើងដោយក្រសួងទេសចរណ៍ក្រោមកិច្ចសហប្រតិបត្តិការ ជាមួយធនាគារ-អភិវឌ្ឍន៍អាស៊ី។ គម្រោងអភិវឌ្ឍន៍ទេសចរណ៍ទន្លេមេគង្គ ទទួលបន្ទុកចាត់ចែងកិច្ចការនេះ ក្នុងបំណងជួយគម្រោងសហគមន៍អេកូ-ទេសចរណ៍ នៅក្នុងបណ្តាខេត្តភាគឦសាននៃប្រទេស។ អាស្រ័យហេតុនេះ ធនាគារអភិវឌ្ឍន៍អាស៊ី អាចពិចារណា ពង្រីកគម្រោងនេះ។

ភូមិបៃតងអាចក្លាយជាកន្លែងទាក់ទាញខាងទេសចរណ៍ ដោយសារភាគច្រើននៃអ្វីដែលភ្ញៀវទេសចរចង់បាន គឺបរិស្ថាន ស្អាត។ ដូច្នេះ តំបន់ទេសចរណ៍នានា ត្រូវតែគ្រប់គ្រង ក្នុងបំណងធ្វើឱ្យមាននិរន្តរភាពបរិស្ថាន និងការប្រើប្រាស់ពាក្យស្លោកដូចជា "ទីក្រុង ស្អាត រមណីដ្ឋានស្អាត និងសេវាល្អ និងភូមិបៃតង " អាចមានប្រយោជន៍ សម្រាប់ថែរក្សា និងជម្រុញទម្លាប់ល្អនៅក្នុងតំបន់ទេសចរណ៍។ កំណើនចំនួនភ្ញៀវទេសចរ ក៏តំណាងឱ្យឱកាសយ៉ាងសំខាន់ផងដែរ ដើម្បីពង្រីកចំនួនការងារធ្វើ និងកំណែលម្អលក្ខខណ្ឌ នៃការចិញ្ចឹមជីវិតរបស់សហគមន៍មូលដ្ឋាន។

## ២) និរន្តរភាពនៃធនធានទឹក

លទ្ធភាពទទួលបានទឹក ដើរតួយ៉ាងសំខាន់នៅក្នុងការកាត់បន្ថយភាពក្រីក្រ ការបង្កើតជម្រើសនានាសម្រាប់ពិពិធកម្មសេដ្ឋកិច្ច ការពង្រឹងសន្តិសុខស្បៀង និងការអភិរក្សបរិស្ថាន។ និយាយម្យ៉ាងទៀតថា ទឹក គឺជាធនធានដែលមានសារៈសំខាន់ជាមូលដ្ឋានសម្រាប់ការអភិវឌ្ឍដោយចីរភាពនៅក្នុងវិស័យមួយចំនួន ដែលរួមទាំងកសិកម្ម ឧស្សាហកម្ម ថាមពល ការប្រើប្រាស់ក្នុង គ្រួសារ នាវាចរណ៍ ទេសចរណ៍ ជលផល និងមានសារៈសំខាន់ណាស់សម្រាប់ការថែរក្សាប្រព័ន្ធអេកូឡូស៊ី។ ដូច្នេះការថែរក្សាធនធាន ដ៏មានសារៈសំខាន់នេះ ទាមទារឱ្យមានកិច្ចសហការ និងសហប្រតិបត្តិការ ក្នុងចំណោមក្រសួងធនធានទឹក និងឧតុនិយម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្រសួងបរិស្ថាន ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងកិច្ចការនារី ក្រសួងមហាផ្ទៃ ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងទេចរណ៍ ព្រមទាំងស្ថាប័នពាក់ព័ន្ធទាំងអស់។

ក្នុងខណៈដែលប្រជាពលរដ្ឋប្រមាណ ៩០%មានទឹកប្រើប្រាស់ ប្រទេសកម្ពុជាមនៅមានបច្ចេកវិទ្យាកម្រិតទាប និងពុំទាន់គ្រប់គ្រាន់សម្រាប់ធ្វើប្រព្រឹត្តកម្មសំអាតទឹកនៅឡើយ ហើយការប្រើប្រាស់ទឹកក៏នៅពុំទាន់មាននិរន្តរភាពនៅឡើយដែរ។ លើសពីនេះ លទ្ធភាពពុំទាន់គ្រប់គ្រាន់ក្នុងការទទួលបានអនាម័យសមស្រប និងទឹក ដែលពុំទាន់មានគុណភាពគ្រប់គ្រាន់ បានបង្កើតឧប្បត្តិហេតុនៃប្រភពជម្ងឺ ដែលកើតឡើងពីទឹក និងចម្លងតាមទឹក។

ក្រសួងធនធានទឹកនិងឧតុនិយម ត្រូវបានគេចាត់ទុកថាជាទីភ្នាក់ងារបឋមមួយ ដែលធ្វើការដោះស្រាយបញ្ហាដែលទាក់ទងនឹងទឹក។ ដូច្នេះ ស្ថាប័ននេះគួរតែបន្តគោលនយោបាយដែលមានស្រាប់របស់ខ្លួន ស្ដីពីមុខនាទីចំបងៗរបស់ទឹកសម្រាប់ កសិកម្ម ថាមពល ឧស្សាហកម្ម សហគ្រាសផលិតកម្ម និងសេវាកម្មខ្នាតតូច ការប្រើប្រាស់ប្រចាំគ្រួសារ និងទេសចរណ៍។ គោលនយោបាយនេះមិនត្រឹមតែចែងទាក់ទងនឹងទឹកសាបនោះទេ ប៉ុន្តែក៏ចែងអំពីទឹកក្នុងតំបន់ឆ្នេរ និងទឹកសមុទ្រ ព្រមទាំងអំពីកិច្ចការពារ និងអភិរក្សទឹកសមុទ្រ។ ក្រសួងធនធានទឹក និងឧតុនិយម គួរបន្តបង្កើនការយល់ដឹងក្នុងចំណោមប្រជាជន ទាំងអំពីតំបន់ឆ្នេរ និងតំបន់ទឹកសាប ដើម្បីបង្កើនការយល់ដឹងក្នុងចំណោមប្រជាជន ទាក់ទងនឹងតួនាទីដ៏សំខាន់នៃទឹក សម្រាប់ការរស់នៅប្រចាំថ្ងៃ និងការអភិវឌ្ឍ សេដ្ឋកិច្ចសង្គម និងជម្រុញការចូលរួមរបស់សាធារណជនសម្រាប់ការថែរក្សា គ្រប់គ្រង អភិរក្ស និងការប្រើប្រាស់ធនធានទឹកឱ្យមានប្រសិទ្ធិ - ភាព និងដោយនិរន្តរភាព។ ការថែរក្សាហេដ្ឋារចនាសម្ព័ន្ធទឹក អាចបង្កើតការងារធ្វើ ដែលបង្កើនប្រាក់ចំណូល សម្រាប់ជនក្រីក្រ។ ទាក់ទងនឹងក្របខ័ណ្ឌច្បាប់ គេចាំបាច់ត្រូវអនុវត្តឱ្យមានប្រសិទ្ធិភាពនូវអនុក្រឹត្យមួយចំនួន ដែលទាក់ទងនឹងទឹក ដែលរួមទាំងការប្រើប្រាស់ទឹកពីសំណាក់កសិករ ការគ្រប់គ្រងអាងទន្លេ ការចេញអាជ្ញាប័ណ្ណទាក់ទងនឹងទឹក និង គុណភាពទឹក។ ដូច្នេះគេក៏ចាំបាច់ត្រូវពង្រឹងការអនុវត្តច្បាប់ស្ដីពីការគ្រប់គ្រងទឹក និងគោលនយោបាយ សម្រាប់ការស្រោចស្រពដោយនិរន្តរភាព ដែលអាចផ្ដោតកាន់តែច្រើនឡើងមកលើការគ្រប់គ្រងទឹកជាទូទៅ សម្រាប់ការស្រោចស្រព។ លើសពីនេះ រដ្ឋាភិបាល អាចដោះស្រាយបញ្ហាប្រើប្រាស់ទឹកតាមរយៈការអនុវត្តអត្រាពន្ធអនុគ្រោះនិងអត្រាពន្ធកំណើន ដើម្បីលើកទឹកចិត្ត សម្រាប់វិស័យឧស្សាហកម្ម ដើម្បីកែលម្អប្រសិទ្ធិភាពនៃការប្រើប្រាស់ទឹក។ តាមរយៈការអនុវត្តអត្រាថ្លៃទឹក ដោយវាស់បរិមាណទឹកប្រើប្រាស់ រដ្ឋាភិបាលអាចលៃទឹកប្រាក់មួយផ្នែកសម្រាប់ប្រើប្រាស់ ដើម្បីពង្រីកសេវាកម្មទឹកសម្រាប់គ្រួសារនានាផ្សេងទៀត ដែលនៅពុំទាន់បានទទួលសេវានៅឡើយ។ និយាយម៉្យាងទៀតថា គេចាំបាច់ត្រូវបន្តកែលម្អ និងពង្រឹងស្តង់ដារជាតិសម្រាប់ទឹកផឹក និងភាពចាំបាច់ ដើម្បីបញ្ចូលបច្ចេកវិទ្យាប្រើប្រាស់ទឹកទៅក្នុងការបង្កើតបទដ្ឋាន សម្រាប់ពង្រឹងសក្ដានុពលសម្រាប់ប្រមូលផលទឹក ឱ្យបានពេញលេញ។ អន្តរាគមន៍បែបនេះ នឹងជួយពង្រឹងភាពធន់របស់ប្រជាពលរដ្ឋទៅនឹងគ្រោះធម្មជាតិបណ្ដាលពីទឹក។

បើនិយាយពីព្រៃឈើ ធនធានទឹកមិនអាចមាននិរន្តរភាពបានទេ លើកលែងតែព្រៃឈើត្រូវបានការពារឱ្យមានប្រសិទ្ធិ ភាព និងច្រាសមកវិញ។ ធនធានព្រៃឈើដើរតួយ៉ាងសំខាន់សម្រាប់ការថែរក្សាវដ្តជលសាស្ត្រ។ ដូច្នេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គួរតែបន្តជម្រុញការគ្រប់គ្រងព្រៃឈើឱ្យមានប្រសិទ្ធិភាព ទាំងនៅក្នុងព្រៃសម្បទាន និងព្រៃសហគមន៍។ ទោះជាយ៉ាងណាក៏ដោយ ក្រសួងមានផែនការរួចមកហើយដែលសង្កត់ធ្ងន់លើយុត្តិធម៌ និងនិរន្តរភាពបរិស្ថាន ដើម្បីកាត់បន្ថយឥទ្ធិពលនៃគ្រោះមហន្តរាយ ពោលគឺ ទឹកជំនន់ ភាពរាំងស្ងួត មកលើការចិញ្ចឹមជីវិត និងទ្រព្យសម្បត្តិសាធារណៈ។ រដ្ឋាភិបាល គួរបន្តលើកទឹកចិត្តឱ្យមានកិច្ចសហប្រតិបត្តិការរវាងក្រសួងធនធានទឹក និងឧតុនិយម និង ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីធានាឱ្យមានការគ្រប់គ្រងធនធានទឹកដោយប្រសិទ្ធិភាពដើម្បីគាំទ្រសហគមន៍មូលដ្ឋានក្នុងការប្រើប្រាស់ទឹក ទាំងសម្រាប់ការប្រើប្រាស់នៅក្នុងគ្រួសារ និងសម្រាប់ការស្រោចស្រពដំណាំកសិកម្ម។ ការគ្រប់គ្រងធនធានទឹក គឺជាការទទួលខុសត្រូវអន្តរក្រសួង។ ជាក់ស្តែង ក្រសួងអភិវឌ្ឍន៍ជនបទ ត្រូវបានចាត់ទុកថាជាអ្នកដើរតួមួយយ៉ាងសំខាន់ក្នុងការគ្រប់គ្រងធនធានទឹក។ ក្រសួងនេះបានកសាងគោលនយោបាយស្ដីពីជនជាតិដើម បង្កើតគោលនយោបាយ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍ជនបទ។ ដូច្នេះ ក្រសួង អភិវឌ្ឍន៍ជនបទបានបន្ត

អនុវត្តគោលនយោបាយរបស់ខ្លួន ស្តីពីការផ្គត់ផ្គង់ទឹកនៅជនបទប្រកបដោយនិរន្តរភាព ដើម្បីបញ្ចៀស ឥទ្ធិពលអវិជ្ជមានមកលើសុខភាព និងបរិស្ថាន។ អាទិភាពស្នូលមួយទៀត គឺត្រូវយកចិត្តទុកដាក់ចំពោះការផ្គត់ផ្គង់ទឹកស្អាត សម្រាប់ពលរដ្ឋគ្រប់រូប។ ប្រការចុងក្រោយនេះនឹងធានាថា បុគ្គលម្នាក់ៗអាចទទួលបានទឹកស្អាត និងសេវាកម្មអនាម័យ។ ទោះជាយ៉ាងណាក៏ដោយ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល បានបង្កើតគោលនយោបាយជាតិស្តីពីការផ្គត់ផ្គង់ទឹក និង អនាម័យ ដើម្បីឆ្លើយតបទៅនឹងអាទិភាពនានា នៅក្នុងយុទ្ធសាស្ត្រចតុកោណ។ គោលនយោបាយនេះត្រូវបានកសាងឡើង ដើម្បីកែលម្អការចិញ្ចឹមជីវិត និងសុខុមាលភាពរបស់ប្រជាពលរដ្ឋ ដោយធានាឱ្យមានការផ្គត់ផ្គង់ទឹក និងសេវាកម្មអនាម័យបានគ្រប់គ្រាន់ តាមតម្លៃទាប ដោយគិតគូរអំពីប្រព័ន្ធអនាម័យដែលមាននិរន្តរភាព និងដែលស្របតាមគោលការណ៍បរិស្ថាន។ គោលនយោបាយនេះ អាចទទួលផលពីការលើកទឹកចិត្តឱ្យមានភាពជាដៃគូរវាងសាធារណៈ-ឯកជន និងគួរតែផ្តល់សេវាកម្មទឹកដោយតម្លៃទាប ដល់អ្នកក្រ ដើម្បីកែលម្អស្ថានភាពរបស់ពួកគេ។

ស្របជាមួយគ្នានេះ ក្រសួងអប់រំ យុវជន និងកីឡា បាន និងកំពុងអនុវត្តគោលនយោបាយសាលាកុមារមេត្រី ដោយផ្តោតលើការធ្វើអត្តសញ្ញាណសុខភាព សុវត្ថិភាព និងកិច្ចការពារកុមារ។ គោលនយោបាយនេះមានគោលដៅធានាថា កុមារទាំងអស់បានទទួលការគាំពារ និងការគាំទ្រ ពីសំណាក់ប្រជាពលរដ្ឋ និងស្ថាប័ននានា។ អាស្រ័យហេតុនេះ ក្រសួងនេះគួបន្តដាក់ឱ្យប្រើប្រាស់ និងអនុវត្តបន្ថែមនូវការប្រើប្រាស់ទឹក និងបរិស្ថានស្អាត នៅក្នុងគោលនយោបាយសាលាកុមារមេត្រី។ ជាក់ស្តែង លក្ខខណ្ឌមិនគ្រប់គ្រាន់ និងទឹកមិនស្អាត អាចបង្កហេតុប៉ះពាល់អវិជ្ជមានយ៉ាងច្រើន ដែលប្រការនេះក៏មានឥទ្ធិពលមកលើវិស័យទេសចរណ៍ផងដែរ។ ការទទួលបានទឹកស្អាត មានសារៈសំខាន់ណាស់សម្រាប់ការអភិវឌ្ឍវិស័យទេសចរណ៍។ ជាទូទៅ ទឹកដែលមានគុណភាពទាប មាន ឥទ្ធិពលមកលើសុខភាពរបស់អ្នកទេសចរ និងអ្នកប្រើប្រាស់។ ដូច្នេះ គេត្រូវពង្រឹងការត្រួតពិនិត្យគុណភាពទឹកជាបន្ថែមទៀត នៅក្នុងតំបន់ទេសចរណ៍ និងកែលម្អការគ្រប់គ្រងសំណល់ ដើម្បីថែរក្សាគុណភាពទឹកឱ្យបានល្អ។ អាស្រ័យហេតុនេះ ក្រសួងទេសចរណ៍ គួរតែសហការជាប់ជាប្រចាំជាមួយក្រសួងធនធានទឹក និងឧតុនិយម ដើម្បីត្រួតពិនិត្យ និងគ្រប់គ្រងគុណភាពទឹក។

## ៣) និរន្តរភាពនៃវិស័យថាមពល កសិកម្ម និងព្រៃឈើ

កសិកម្មដែលមាននិរន្តរភាព អាចមានប្រសិទ្ធិភាពក្នុងការជួយកែលម្អសន្តិសុខស្បៀង និងកាត់បន្ថយភាពក្រីក្រ។ កសិកម្មជម្រុញការផលិតស្បៀង ដែលអាចមានផលប៉ះពាល់តិចតួចបំផុតមកលើបរិស្ថាន។ កសិកម្មដែលមាននិរន្តរភាពផ្តល់ឱកាសដើម្បី សម្រេចការអភិវឌ្ឍសេដ្ឋកិច្ច អាចបង្កើតការងារធ្វើ ដើម្បីកាត់បន្ថយភាពក្រីក្រ និងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់។ ការប្រើប្រាស់ថ្នាំគីមីកសិកម្មតិចតួច ឬមិនប្រើប្រាស់ថ្នាំគីមីកសិកម្ម អាចជួយធានាសុវត្ថិភាពស្បៀងសម្រាប់អ្នកប្រើប្រាស់ និងផ្តល់សន្តិសុខស្បៀងសម្រាប់កសិករដែលមានចំណែកដីតូចៗ។ សម្រាប់រយៈពេលវែង កសិកម្មដែលមាននិរន្តរភាពអាចផ្តល់ ឱកាសខាងពាណិជ្ជកម្ម សម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ និងស្តារប្រព័ន្ធអេកូឡូស៊ី ដែលមានភាពរេចរឹល។

រាជរដ្ឋាភិបាលកម្ពុជា បានចាត់ទុកការអភិរក្ស និងគ្រប់គ្រងធនធានព្រៃឈើ ដែលធានាការពារបានសក្តានុពលនៃអេកូឡូស៊ីសង្គម និងសេដ្ឋកិច្ច ថាជាផ្នែកចំបងមួយនៃសុខុមាលភាពសាធារណៈ ដែលរួមចំណែកដោយផ្ទាល់ទៅក្នុងកិច្ចការពារបរិស្ថាន ការ

កាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម (RGC, 2002)។ ដូច្នេះ រាជរដ្ឋាភិបាលកម្ពុជា គួរតែបន្តអនុវត្តការប្តេជ្ញារបស់ខ្លួនដើម្បីអភិរក្ស និងគ្រប់គ្រងធនធានព្រៃឈើនៅក្នុងប្រទេសនេះឱ្យមាននិរន្តរភាព។ វិស័យថាមពល បានកើនឡើងដោយសារតែកំណើនសេដ្ឋកិច្ចយ៉ាងឆាប់រហ័ស។ ក្នុងន័យនេះ កសិកម្ម ព្រៃឈើ និងថាមពល ដែលមាននិរន្តរភាព មានសារៈសំខាន់ជាសារវន្តសម្រាប់ការរស់នៅរបស់កសិករតូចតាច និងជនក្រីក្រផ្សេងទៀតនៅជនបទ ដោយបង្កលក្ខខណ្ឌអំណោយផលដល់ពួកគាត់ក្នុងការបង្កើនផលិតកម្មស្បៀង និងប្រាក់ចំណូល។ កិច្ចសហការ និងសហប្រតិបត្តិការ ក្នុងចំណោមក្រសួងនានា រួមមាន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងធនធានទឹក និងឧតុនិយម ក្រសួងបរិស្ថាន ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងកិច្ចការនារី ក្រសួងមហាផ្ទៃ ក្រសួងសុខាភិបាល ក្រសួងពាណិជ្ជកម្ម ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សភាពាណិជ្ជកម្មនៃកម្ពុជា ក្រសួងទេចរណ៍ មានសារៈសំខាន់ណាស់ ដើម្បីពង្រឹងការ គ្រប់គ្រងធនធានឱ្យមាននិរន្តរភាព។

ដើម្បីជម្រុញនិរន្តរភាពជារួម ខាងកសិកម្ម ធនធានព្រៃឈើ និងធនធានទឹក តំណាងពីស្ថាប័ននានានៃរដ្ឋាភិបាល ក៏បានលើកស្នើឱ្យមានគម្រោងសាកល្បង/បង្ហាញ ដើម្បីជម្រុញការប្រើប្រាស់ឡជីវៈឧស្ម័ន សម្រាប់ការផលិតថាមពល (ការសង្កត់ធ្ងន់ជាពិសេសលើវិស័យនេះ តាមរយៈប្រព័ន្ធផ្តល់ទង់សម្រាប់ភូមិបៃតង/ទីក្រុងបៃតង ដូចដែលមានកត់សំគាល់ពីខាងដើម)។ ការពង្រឹងលើការអនុវត្តច្បាប់ព្រៃឈើដែលមានសព្វថ្ងៃនេះ ដែលគួសបញ្ជាក់អំពីតំបន់ការពារបរិស្ថាន ក៏ដូចជា កំណើនការប្រើប្រាស់បច្ចេកវិទ្យាថាមពលកកើតឡើងវិញ នឹងមានសក្តានុពលក្នុងការកាត់បន្ថយការកាប់ឈើល្មើសច្បាប់។ កត្តាខាងដើម ទាមទារឱ្យមានកំណែទម្រង់គោលនយោបាយ ដែលស្របតាមកាលៈទេសៈរបស់ជាតិ និងជាពិសេសនៅតាមមូលដ្ឋាន ដូចជាការតមេដាន ការវាយតម្លៃនឹងអាចទទួលផលពីការចូលរួមរបស់ក្រសួងមហាផ្ទៃ។ កិច្ចផ្តួចផ្តើមទាំងនេះ ក៏អាចរួមបញ្ចូលជាមួយ ការលើកកំពស់ទម្លាប់អនុវត្ត លើការគ្រប់គ្រងដីឱ្យមាននិរន្តរភាព និងការគ្រប់គ្រងចម្រុះព្រៃឈើផងដែរ ដូចជាការបណ្តុះបណ្តាល អ្នកមានរបរកាប់ឈើ ឱ្យពួកគេធ្វើការជាអ្នកនាំផ្លូវសម្រាប់អេកូទេសចរណ៍។ លើសពីនេះ ការដាក់ឱ្យអនុវត្តយន្តការដេញថ្លៃ ដើម្បីត្រួតពិនិត្យការកាប់ឈើ រួមផ្សំជាមួយយន្តការដែលធានានូវការប្រព្រឹត្តកម្រៃសម្បទាន ឬ ពន្ធបន្ថែម នៅតាមសិប្បកម្មអារឈើ ក៏អាចកាត់បន្ថយសម្ពាធមកលើព្រៃឈើ។ នៅថ្នាក់ជាតិ ការធ្វើសារពើភ័ណ្ឌកាបូននៃព្រៃឈើ អាចជួយធ្វើឱ្យប្រទេសកម្ពុជា មានលក្ខណៈសម្បត្តិសមស្របគ្រប់គ្រាន់ ដើម្បីទទួលឥណទានពីកម្មវិធី"ការកាត់បន្ថយការបញ្ចេញឧស្ម័នពីការបាត់បង់ព្រៃឈើ និងការរេចរឹលព្រៃឈើ" (REDD)។ ការដាក់ឱ្យអនុវត្តគម្រោង" ការដាំដើមឈើ និងការស្តារព្រៃឈើ សម្រាប់យន្តការអភិវឌ្ឍន៍ស្អាត" (A/R CDM) គួរតែត្រូវបាន ពិចារណាផងដែរដើម្បីធានាការពារគម្របព្រៃឈើ។ គម្រោងនេះ អាចជួយកម្ពុជាក្នុងការឈានទៅសម្រេចការប្តេជ្ញារបស់ខ្លួន ដើម្បីរក្សាគម្របព្រៃឈើឱ្យបាន ៦0% រហូតដល់ឆ្នាំ ២០១៥។ លើសពីនេះ គម្រោងនេះមិនត្រឹមតែបង្កើនគម្របព្រៃឈើប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបង្កើនកម្រិតស្រូបកាបូន/សន្និធិកាបូន ដើម្បីកាត់បន្ថយកំណើនកំដៅពិភពលោក និង ក៏អាចកាត់បន្ថយភាពក្រីក្ររបស់សហគមន៍មូលដ្ឋាន តាមរយៈការផ្តល់ឱកាសសម្រាប់ការងារបៃតង។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គួរតែបន្តផែនការអភិវឌ្ឍន៍កសិកម្មរបស់ខ្លួន ដែលមានគោលដៅកាត់បន្ថយភាពក្រីក្រនិងកំណើនសេដ្ឋកិច្ច តាមរយៈការអិវឌ្ឍវិស័យកសិកម្ម ដែលរួមទាំងការគ្រប់គ្រងសារធាតុគីមីដោយសុវត្ថិភាព និង ជម្រើសប្រើប្រាស់សារធាតុក្រៅពីគីមី។ ផែនការវិស័យនេះ មានគោលដៅធានាសន្តិសុខស្បៀង បង្កើនប្រាក់ចំណូល បង្កើតការងារ និងកែលម្អស្ថានភាពអាហារូបត្ថម្ភ សម្រាប់ប្រជាជនទាំងអស់ តាមរយៈកំណែលម្អផលិតភាព ពិពិធកម្ម និងពាណិជ្ជកម្មផលិតផលកសិកម្ម ដែលផលិតឡើងដោយគោរពតាមគោលការណ៍បរិស្ថាន (ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ) ។ លើសពីនេះ ដើម្បីឈានទៅសម្រេចបានកសិកម្មដែលមាននិរន្តរភាព ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គួរតែបន្តពិចារណាអំពីការអភិរក្ស ធនធានទឹក និងដីវិធានការចម្រុះការពារដំណាំ និងការកាត់បន្ថយប្រភពបំពុល ដែលមានលក្ខណៈសាយភាយ។ ទន្ទឹមនឹងនេះ បើគ្មានការចូលរួមពីក្រសួងធនធានទឹក និងឧតុនិយមទេនោះ កម្ពុជាមិនអាចធ្វើឱ្យកសិកម្មមាននិរន្តរភាពបានឡើយ ដោយសារក្រសួង នេះដើរតួយ៉ាងសំខាន់នៅក្នុងការលើកកំពស់ហេដ្ឋារចនាសម្ព័ន្ធស្រោចស្រពដែលមាននិរន្តរភាព ការគ្រប់គ្រងតំបន់ផ្ទៃរងទឹកភ្លៀង ទន្លេ បឹង ស្ទឹង និងធនធានទឹកដទៃទៀតដោយប្រសិទ្ធភាព ដែលផ្តល់ទឹកសម្រាប់ការប្រើប្រាស់នៅក្នុងរដូវប្រាំង។ ការបង្កើត និង កែលម្អការព្យាករណ៍ធាតុអាកាស ក៏អាចកាត់បន្ថយផលប៉ះពាល់អវិជ្ជមាន បណ្តាលពីទឹកជំនន់។ អាស្រ័យហេតុនេះ ក្រសួងធនធានទឹក និងឧតុនិយមគួរតែផ្តល់ឱកាសកាន់តែច្រើនថែមទៀតដល់សហគមន៍ និងអ្នកពាក់ព័ន្ធនានា ដើម្បីចូលរួមនៅក្នុងកិច្ចការពារ អភិរក្ស គ្រប់គ្រង និង/ឬប្រើប្រាស់ធនធានទឹក ដែលឆ្លុះបញ្ចាំងអំពីតម្រូវការពិតប្រាកដ។

បើនិយាយអំពីធនធានព្រៃឈើ ការប្រើប្រាស់អុសជាថាមពលបំរើអាជីវកម្មសិប្បកម្មមានផលប៉ះពាល់ទាំងមកលើបរិស្ថាន និង សុខភាពប្រជាជន។ ហើយការបាត់បង់ព្រៃឈើ ដោយសារការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងការពង្រីកដីកសិកម្ម ក៏បង្កជាសម្ពាធមកលើព្រៃឈើដែលមានសព្វថ្ងៃនេះ។ ការថែរក្សាគម្របព្រៃឈើ មានសារៈសំខាន់ណាស់ សម្រាប់និរន្តរភាពនៃប្រព័ន្ធអេកូឡូស៊ីសម្រាប់ការទប់ស្កាត់សំណឹកដី តំបន់ផ្ទៃរងទឹកភ្លៀង និងជាកន្លែង ស្តុកកាបូន។ ក្រសួងបរិស្ថាន និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គួរតែបន្តពង្រឹងការអនុវត្តច្បាប់ស្តីពីតំបន់ការពារធម្មជាតិ និងច្បាប់ស្តីពីការគ្រប់គ្រងវិស័យព្រៃឈើ ដើម្បីធានាការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព និងលើកកំពស់ជាបន្ថែមនូវការ ចូលរួមជាសាធារណៈក្នុងកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដើម្បីឱ្យប្រជាពលរដ្ឋអាចទទួលបានព័ត៌មាន និងការចូលរួមនៅក្នុងដំណើរការធ្វើសេចក្តីសម្រេចនានា ដែលទាក់ទងនឹងបរិស្ថាន។

នៅក្នុងឆ្នាំ ២០០៧ រាជរដ្ឋាភិបាលកម្ពុជា បានអនុម័តកម្មវិធីជាតិបន្សាំនឹងការប្រែប្រួលអាកាសធាតុ (NAPA)។ កម្មវិធីនេះផ្តល់ជាមូលដ្ឋានសម្រាប់សកម្មភាពបន្សាំនឹងការប្រែប្រួលអាកាសធាតុសម្រាប់រយៈពេលខ្លីនៅក្នុងប្រទេសកម្ពុជា ដូច្នេះ កម្ពុជា ត្រូវបន្តជម្រុញការអនុវត្តកម្មវិធីនេះបន្ថែមទៀត។ នៅពេលដែលក្រសួងបរិស្ថានបានរៀបចំកម្មវិធីជាតិបន្សាំនឹងការ ប្រែប្រួលអាកាសធាតុ លទ្ធផលជាមូលដ្ឋាន ដែលបានរកឃើញសម្រាប់ការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ គឺការថែរក្សាគម្របព្រៃឈើ។ ដូច្នេះ គួរតែអនុវត្ត និងកែសម្រួលកម្មវិធីនេះ យ៉ាងហោចណាស់នៅក្នុងរវាងប្រាំឆ្នាំម្តង ដើម្បីឆ្លុះបញ្ចាំងអំពីអាទិភាពនៃការបន្សាំ និងដើម្បីធ្វើអត្តសញ្ញាណតម្រូវការបន្សាំរបស់ប្រជាជនកម្ពុជា។ លើសពីនេះ គម្រោងនានា ដែលកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ទាំងនៅ

ក្រោមយន្តការអភិវឌ្ឍន៍ស្អាត (CDM) និងទីផ្សារស្ម័គ្រចិត្ត ត្រូវបានអនុវត្តនៅកម្ពុជាដោយបានទទួលជោគជ័យជាបន្តបន្ទាប់ រួចមកហើយ ជាពិសេសនៅក្នុងផ្នែកថាមពលកកើតឡើងវិញ។ គេគួរជម្រុញ និងពង្រីកការអនុវត្តគម្រោងបែបនេះជាបន្ថែមទៀត ទៅកន្លែងថ្មីៗដែលមានសក្តានុពលកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់រួមទាំងក្នុងវិស័យប្រសិទ្ធិភាពថាមពល កសិកម្ម និងព្រៃឈើ។

ប្រទេសកម្ពុជា គួរតែត្រៀមលក្ខណៈ ដើម្បីចូលរួមនៅក្នុងការចរចារបបអាកាសធាតុនៅក្រោយអាណត្តិ នៃពិធីសារក្យូតូ ដូចជា ការកាត់បន្ថយការបញ្ចេញឧស្ម័ន ពីការបាត់បង់ព្រៃឈើ និងការរេចរឹលព្រៃឈើ (REDD) និងសកម្មភាពអភិរក្សព្រៃឈើ ទាំងនៅក្នុងតំបន់ព្រៃឈើដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងតំបន់ការពារធម្មជាតិដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់ក្រសួងបរិស្ថាន។ អាស្រ័យហេតុនេះ យន្តការ REDD និង REDD+ គួរតែបានអនុវត្ត ដោយធ្វើការពិចារណា អំពីការធានាទាំងគុណភាព និងវិសាលភាពព្រៃឈើ។ ប្រការសំខាន់មួយទៀត គឺត្រូវកែលម្អការផ្គត់ផ្គង់ថាមពលអគ្គិសនីនៅជនបទ ដើម្បីបំពេញតម្រូវការថាមពល ដែលកំពុងកើនឡើង សម្រាប់បង្កើនការលូតលាស់នៃអភិវឌ្ឍន៍សេដ្ឋកិច្ច។ គេគួរតែកែប្រែទម្លាប់នៃការអនុវត្តតាមបែបបុរាណនៅក្នុងវិស័យសាធារណៈសម្រាប់ការផលិតអគ្គិសនី ដើម្បីឈានទៅ ១) អនុវត្តប្រកបដោយប្រសិទ្ធិភាព នូវគម្រោងថាមពលអគ្គិសនី ដែលមានសព្វថ្ងៃនៅក្នុងវិស័យសាធារណៈ ២) គាំទ្រឱ្យមានប្រតិបត្តិការវិស័យឯកជន និងភាពជាដៃគូសាធារណៈ-ឯកជន និង ៣) គាំទ្រដល់ការងារផ្នែកវិភាគគោលនយោបាយ និងបច្ចេកទេសខាងផ្នែកថាមពលកកើតឡើងវិញ (ADB, 2007)។ គេអាចអភិវឌ្ឍន៍បច្ចេកវិទ្យាថាមពលកកើតឡើងវិញ ដើម្បីបំពេញតម្រូវការថាមពលនៅតាមទីជនបទ និងតំបន់ដាច់ស្រយាល ជាពិសេស តាមតំបន់ដែលគ្មានបណ្តាញចែកចាយ ដើម្បីបង្កើនស្តង់ដារនៃការរស់នៅរបស់ប្រជាពលរដ្ឋនៅជនបទ។ ការអនុវត្តផែនការយុទ្ធសាស្ត្រថាមពលកកើតឡើងវិញឱ្យបានជាប់ជាប្រចាំ និងប្រកបដោយប្រសិទ្ធិភាព ដោយរួមបញ្ចូលជម្រើសសម្រាប់ថាមពលវារីអគ្គិសនី ថាមពលពន្លឺព្រះអាទិត្យ ជីវៈម៉ាស/ជីវឧស្ម័ន និងថាមពលខ្យល់។ល។ ដើម្បីធានា និងសម្រួលដល់ការផ្គត់ផ្គង់អគ្គិសនីនៅជនបទ រួមផ្សំជាមួយកំណើនកិច្ចការពារព្រៃឈើដែលមានស្រាប់ អាចផ្តល់ឥទ្ធិពលវិជ្ជមានមកលើសុខភាពមនុស្ស និងការកាត់បន្ថយភាពក្រីក្រ។ ក្រសួងពាណិជ្ជកម្ម ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងផែនការ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងក្រសួងអប់រំ យុវជន និងកីឡា គួរជួយ និងសម្រួលឱ្យមានការបញ្ជ្រាបជម្រើសថាមពលកកើតឡើងវិញ ដោយកាត់បន្ថយអត្រាពន្ធលើការនាំចូលមកលើបច្ចេកវិទ្យាដែលមានសុវត្ថិភាពខាងបរិស្ថាន (ESTs)។

នៅក្នុងពេលជាមួយគ្នានេះ ក្រសួងកិច្ចការនារី ក៏ត្រូវបានចាត់ទុកថាជាស្ថាប័នចំបងមួយនៅក្នុងការគ្រប់គ្រងធនធានធម្មជាតិ។ ក្រសួងកិច្ចការនារី គួរបង្កើត និងអនុវត្តគោលនយោបាយ និងរៀបចំគោលការណ៍ណែនាំ យុទ្ធសាស្ត្រ និងផែនការនានា ដើម្បីធានាឱ្យមានតុល្យភាពយេនឌ័រនៅក្នុងការអប់រំ ការបណ្តុះបណ្តាល អាហារូបត្ថម្ភសមស្រប និងសេវាកម្មសុខភាព និង សិទ្ធិប្រើប្រាស់ និងគ្រប់គ្រងធនធានធម្មជាតិ។ លើសពីនេះ សភាពាណិជ្ជកម្មកម្ពុជា គួរបន្តកែលម្អប្រសិទ្ធិភាពសហគ្រាស ដើម្បីជាប្រយោជន៍នៃវិស័យពាណិជ្ជកម្ម ឧស្សាហកម្ម កសិកម្ម សិប្បកម្ម និងសេវាកម្ម និងសេដ្ឋកិច្ចទូទៅ។ ទីបំផុត សហគ្រាសនានា គួរតែរៀបចំ និងផ្សព្វផ្សាយនូវតួលេខស្ថិតិពាណិជ្ជកម្ម និងសេដ្ឋកិច្ច ធ្វើការស្រាវជ្រាវអំពីបញ្ហាពាណិជ្ជកម្ម និងជម្រុញប្រសិទ្ធិភាពនៃផលិតកម្ម និងអេកូទេសចរណ៍។ ភស្តុតាងនានាបង្ហាញថា ការអភិវឌ្ឍកសិកម្ម មានសារៈសំខាន់ជាពិសេស សម្រាប់ភ្ញៀវទេសចរ ដោយសារអ្នកទេសចរជាច្រើនទិញផលិតផលកសិកម្ម។ ជាក់ស្តែង នៅក្នុងឆ្នាំ ២០០៨ ភ្ញៀវទេសចរក្នុងស្រុកប្រមាណ ៦.៧ លាននាក់ និងភ្ញៀវទេសចរបរទេសចំនួន

២.១ លាននាក់ បានទិញផលិតផលកសិកម្ម និង អាហាររបស់ខ្មែរ។ ដើម្បីតភ្ជាប់ផលិតកម្មកសិកម្ម ជាមួយទីផ្សារ គេចាំបាច់ត្រូវតែអភិវឌ្ឍគោលនយោបាយ និងយុទ្ធសាស្ត្រ ដោយ លើកទឹកចិត្តឱ្យម្ចាស់សណ្ឋាគារ និងភោជនីយដ្ឋាន ប្រើប្រាស់ផលិតផល និងស្បៀងអាហារក្នុងស្រុកកាន់តែច្រើនឡើង ដែលរួមទាំងផលិតផលស្បៀងសរីរាង្គ ដោយមានបន្ថែមលក្ខខណ្ឌនៃប្រព័ន្ធចេញវិញ្ញាបនប័ត្រ និងការដាក់ស្លាកសញ្ញា។ ភស្តុតាងនានាបង្ហាញ ថា មានតែសណ្ឋាគារ និងភោជនីយដ្ឋានមួយចំនួនតូចតែប៉ុណ្ណោះ ដែលប្រើប្រាស់ស្បៀងអាហារផលិតផលក្នុងស្រុក។

## ៤) និរន្តរភាពនៃការគ្រប់គ្រងសំណល់

សព្វថ្ងៃនេះ ការប្រឈមធំបំផុតនៅក្នុងការគ្រប់គ្រងសំណល់ រួមមាន : សារធាតុបំពុលពីការបោកគក់នៅតាមរោងចក្រនៅក្នុងវិស័យកាត់ដេរ ការចោលសំណល់ពីស្ថានីយជួសជុលយានយន្ត (ប្រេងរំអិល សារធាតុត្រជាក់) ការចោលសំណល់ពីលំនៅស្ថានដោយសារតែការយល់ដឹងមានកម្រិត សំណល់វេជ្ជសាស្ត្រ (ពោលគឺ ម្ជុល និង សារធាតុគីមី) និងការតាមដានក្នុងកម្រិតកំណត់លើផលិតផលចាស់ៗនៅក្នុងវិស័យយានយន្ត (រថយន្ត កង់រថយន្ត។ល។) និងសំណល់អេឡិចត្រូនិក ដែលនាំចូលមកក្នុងប្រទេស។ ដើម្បីសម្រេចបាននូវការគ្រប់គ្រងសំណល់ខាងលើដោយនិរន្តរភាព ក្រសួងបរិស្ថាន គួរបន្តធ្វើការយ៉ាងជិតស្និទ្ធជាមួយ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្រសួងធានធានទឹក និងឧតុនិយម ក្រសួងសាធារណការ និង ដឹកជញ្ជូន ក្រសួងពាណិជ្ជកម្ម ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងសុខាភិបាល ក្រសួងផែនការ ក្រសួងអប់រំ យុវជន និងកីឡា សាលាក្រុងភ្នំពេញ ក្រសួងកិច្ចការនារី និងក្រសួងទេសចរណ៍។

អន្តរាគមន៍ដែលអាចកែលម្អគុណភាពនៃការគ្រប់គ្រងសំណល់ រួមមាន យុទ្ធនាការបង្កើនការយល់ដឹងដល់សហគមន៍ ការធ្វើអត្តសញ្ញាណ និងការត្រួតពិនិត្យទីលានចោលសម្រាម ការពង្រឹងលើការអនុវត្តច្បាប់ឱ្យបានល្អជាងមុន ការអប់រំយុវជនអំពី សារៈសំខាន់នៃបរិស្ថាន និងការត្រួតពិនិត្យលើការនាំចូលផលិតផលចាស់ៗ និងការជម្រុញអភិបាលកិច្ច និងការដឹកនាំដោយខ្លួនឯងនៅថ្នាក់មូលដ្ឋាន ដើម្បីកែលម្អការសម្របសម្រួលវិមជ្ឈការនូវកិច្ចប្រឹងប្រែងទាំងនេះ។ នៅក្នុងពេលធ្វើអត្តសញ្ញាណទីលានចោលសម្រាមឱ្យបានសមស្រប រដ្ឋាភិបាលកម្ពុជា អាចអនុវត្តលើការកំណត់ថ្លៃសម្រាប់ការប្រមូលសំណល់ពីគេហដ្ឋាន និងពីទីក្រុង ដោយផ្អែកលើបរិមាណសំណល់ ប្រាក់កម្រៃបែបនេះ សំរាប់លើកទឹកចិត្តសដល់ការបង្កើនការកែច្នៃសំណល់ឡើងវិញ។ រដ្ឋាភិបាលគួរពិចារណាដាក់ឱ្យអនុវត្ត និងលើកទឹកចិត្តឱ្យប្រើប្រាស់ធុងសម្រាម សម្រាប់ញែកសំណល់ ដើម្បីបែងចែកឱ្យដាច់គ្នារវាងសំណល់ប្រភេទខុសៗគ្នា ដើម្បីធានាឱ្យមានការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព។ គេក៏ត្រូវកែលម្អ និងពង្រឹងការអនុវត្តអនុក្រឹត្យស្តីពីការគ្រប់គ្រង សំណល់រឹងដែលទាក់ទងនឹងមិនត្រឹមតែជាមួយការគ្រប់គ្រងសំណល់រឹង និង/ឬសម្រាមឱ្យបានត្រឹមត្រូវប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងគ្រប់គ្រងសំណល់ពីមន្ទីរពេទ្យ សំណល់ឧស្សាហកម្ម និងសំណល់ប្រកបដោយគ្រោះថ្នាក់ផ្សេងៗទៀត ឱ្យមានប្រសិទ្ធភាព(ដែលរួមទាំងការដឹកជញ្ជូន ការរក្សាទុក ការយកទៅចោល ការធ្វើប្រព្រឹត្តកម្មសំអាតសំណល់ទាំងនោះ)។ ក្រៅពីយុទ្ធសាស្ត្រគ្រប់គ្រងប្រកបដោយសុវត្ថិភាព រាជរដ្ឋាភិបាលកម្ពុជា គួរពិនិត្យមើលជម្រើសនៃការបម្លែងសំណល់ឱ្យទៅជាថាមពល ដែលរួមទាំងជម្រើសនានា

សម្រាប់ការធ្វើឧស្ម័នកម្មជីវសាស្ត្រ និងការដុតសំណល់។ បើទោះជាត្រូវចោល ឬដុតក៏ដោយ អាជ្ញាធររាជធានីភ្នំពេញ គួរផ្តោតលើកិច្ចប្រឹងប្រែងនានា ដើម្បីកែលម្អការគ្រប់គ្រងសំណល់ ដោយកែលម្អមធ្យោបាយសម្រាប់ដឹកជញ្ជូន និងការទុកដាក់សំណល់ (អាជ្ញាធររាជធានីភ្នំពេញ)។

បន្ថែមលើការពង្រឹងលើការអនុវត្តបទប្បញ្ញត្តិនានា បង្កើនការយល់ដឹង និងជម្រើសលើការត្រួតពិនិត្យ ដើម្បីកែលម្អការគ្រប់គ្រងសំណល់ ការអនុវត្តឧបករណ៍គោលនយោបាយសារពើពន្ធ ដូចជា ពន្ធលើសារធាតុ និងផលិតផលដែលបង្កគ្រោះថ្នាក់មកលើបរិស្ថាន ដូចជា ថង់ប្លាស្ទិក សារធាតុគីមី និងសំណល់ប្រកបដោយគ្រោះថ្នាក់ និងជីអាសូត អាចមានប្រសិទ្ធិភាពក្នុងការកាត់បន្ថយការប្រើប្រាស់ផលិតផលដែលគ្មាននិរន្តរភាពទាំងនេះ ទន្ទឹមនឹងការបង្កើតលក្ខខណ្ឌបរិយាកាសអំណោយផលសម្រាប់ផលិតផល និងសេវាកម្ម ដែលគោរពតាមគោលការណ៍បៃតង។ បញ្ហាទាំងនេះអាចដោះស្រាយបាន តាមរយៈកិច្ចសហប្រតិបត្តិការរវាងក្រសួងបរិស្ថាន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្រសួងផែនការ និងក្រសួងពាណិជ្ជកម្ម។ ទាក់ទងនឹងការគ្រប់គ្រងសំណល់នៅក្នុងព្រៃឈើ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គួរបន្តជម្រុញឱ្យម្ចាស់ក្រុមហ៊ុនព្រៃសម្បទានធ្វើការប្រមូល និងគ្រប់គ្រងសំណល់ពីការប្រមូលផលព្រៃឈើឱ្យមានប្រសិទ្ធិភាព។ ការជម្រុញមុខជំនួញបៃតង និងផលិតផលបៃតង គួរតែបន្តធ្វើឡើងដើម្បីបង្កើនប្រសិទ្ធិភាពធនធាន ហើយនៅក្នុងការផលិតសម្ភារៈនានា គួរតែបង្កើនការទទួលខុសត្រូវ លើអាយុកាលទាំងមូលនៃផលិតផលដែលបានបង្កើតឡើង ព្រមទាំងអាចជៀសវាងការបង្កើតសំណល់តាំងពីដើមដំបូងមក។ ការកែប្រែផលិតផល និងសេវាកម្ម អាចត្រូវការពលកម្មច្រើន ជាងការធ្វើសកម្មភាពតាមបែបធម្មតា ប៉ុន្តែក៏អាចបង្កើនការងារជាបន្ថែម ដូចជា តាមរយៈការជម្រុញឱ្យមានផលិតផលស្អាត ដើម្បីធានាឱ្យមានការអភិវឌ្ឍ ឧស្សាហកម្មដោយចីរភាព ការគ្រប់គ្រងដោយប្រុងប្រយ័ត្ននូវផលិតផលគីមី ដែលទាក់ទងនឹងសារធាតុគីមីបំពុលសរីរាង្គមិនងាយបំបែកធាតុ (POPs) និងបន្ទះសៀគ្វីអេឡិចត្រូនិក (PCBs)។

ការគ្រប់គ្រងជាបន្ថែមនូវសារធាតុគ្រោះថ្នាក់ អាចធ្វើទៅបាន តាមរយៈការកាត់បន្ថយ និងការលុបបំបាត់ជាបណ្តើរៗនូវការនាំចូល និងការប្រើប្រាស់ផលិតផល ដែលផ្សំដោយសារធាតុគីមីបំពុលមិនងាយបែកធាតុ និងបន្ទះសៀគ្វីអេឡិចត្រូនិក។ ក្រៅពីនេះ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល អាចបន្តជម្រុញ និងពង្រឹង សមត្ថភាពគ្រប់គ្រងសំណល់ឧស្សាហកម្មពីរោងចក្រ នានា។ សកម្មភាពចំបងៗ រួមមាន ការគាំទ្រខាងបច្ចេកទេស ដូចជា ការបណ្តុះបណ្តាល ការកែលម្អបច្ចេកវិទ្យា ការរៀបចំគោលការណ៍ណែនាំ ការវាយតម្លៃ និងការគាំទ្រខាងបទប្បញ្ញត្តិ។ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល អាចបន្តដាក់ឱ្យអនុវត្តសាកល្បង និងបង្ហាញអំពីផលិតកម្មស្អាត ដល់សហគ្រាសខ្នាតតូច និងមធ្យម និងជម្រុញគោលនយោបាយនានា សម្រាប់ឧស្សាហកម្មបៃតង ជាមួយនឹងរដ្ឋាភិបាលទាំងមូល។ ទាក់ទងនឹងការគ្រប់គ្រងសំណល់ពីការសាងសង់ផ្លូវ ក្រសួងសាធារណការ និងដឹកជញ្ជូន គួរបន្តបង្កើតផែនការគ្រប់គ្រងសំណល់ តាមរយៈការអនុវត្តកម្មវិធីប្រមូលសំណល់ និងអនុវត្តគោលនយោបាយស្តីពី ការកាត់បន្ថយ និងការបំបាត់ឱ្យអស់នូវការបំពុល ដែលមានប្រភពពីដីគោក បណ្តាលពីសកម្មភាពនានារបស់មនុស្ស។ នៅទីនេះ ក្រសួងអប់រំ យុវជន និងកីឡា អាចដាក់បញ្ចូលជាបន្ថែមទៀតនូវកម្មវិធីបរិស្ថាន ទៅក្នុងកម្មវិធីសិក្សា ដោយចាប់ផ្តើមពីថ្នាក់បឋម សិក្សារហូតដល់សកលវិទ្យាល័យ។ ក្រសួងផ្សេងទៀត ដែលពាក់ព័ន្ធក្នុងការជម្រុញឱ្យមានការគ្រប់គ្រងសំណល់បានត្រឹមត្រូវ ដែលមិនបង្កគ្រោះថ្នាក់ចំពោះបរិស្ថាន គួរចងក្រង

បទពិសោធន៍ល្អៗរបស់ខ្លួន ហើយក្រសួងអប់រំ យុវជន និងកីឡា អាចប្រើប្រាស់បទពិសោធន៍ទាំងនេះ សម្រាប់ជាគម្រោងអនុវត្តបង្ហាញ នៅតាមសាលារៀន និងសាកលវិទ្យាល័យ ។

តំបន់នានាដែលសំបូរដោយជីវៈចម្រុះ និងបរិស្ថាន ដែលមានលក្ខណៈពិសេស អាចមាននាទីជាកម្លាំងទាក់ទាញសម្រាប់កំណើននៅក្នុងវិស័យទេសចរណ៍។ នៅកម្ពុជា វិស័យទេសចរណ៍ អាចក្លាយជាកម្លាំងជម្រុញចំបងមួយនៃកំណើនសេដ្ឋកិច្ច និង បង្កើតការងារធ្វើ ដោយនៅក្នុងឆ្នាំ ២០០៨ មានចំនួនភ្ញៀវទេសចរអន្តរជាតិដល់ចំនួន ២.១២៥.៤៦៥ នាក់ ដូច្នេះគេរំពឹង ថាចំនួនភ្ញៀវទេសចរនឹងកើនឡើងថែមទៀត នៅក្នុងរយៈពេលប៉ុន្មានឆ្នាំខាងមុខនេះ (MoT, 2008)។ សព្វថ្ងៃនេះ ក្រសួងទេសចរណ៍ កំពុងរៀបចំផែនការដើម្បីបង្កើតគម្រោងទេសចរណ៍ក្នុងមហាអនុតំបន់មេគង្គ (គម្រោងចំនួនបួន) និងកម្មវិធី ស្ទូលស្ថីពីបរិស្ថាន (គម្រោងបែបថ្មីចំនួនបួន)។ ទោះជាយ៉ាងណាក៏ដោយ កម្ពុជាអាចត្រូវប្រឈមនឹងការលំបាកយ៉ាងច្រើន ដូចជា កង្វះហេដ្ឋារចនាសម្ព័ន្ធនៅតាមតំបន់ទេសចរណ៍ កង្វះការគ្រប់គ្រងសំណល់ឱ្យបានសមស្រប អនាម័យ និងស្តង់ដារមិនទាន់គ្រប់គ្រាន់ សម្រាប់ផលិតផលវត្ថុអានុស្សាវរីយ៍ និងការផ្តល់សេវានានា ព្រមទាំងការផ្គត់ផ្គង់អគ្គិសនីដល់តំបន់ខ្លះៗ។ ក្រសួងទេសចរណ៍ បានកសាងផែនការសកម្មភាពយុទ្ធសាស្ត្រ ដែលគូសបញ្ជាក់អំពីជម្រើសនានាសម្រាប់បង្កើតដំណោះស្រាយសមស្រប ខាងបរិស្ថាន ក្នុងការដោះស្រាយការប្រឈមខាងលើនេះ ដោយបង្កើនការលើកទឹកចិត្តសម្រាប់ការអភិវឌ្ឍអេកូទេសចរណ៍ ដែលរួមទាំង ប្រព័ន្ធវិញ្ញាបនប័ត្របៃតងសម្រាប់សណ្ឋាគារ ការវេចខ្ចប់សំណល់ ការប្រើប្រាស់ថាមពលកកើតឡើងវិញ ដូចជា ជីវឧស្ម័ន ការប្រើប្រាស់ស្រូវសរីរាង្គ ដែលផលិតនៅក្នុងស្រុក និងផលិតផលសរីរាង្គ ព្រមទាំងកិច្ចផ្តួចផ្តើមនានាដទៃទៀត ។

## ៥) និរន្តរភាពនៃការដឹកជញ្ជូន

វិស័យដឹកជញ្ជូនដើរតួយ៉ាងសំខាន់នៅក្នុងការអភិវឌ្ឍសេដ្ឋកិច្ចនៅកម្ពុជា។ ហេដ្ឋារចនាសម្ព័ន្ធទូទាំងប្រទេស និងការតភ្ជាប់ជាមួយប្រទេសជិតខាង ជាការសំរួលដល់គ្រប់ភាគីទាំងឡាយ គ្រប់ទីប្រជុំជន រាជធានី ខេត្ត-ក្រុង និងជនបទ ដែលជំរុញឱ្យមានការអភិវឌ្ឍបានឆាប់រហ័ស។ ទន្ទឹមនឹងនេះ សកម្មភាពដឹកជញ្ជូនតាមផ្លូវដែក និងតាមសមុទ្រ នៅមានកម្រិតទាប ធៀបនឹងសក្តានុពលរបស់វា និងគួរតែអភិវឌ្ឍបន្ថែមទៀត។ ក្រសួងពាក់ព័ន្ធដូចខាងក្រោមនេះ គួរធ្វើកិច្ចសហការ និងសហប្រតិបត្តិការជាមួយគ្នា ដើម្បីលើកទឹកចិត្ត និងពង្រឹងការអភិវឌ្ឍការដឹកជញ្ជូនឱ្យមាននិរន្តរភាព : ក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងបរិស្ថាន ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្រសួងធនធានទឹក និងឧតុនិយម ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងពាណិជ្ជកម្ម ក្រសួងសុខាភិបាល ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ អាជ្ញាធររាជធានីភ្នំពេញ អាជ្ញាធរខេត្ត-ក្រុង ក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងទេសចរណ៍។ លើសពីនេះ ការដឹកជញ្ជូនតាមផ្លូវទឹកមានសារៈសំខាន់សម្រាប់ប្រជាជន នៅតាមជនបទក្នុងការធ្វើដំណើរ ចំណែកការដឹកជញ្ជូនតាមផ្លូវអាកាស មានតួនាទីសំខាន់យ៉ាងខ្លាំងនៅក្នុងឧស្សាហកម្មទេសចរណ៍។

ការដឹកជញ្ជូននៅក្នុងប្រទេសកម្ពុជាបានប្រឈមនឹងការលំបាកជាច្រើន ដូចជា កង្វះជម្រើសដឹកជញ្ជូនសាធារណៈដែលងាយស្រួល និងដែលមានថ្លៃទាប ការរំលោភលើច្បាប់ចរាចរ ការដាក់កំហិតតិចតួច ឬគ្មានការកំហិតលើចំនួនយានយន្ត ការធ្វើចរាចរដោយគ្មាន ឬមានមធ្យោបាយមិនគ្រប់គ្រាន់សម្រាប់សម្រួលដល់អ្នកថ្មើរជើង (ចិញ្ចើមផ្លូវ ភ្លើងចរាចរ ។ល ។) ដែលនាំឱ្យមានការស្ទះចរាចរ ។ ទោះជាយ៉ាងណាក៏ដោយ មានការចាត់ចែងខ្លះៗរួចមកហើយ ដើម្បីដោះស្រាយការប្រឈមទាំងនេះ: ការពង្រឹងជាបន្ថែម និងការអនុវត្តឱ្យមានប្រសិទ្ធិភាពនូវច្បាប់ចរាចរដែលមានស្រាប់ ការជម្រុញឱ្យមានមធ្យោបាយដឹកជញ្ជូនសាធារណៈ និងការកែលម្អគុណភាពចញ្ចើមផ្លូវ (ក្រសួងសាធារណការនិងដឹកជញ្ជូន ក្រសួងមហាផ្ទៃ និង អាជ្ញាធររាជធានីភ្នំពេញ និងអាជ្ញាធរខេត្ត-ក្រុង) ។ លើសពីនេះ ការត្រួតពិនិត្យជាទៀងទាត់លើម៉ាស៊ីនយានយន្ត អាចធានាលើគុណភាព និង ដំណើរការ នៃម៉ាស៊ីន និងដើម្បីធានាប្រសិទ្ធិភាពនៃចំហេះ (ក្រសួងសាធារណការនិងដឹកជញ្ជូន ក្រសួងបរិស្ថាន ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ក្រសួងពាណិជ្ជកម្ម) ។ ការជម្រុញឱ្យប្រើប្រាស់មធ្យោបាយដឹកជញ្ជូនសាធារណៈគឺជាប្រការចាំបាច់ និងគោលនយោបាយ ដែលគាំទ្រឱ្យប្រើប្រាស់មធ្យោបាយដឹកជញ្ជូនសាធារណៈ អាចធ្វើឱ្យមានភាពទាក់ទាញកាន់តែខ្លាំងឡើងដល់វិស័យឯកជនក្នុងការវិនិយោគលើការអភិវឌ្ឍមធ្យោបាយដឹកជញ្ជូនសាធារណៈ ។ ការជម្រុញឱ្យយានយន្តប្រើប្រាស់ឧស្ម័ន ឬប្រេងរុក្ខជាតិ ដើម្បីកាត់បន្ថយការញ្ចេញឧស្ម័នពុល អាចជាចំណុចមួយផ្សេងទៀតដែលត្រូវយកចិត្តទុកដាក់ ។ក្នុងដំណាក់កាលនេះ រដ្ឋាភិបាល គួរបន្តអំពាវនាវ និងពង្រឹងកិច្ចសហប្រតិបត្តិការ និងសហការរវាងក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួងបរិស្ថាន អាជ្ញាធររាជធានីភ្នំពេញ និងអាជ្ញាធរខេត្ត-ក្រុង និងក្រសួងសុខាភិបាល ដើម្បីរៀបចំផែនការសកម្មភាពសម្រាប់ការដឹកជញ្ជូនឱ្យមាននិរន្តរភាព ដែលផ្តោតលើការកាត់បន្ថយការបញ្ចេញផ្សែងពុលនៅក្នុងបរិស្ថានទីក្រុងដែលកើតចេញពីការស្ទះចរាចរ កាត់បន្ថយគ្រោះថ្នាក់ចរាចរ និងកាត់បន្ថយការបញ្ចេញឧស្ម័ន CO និង $CO_2$ ទៅក្នុង បរិយាកាស ។

ដើម្បីកែលម្អការដឹកជញ្ជូននៅក្នុងទីជនបទ និងនៅក្នុងតំបន់ព្រៃឈើ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គួរកែលម្អ និងពង្រឹងគោលនយោបាយ ផែនការសកម្មភាព និងយុទ្ធសាស្ត្រដែលមានស្រាប់សម្រាប់ការអភិវឌ្ឍដោយចីរភាព ។ ដើម្បីធានាថាការអភិវឌ្ឍផ្លូវថ្មល់នៅក្នុងតំបន់ព្រៃឈើ មិននាំឱ្យមានកំណើនការបាត់បង់ព្រៃឈើ ដោយសារតែការកាប់ឈើដោយល្មើសច្បាប់ ។ កិច្ចសហប្រតិបត្តិការ និងការសម្របសម្រួលរវាង ក្រសួងសាធារណការនិងដឹកជញ្ជូន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងក្រសួងបរិស្ថាន មានសារៈសំខាន់ណាស់ ដើម្បីធ្វើអត្តសញ្ញាណចំណែកដី សមស្របសម្រាប់សាងសង់ផ្លូវ ដើម្បីបញ្ចៀសឥទ្ធិពលអវិជ្ជមានមកលើការតាំងទីលំនៅ និងដីកសិកម្ម ។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាចកែលម្អជាបន្ថែម និងពង្រឹងគោលនយោបាយ ផែនការសកម្មភាព និងយុទ្ធសាស្ត្រ ដែលមានស្រាប់ សម្រាប់ការអភិវឌ្ឍ មធ្យោបាយដឹកជញ្ជូន ដើម្បីធានាឱ្យមានភាពចុះសម្រុងគ្នារវាងការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព និងជម្រើសនៃការដឹកជញ្ជូន ដែលមាននិរន្តរភាព នៅក្នុងតំបន់ទាំងនេះ ។ យុទ្ធនាការបង្កើនការយល់ដឹងអំពី សុវត្ថិភាពចរាចរត្រូវបានលើកស្ទើឡើង ស្របជាមួយវិស្វកម្មប្រព័ន្ធចរាចរប្រសើរជាងមុន ការគ្រប់គ្រងលើតម្រូវការដឹកជញ្ជូន ប្រព័ន្ធដឹកជញ្ជូនសាធារណៈ និងការអប់រំយុវជន និង អ្នកថ្មើរជើង ។ វិស័យទេសចរណ៍ ក៏មានការពាក់ព័ន្ធជាមួយការដឹកជញ្ជូន ដោយសារភ្ញៀវទេសចរដែលមកទស្សនាកម្ពុជា អាចប្រើប្រាស់បានយ៉ាងច្រើននូវជម្រើសដឹកជញ្ជូនដែលមានស្រាប់ (ក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួងមហាផ្ទៃ និងក្រសួង ទេសចរណ៍) ។ ជាក់ស្តែង ភ្ញៀវទេសចរភាគច្រើនបានស្នាក់នៅ និងប្រើប្រាស់មធ្យោបាយដឹកជញ្ជូន ដែលមានស្រាប់ជាច្រើន (កង់ រថយន្ត ទូក កាណូត រថភ្លើង

និងយន្តហោះ)។ នៅពេលថ្មីៗនេះ ក្រសួងទេសចរណ៍បានអះអាង អំពីតម្រូវការសាងសង់ស្ថានីយ៍នៅតាមដងផ្លូវ តាមរយៈជំនួយពីមូលនិធិសមាហរណកម្មអាស៊ាននៃប្រទេសជប៉ុន(JAIF) នៅក្រោមប្រព័ន្ធសហប្រតិបត្តិការអភិវឌ្ឍន៍ ត្រីកោណ( មណ្ឌលគិរី ស្ទឹងត្រែង និងរតនគិរី)[3]គេចាំបាច់ត្រូវកែលម្អ និងសាងសង់ផ្លូវជាច្រើនថែមទៀត ។គេគួរដាក់បញ្ចូលការប្រើប្រាស់រទេះសេះ រទេះគោតាមប្រពៃណី កង់ និង/ឬ មធ្យោបាយបច្ចេកទេសទំនើបផ្សេងទៀត ដែលបញ្ចេញកាបូនតិចសម្រាប់ការដឹកជញ្ជូន ដើម្បីកាត់បន្ថយការបំពុល និងការបញ្ចេញកាបូន នៅតាមកន្លែងទេសចរណ៍សមស្របនានា ។

## ៤.៣ អន្តរាគមន៍សម្រាប់រយៈពេលវែង (១០-២០ ឆ្នាំ)

រាជរដ្ឋាភិបាលកម្ពុជា បានដឹងយ៉ាងច្បាស់អំពីគោលការណ៍ជាមូលដ្ឋាន ក្នុងការដឹកនាំប្រទេសកម្ពុជាទៅរកការអភិវឌ្ឍ ដែលអាចបំពេញភាពចាំបាច់របស់ប្រជាជន ។ ប្រការដែលយកចិត្តទុកដាក់រួមមាន : ការគោរពយ៉ាងហ្មឺងម៉ាត់តាមគោលការណ៍ ប្រជាធិប-តេយ្យនៅក្នុងអភិបាលកិច្ច ការរក្សាស្ថិរភាពនយោបាយ នីតិរដ្ឋ សមធម៌ និងសណ្តាប់ធ្នាប់សង្គម ការឆ្លើយតបយ៉ាងពេញលេញប្រកបដោយការទទួលខុសត្រូវ ប្រសិទ្ធិភាព តម្លាភាព គណនេយ្យភាព និងដែលអាចព្យាករណ៍បាន និងដើម្បីធានាឱ្យមានស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច កសាងនិងថែរក្សាហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ ក៏ដូចជាបរិយាកាសអំណោយផលសម្រាប់ការអភិវឌ្ឍវិស័យឯកជន និង ផ្តល់សេវាកម្មសង្គមសំខាន់ៗ សម្រាប់ការបង្កើតនិងពង្រឹងមូលធនមនុស្ស ។ ទោះជាយ៉ាងណាក៏ដោយ ប្រទេសកម្ពុជា បានចាត់វិធានការជាច្រើនរួចមកហើយ សម្រាប់ឆ្លើយតបទៅនឹងការអភិវឌ្ឍបៃតងដើម្បីកំណើនសេដ្ឋកិច្ច ។ អាស្រ័យហេតុនេះ រាជរដ្ឋាភិបាល គួរផ្តោតជាបន្ថែមលើផលប្រយោជន៍រយៈពេលវែង នៃការកែលម្អប្រសិទ្ធិភាពថាមពលនៅក្នុងវិស័យដែលប្រើប្រាស់ថាមពលច្រើន និងការវិនិយោគលើការដឹកជញ្ជូន និងថាមពលកកើតឡើងវិញឱ្យមាននិរន្តរភាព ទន្ទឹមនឹងវិធានការនានាដែលជម្រុញផលិតភាពកសិកម្មដោយគោរពតាមគោលការណ៍ធម្មជាតិ ការគ្រប់គ្រងដែនទឹកសាបឱ្យមាននិរន្តរភាព និងការធ្វើឱ្យប្រជាជន ទទួលបានអនាម័យសមស្រប ។

លើសពីនេះ ចាំបាច់ត្រូវលើកទឹកចិត្តឱ្យមានការបញ្ចូលគោលការណ៍នៃការអភិវឌ្ឍបៃតង ទៅក្នុងប្រព័ន្ធអប់រំ ដោយត្រូវយកចិត្តទុកដាក់ដើម្បីបង្កើនការយល់ដឹង និងកសាងសមត្ថភាពអំពីគោលគំនិត អំពីការអភិវឌ្ឍបៃតងសម្រាប់កម្មករ និងកសិករ ទន្ទឹមនឹងការពិចារណាបញ្ជ្រាបសមធម៌យេនឌ័រទៅក្នុងគោលគំនិតនៃការអភិវឌ្ឍបៃតង ។ សម្រាប់រយៈពេលវែង រាជរដ្ឋាភិបាល គួរតែបន្តកាត់បន្ថយនូវការឧបត្ថម្ភធនមិនសមស្រប ដូចជា លើផ្នែកឥន្ធនៈផូស៊ីល និងត្រូវជំនួសវិញតាមរយៈការលើកទឹកចិត្ត និងការយកពន្ធឱ្យបានសមស្រប ដែលនឹងជម្រុញឱ្យមានសេដ្ឋកិច្ចបៃតង ។ រដ្ឋាភិបាល គួរបន្តតែពិចារណាអំពីកំណែទម្រង់ផ្សេងទៀត ដើម្បីដោះស្រាយបញ្ហារួមនៃគោលនយោបាយប្រើប្រាស់ដី និងការអភិវឌ្ឍទីក្រុង ដើម្បីកែលម្អការគ្រប់គ្រងដីសាធារណៈ និងកម្មសិទ្ធិដីធ្លី ។ រដ្ឋាភិបាល គួរតែបន្តពង្រឹងអន្តរាគមន៍សម្រាប់រយៈពេលវែង ដែលអាចផ្តល់លទ្ធភាពសម្រាប់បង្កើតឱកាសពិតប្រាកដ ដើម្បីជួយដល់ជនក្រីក្រ និងជនងាយរងគ្រោះ ក្នុងការស្តារបរិស្ថានមករកស្ថានភាព ដែលមានសក្តានុពលពេញលេញ និងកែលម្អការចិញ្ចឹមជីវិតរបស់ប្រជាជន ។

---

[3] ខេត្តទាំងបីនេះ ស្ថិតនៅភាគឦសាននៃប្រទេស និងមានព្រំប្រទល់ជាប់ជាមួយប្រទេសវៀតណាម និងប្រទេសឡាវ ។

## ៤.៣.១ កិច្ចផ្តួចផ្តើមខាងសារពើពន្ធ

ជាទូទៅ ផែនការរួមសម្រាប់ការអភិវឌ្ឍប្រព័ន្ធហិរញ្ញវត្ថុ មានចែងនៅក្នុងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ផែនការនេះមានលក្ខណៈទូលំទូលាយ ប្រកបដោយទស្សនៈទានអំពីការអនុវត្តជំហាន១នៅក្នុងការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ។ មកទល់សព្វថ្ងៃនេះ ក៏មានការរីកចម្រើនច្រើនរួចមកហើយលើការអភិវឌ្ឍក្របខ័ណ្ឌច្បាប់ និងបទប្បញ្ញត្តិនានា។ ទោះជាយ៉ាងណាក៏ ក្រសួងនេះនៅមានកិច្ចការជាច្រើនទៀត ដែលគួរបន្តធ្វើដើម្បីធ្វើឱ្យកំណើនម៉ាក្រូសេដ្ឋកិច្ចមានស្ថិរភាព និងរឹងមាំ មានបទប្បញ្ញត្តិលើសារពើពន្ធ និងវិស័យហិរញ្ញវត្ថុដែលរស់រវើក ដើម្បីធានាឱ្យមានការរីកចម្រើនជានិច្ច។ អាស្រ័យហេតុនេះ

រាជរដ្ឋាភិបាលកម្ពុជា គួរតែពិចារណាលើគោលនយោបាយរបស់ខ្លួនក្នុងការឧបត្ថម្ភធន ដើម្បីធានាថា ការឧបត្ថម្ភធនពុំបង្កផលវិបាកអវិជ្ជមានឡើយ ហើយសកម្មភាពនានាក៏មិនបង្កគ្រោះថ្នាក់ចំពោះបរិស្ថាន ដែរ។ ក្នុងន័យនេះ រាជរដ្ឋាភិបាលកម្ពុជា អាចអនុវត្តគោលការណ៍អ្នកបំពុលត្រូវបង់ថ្លៃ ដើម្បីជម្រុញឱ្យមានការគិតបញ្ចូលនូវការខូចខាតមកលើបរិស្ថាន។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក៏គួរតែបន្តអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុរបស់ខ្លួន ដើម្បីគាំទ្រដល់ការអភិវឌ្ឍប្រព័ន្ធហិរញ្ញវត្ថុ ដែលផ្អែកលើយន្តការទីផ្សារសមស្រប ដើម្បីគាំទ្រដល់ការកៀងគរធនធាន ការបែងចែកធនធានហិរញ្ញវត្ថុឱ្យមានប្រសិទ្ធិភាព និង កំណើនសេដ្ឋកិច្ច ដែលមានមូលដ្ឋានធំទូលាយប្រកបដោយនិរន្តរភាព។

## ៤.៣.២ កសិកម្មស្របតាមគោលការណ៍ធម្មជាតិ

កសិកម្មស្របតាមគោលការណ៍ធម្មជាតិ នាំមកនូវផលជាច្រើន និងមានសក្តានុពល ក្នុងការធានាសន្តិសុខស្បៀង។ គោលការណ៍នេះអាចអនុញ្ញាតឱ្យកសិករកែលម្អផលិតកម្មស្បៀងរបស់ខ្លួន ដោយប្រើប្រាស់បច្ចេកវិទ្យា និងសម្ភារៈដែលចំណាយតិច និងដែលមានស្រាប់ ដោយពុំបង្កការខូចខាតចំពោះបរិស្ថាន ឡើយ។ កសិកម្មស្របតាមគោលការណ៍ធម្មជាតិ រួមមាន វិធានការចម្រុះការពារដំណាំ ការគ្រប់គ្រងសារធាតុចិញ្ចឹមតាមវិធីចម្រុះ ការភ្ជួររាស់ដីក្នុងកម្រិតអប្បបរមា កសិ-រុក្ខកម្ម ការរក្សាទុកទឹកភ្លៀងសម្រាប់ប្រើប្រាស់នៅក្នុងតំបន់រាំងស្ងួត កង្ហារសម្រាប់បូមទឹក ការផ្គត់ផ្គង់ទឹកដោយប្រពន្ធ័ស្រោចស្រព និងការរួមបញ្ចូលនូវការចិញ្ចឹមសត្វ និងវារីវប្បកម្មទៅក្នុងប្រព័ន្ធកសិកម្ម។ ការអនុវត្តដែលមានប្រសិទ្ធិភាព មិនត្រឹមតែបង្កើនទិន្នផលនោះទេ ប៉ុន្តែត្រូវកាត់បន្ថយឥទ្ធិពលអវិជ្ជមានមកលើបរិស្ថាន និងរួមចំណែកផ្តល់ផលិតផល និងសេវាកម្មដែលមានសារៈសំខាន់ចំពោះបរិស្ថាន (ដូចជា កាត់បន្ថយការប្រែប្រួលអាកាសធាតុ) តាមរយៈកំណើនប្រសិទ្ធិភាពប្រើប្រាស់ទឹក និងការស្រូបយកកាបូន និងកាត់បន្ថយការប្រើប្រាស់ថ្នាំគីមីកសិកម្ម ទើបអាចសម្រេចបានគោលដៅនៃការអភិវឌ្ឍបៃតង។[4] ការណែនាំកសិករកម្ពុជា ឱ្យអនុវត្តកសិកម្មស្របតាមគោលការណ៍ធម្មជាតិ មានសារៈសំខាន់ណាស់ ដែលអាចជួយកសិករកែលម្អគុណភាពអាហារ និងបង្កើតផលិតកម្មស្បៀង ដែលផ្តល់សុខភាពល្អ និងធានានូវនិរន្តរភាពបរិស្ថាន។

[4] http://www.auroville.org/environment/agri.htm and http://www.twnside.org.sg/title2/susagri/susagri064.htm

វិស័យកសិកម្ម គឺជាវិស័យសំខាន់មួយក្នុងនយោបាយរបស់កម្ពុជា ដែលស្ថិតក្រោមឥទ្ធិពលជាច្រើន រួមទាំងកិច្ចការពារខាងពាណិជ្ជកម្ម ការឧបត្ថម្ភធនមិនសមស្រប ការខ្វះខាតទឹក ការដាំដំណាំដែលពុំមាននិរន្តរភាព និងការប្រើប្រាស់សារធាតុគីមីគ្រោះថ្នាក់ច្រើនហួសកម្រិត។ ដើម្បីកាត់បន្ថយភាពងាយរងគ្រោះនៃវិស័យនេះ រាជរដ្ឋាភិបាលកម្ពុជា បានលើកទឹកចិត្តឱ្យមានការវិនិយោគលើកសិកម្ម ដែលផ្តល់និរន្តរភាព និងកសិកម្មសរីរាង្គ។ លើសពីនេះ រាជរដ្ឋាភិបាលកម្ពុជា គួរពិចារណាអំពីការវិនិយោគ លើប្រព័ន្ធទឹកសាប ដើម្បីបង្កើនផលិតភាពកសិកម្ម និងកាត់បន្ថយការបាត់បង់នៅពេលបញ្ជូនទឹក/កែលម្អមធ្យោបាយរក្សាទឹកទុកសម្រាប់ប្រព័ន្ធស្រោចស្រព។ និរន្តរភាពកសិកម្ម មានទំនាក់ទំនងជិតស្និទ្ធជាមួយការផ្គត់ផ្គង់ទឹក ដូច្នេះ រដ្ឋាភិបាលគួរលើកទឹកចិត្តឱ្យអនុវត្តគោលនយោបាយរបស់ខ្លួន ស្តីពីកំណែលម្អប្រព័ន្ធស្រោចស្រពតាមរយៈការស្តារឡើងវិញនូវប្រព័ន្ធស្រោចស្រពដែលមានស្រាប់ និងកសាងប្រព័ន្ធថ្មីៗជាបន្ថែម ដើម្បីធានាថាកសិករមានទឹកគ្រប់គ្រាន់សម្រាប់ប្រើប្រាស់។

រាជរដ្ឋាភិបាលកម្ពុជា គួរលើកទឹកចិត្តឱ្យមានការគាំទ្រដូចគ្នា ដល់និរន្តរភាពផលិតកម្មកសិកម្ម ដែលរួមទាំង ផលិតផលកសិកម្មសរីរាង្គ តាមរយៈកំណើនការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធសម្រាប់ផលិតសម្ភារៈកសិកម្មសរីរាង្គ ការរក្សាទុក និងដឹកជញ្ជូនផលិតផល និងអាចផ្តល់នូវការឧបត្ថម្ភធនសម្រាប់ការចាប់ផ្តើមដំបូងនៃការវិនិយោគ និង/ឬ ប្រាក់កម្ចីអនុគ្រោះ។ ទោះជាយ៉ាងណាក៏ដោយ ដើម្បីអនុវត្តឱ្យបានជោគជ័យ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គួរពង្រឹងកិច្ចសហប្រតិបត្តិការជាមួយក្រសួង ធនធានទឹក និងឧតុនិយម លើការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កសិកម្ម និងធនធានទឹក ដើម្បីធានាវត្តមាន និងសុវត្ថិភាពស្បៀង និងទឹកគ្រប់គ្រាន់សម្រាប់ការអភិវឌ្ឍវិស័យកសិកម្មបានសមស្រប និងមាននិរន្តរភាព ដែលមានការចំណាយទាប។ ក្នុងន័យនេះ រាជរដ្ឋាភិបាលកម្ពុជា គួរផ្តោតការយកចិត្តទុកដាក់ថែមទៀតលើការបង្កើនប្រពលភាពផលិតកម្មដំណាំដើម្បីបង្កើនទិន្នផល និងប្រាក់ចំណូលនៅជនបទ ធ្វើពិពិធកម្មដំណាំ កែលម្អការគ្រប់គ្រងជលផល ការគ្រប់គ្រងព្រៃឈើឱ្យមាននិរន្តរភាព តាមរយៈកំណែទម្រង់ការអភិរក្សបរិស្ថាន និងការអនុវត្តកំណែទម្រង់ដីធ្លី ដើម្បីធានាឱ្យអ្នកក្រមានដីកម្មសិទ្ធិសម្រាប់ប្រើប្រាស់។ លើសពីនេះ រដ្ឋាភិបាលគួររៀបចំយុទ្ធសាស្ត្រលំអិត សម្រាប់វិស័យកសិកម្ម លើកទឹកចិត្ត និងសម្រួលឱ្យវិស័យឯកជន បានចូលរួមនៅក្នុងកសិកម្ម និងការកែច្នៃផលិតផលកសិកម្ម និងសហការជាមួយសភាពាណិជ្ជកម្មកម្ពុជា ដើម្បីពង្រឹងការជម្រុញពីខាងទីផ្សារសម្រាប់ទាក់ទាញផលិតផលកសិកម្មសរីរាង្គ។

## ៤.៣.៣ ការកែលម្អហេដ្ឋារចនាសម្ព័ន្ធ និងពាណិជ្ជកម្ម

កង្វល់ទូទាំងពិភពលោកអំពីបញ្ហាបរិស្ថាន កំពុងជម្រុញភាពរស់រវើកខាងទីផ្សារសម្រាប់ស្រូបយកផលិតផល និងសេវាកម្មបរិស្ថាន (EGS)។ ទីផ្សារគ្របដណ្តប់លើវិស័យខុសៗគ្នាជាច្រើន រាប់ចាប់ពីវិស័យដែលផ្អែកលើធនធានធម្មជាតិ រហូតដល់បច្ចេកវិទ្យា និងសេវាកម្មបរិស្ថាន។ ឧស្សាហកម្មបរិស្ថាន កំពុងរីកចម្រើននៅក្នុងប្រទេសពុំសូវលូតលាស់ និងប្រទេសលូតលាស់តិចតួចជាងគេនៅតំបន់អាស៊ីខាងត្បូង និងអាស៊ីអាគ្នេយ៍ ដែលរួមទាំងកម្ពុជា។ បច្ចេកវិទ្យាបរិស្ថានខ្លះដែលអាចជាវបាន ត្រូវបានអនុវត្តរួចមកហើយនៅក្នុងប្រទេសកម្ពុជា។ ការប្រើប្រាស់បច្ចេកវិទ្យាបែបនេះ នៅពុំទាន់បានទូលំទូលាយនៅឡើយទេ ដោយសារតែកង្វះព័ត៌មាន

និងភាពទន់ខ្សោយនៃការចាត់ចែងខាងទីផ្សារ កម្រិតទាបនៃទំនាក់ទំនងជាមួយមុខជំនួញបៃតង និងកង្វះភាពជាដៃគូ រវាងវិស័យសាធារណៈ និងឯកជន។

ទន្ទឹមនឹងនេះ កម្ពុជាក៏គួរតែពិចារណា អំពីសក្តានុពលរបស់ខ្លួនក្នុងការនាំចេញបច្ចេកវិទ្យា និងសេវាបរិស្ថាន តាមរយៈឧស្សាហកម្មនាំមុខរបស់ខ្លួននៅក្នុងតំបន់នេះ។ ពាណិជ្ជកម្មរវាងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ អាចសម្រួលឱ្យមានការផ្ទេរបច្ចេកវិទ្យា និងសេវាកម្មពាក់ព័ន្ធនានាជាច្រើន និងគួរតែត្រូវបានចាត់ទុកថាជាឧបករណ៍ ដែលមានប្រសិទ្ធិភាពសម្រាប់ការអភិវឌ្ឍ ដោយនិរន្តរភាព ដែលបញ្ចេញកាបូនតិច ក៏ដូច ជាប្រភពនៃការងារ "បៃតង" និងផលចំណូលពីការនាំចេញ។

ដើម្បីជម្រុញការអភិវឌ្ឍន៍នៅជនបទជាបន្ថែម និងស្របជាមួយគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ រដ្ឋាភិបាលគួរតែផ្តោតការយកចិត្តទុកដាក់លើហេដ្ឋារចនាសម្ព័ន្ធ ផ្លូវថ្នល់នៅជនបទ ទីផ្សារ និងមធ្យោបាយសម្រាប់ផ្គត់ផ្គង់ទឹកស្អាត អនាម័យ ប្រព័ន្ធស្រោចស្រពខ្នាតតូច សាលារៀន និងសេវាកម្មសុខភាព។ល។ ដែលភាគច្រើនអាចធ្វើបានតាមរយៈការផ្ទេរមូលនិធិ តាមរយៈក្រុមប្រឹក្សាឃុំ ដែលអាចបង្កើតការងារធ្វើ និងឱកាសសម្រាប់ជម្រុញសេដ្ឋកិច្ចនៅមូលដ្ឋាន។ ហេដ្ឋារចនាសម្ព័ន្ធរូបវន្តផ្សេងទៀត រួមមាន ផ្លូវថ្នល់ជាតិ ផ្លូវខេត្ត ផ្លូវដែក ព្រលានយន្តហោះ កំពង់ផែ ប្រព័ន្ធស្រោចស្រព ប្រព័ន្ធទូរគមនាគមន៍ ប្រព័ន្ធផលិត និងបណ្តាញចែកចាយអគ្គិសនី គួរតែត្រូវបានចាត់ទុកជាអាទិភាព និងលើកទឹកចិត្ត។ ដូច្នេះ ក្រសួងសាធារណការ និងដឹកជញ្ជូន គួរបន្តអនុវត្តឱ្យមានប្រសិទ្ធិភាពនូវយុទ្ធសាស្ត្រអភិវឌ្ឍន៍ការដឹកជញ្ជូន ដែលមាននិរន្តរភាពបរិស្ថាន ដើម្បីធានាឱ្យមានកំណើនសេដ្ឋកិច្ច និង និរន្តរភាពបរិស្ថាន រួមទាំង :

- ការបង្កើតបណ្តាញដឹកជញ្ជូន ស្របជាមួយផែនការប្រើប្រាស់ដី ដោយលៃទុកកន្លែងសម្រាប់គ្រោងអភិវឌ្ឍន៍ និងការបង្កើតបណ្តាញផ្លូវថ្នល់ ដើម្បីជម្រុញការអភិវឌ្ឍទីក្រុងតាមការគ្រោងទុក (ក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួងបរិស្ថាន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់)
- ការដាក់ឱ្យអនុវត្តប្រព័ន្ធដឹកជញ្ជូនសាធារណៈទំនើប និងថ្មីៗ សម្រាប់ឆ្លើយតបទៅនឹងតម្រូវការចរាចរទៅអនាគត ក៏ដូចជា ការអភិវឌ្ឍរាជធានី និងទីក្រុងឱ្យក្លាយជាមជ្ឈមណ្ឌលសេដ្ឋកិច្ច និងប្រព័ន្ធដែលអំណោយផលដល់ការវិនិយោគ និង ដែលអាចប្រតិបត្តិការដោយការចំណាយតិច (ក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងពាណិជ្ជកម្ម ក្រសួងមហាផ្ទៃ ក្រសួងបរិស្ថាន អាជ្ញាធរ រាជធានីភ្នំពេញ និង អាជ្ញាធរ ខេត្ត-ក្រុង );
- ការអភិវឌ្ឍប្រព័ន្ធដឹកជញ្ជូនដែលមានប្រសិទ្ធិភាព ផាសុខភាព និងសុវត្ថិភាព ដើម្បីកាត់បន្ថយការស្ទះចរាចរនៅលើដងផ្លូវសំខាន់ៗ និងបង្កើនតួនាទីនៃប្រព័ន្ធដឹកជញ្ជូន (ក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួងមហាផ្ទៃ អាជ្ញាធររាជធានីភ្នំពេញ និង អាជ្ញាធរ ខេត្ត-ក្រុង);
- ការកែលម្អបរិស្ថានទីក្រុង និងចរាចរ ដើម្បីស្តារឡើងវិញនូវចិញ្ចើមផ្លូវជាតិ និងផ្លូវខេត្ត ជាពិសេស នៅតាមទីប្រជុំជន និងដាក់ឱ្យអនុវត្តប្រព័ន្ធដឹកជញ្ជូនសាធារណៈ ដែលសមស្របសម្រាប់បរិស្ថានទីក្រុង និងទេសចរណ៍ (ក្រសួងសាធារណ

ការ និងដឹកជញ្ជូន ក្រសួងបរិស្ថាន ក្រសួងមហាផ្ទៃ ក្រសួងទេសចរណ៍ ក្រសួងដែនដី នគរូបនីយកម្ម និងសំណង់ និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ) និង

- ការបង្កើតប្រព័ន្ធបញ្ជាចរាចរ ដែលមានប្រសិទ្ធិភាព ដោយមានបំពាក់សញ្ញាចរាចរនៅតាមទីក្រុង និងទីប្រជុំជន ដើម្បីចាត់វិធានការកាត់បន្ថយគ្រោះថ្នាក់ចរាចរ និងកាត់បន្ថយការស្ទះចរាចរ និងអប់រំអំពីច្បាប់ចរាចរ ក៏ដូចជាពង្រឹងការអនុវត្តច្បាប់ចរាចរ (ក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងមហាផ្ទៃ អាជ្ញាធររាជធានីភ្នំពេញ និង អាជ្ញាធរ ខេត្ត-ក្រុង)

### ៤.៣.៤ និរន្តរភាពថាមពល

ប្រទេសកម្ពុជាត្រូវការជាចាំបាច់នូវថាមពលសម្រាប់ជម្រុញការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម។ រាជរដ្ឋាភិបាល បានពង្រឹង និងជម្រុញសន្តិសុខថាមពលរបស់ប្រទេស តាមរយៈការវិនិយោគលើបច្ចេកវិទ្យាខុសៗគ្នា ដែលផ្តល់សក្តានុពលសម្រាប់កាត់បន្ថយការពឹងផ្អែកលើឥន្ធនៈផូស៊ីលធម្មតា ក៏ដូចជា ដើម្បីកាត់បន្ថយឥទ្ធិពលមកលើបរិស្ថាន និងសុខភាពប្រជាជន។ ដូច្នេះ រដ្ឋាភិបាល គួរបន្តជម្រុញ និងលើកទឹកចិត្តជាបន្ថែម ដើម្បីឱ្យមានការផលិតថាមពលកកើតឡើងវិញ និងគួរបង្កើតក្របខ័ណ្ឌគោលនយោបាយ ដើម្បីប្រើប្រាស់ប្រភពថាមពលកកើតឡើងវិញ សម្រាប់អគ្គិសនីកម្មជនបទ តាមរយៈ :

- ពុះពារដើម្បីផ្តល់សេវាកម្មអគ្គិសនី ដែលមានសុវត្ថិភាព និងមានផលប៉ះពាល់ត្រឹមកម្រិតអប្បរមាមកលើបរិស្ថាន ដោយតម្រូវឱ្យសហគមន៍ជនបទបង់ថ្លៃចំណាយក្នុងកម្រិតតិចបំផុត ដែលអាចទទួលយកបាន
- ផ្តល់ក្របខ័ណ្ឌច្បាប់ ការគាំទ្រដែលមានប្រសិទ្ធិភាព តាមរយៈការលើកទឹកចិត្តខុសៗគ្នា និងពង្រឹងការចូលរួមនៃវិស័យឯកជន ដើម្បីផ្គត់ផ្គង់សេវាកម្មថាមពលអគ្គិសនីកកើតឡើងវិញ (ថាមពលព្រះអាទិត្យ ថាមពលខ្យល់ ថាមពលវារីអគ្គិសនី ថាមពលទឹកជោរ-នាច និងជីវៈឧស្ម័ន/ជីវម៉ាស) ដល់សហគមន៍ជនបទ ដោយធ្វើឱ្យសហគមន៍មូលដ្ឋានចូលរួមដោយផ្ទាល់ក្នុងការបង្កើតតម្លៃបន្ថែម ដូចជា បង្កើនការងារ និងការបង្កើតជំនាញ។
- ដើរតួជាអ្នកសម្របសម្រួលខាងទីផ្សារ ដោយប្រើប្រាស់យន្តការលើកទឹកចិត្តខុសៗគ្នា ដែលសមស្របសម្រាប់សេវាកម្មអគ្គិសនី ដែលមានសមធម៌ និងមានសុវត្ថិភាព ដោយបង្កផលប៉ះពាល់មកលើបរិស្ថានក្នុងកម្រិតអប្បបរមា និងតាមតម្លៃដែលសហគមន៍ជនបទអាចជាវបាន។
- ពង្រឹងការផលិត ការបញ្ជូន និងចែកចាយអគ្គិសនី ដោយប្រើប្រាស់បច្ចេកវិទ្យាថាមពលកកើតឡើងវិញ តាមរយៈការកំណត់អត្រាអគ្គិសនី ដែលស្របជាមួយគោលការណ៍នៃច្បាប់អគ្គិសនីរបស់កម្ពុជា។
- លើកកំពស់ប្រព័ន្ធអគ្គិសនី ដែលប្រើប្រាស់ប្រព័ន្ធថាមពលកកើតឡើងវិញដែលមានថ្លៃទាបបំផុត សម្រាប់សហគមន៍ជនបទ និងការបង្កើតគំរូមួយដែលទាក់ទងនឹងការពង្រីកបណ្តាញអគ្គិសនី និងបង្កើនសេវាក្នុងតំបន់គ្មានបណ្តាញអគ្គិសនីនិង

- ការផ្តល់មូលនិធិ យន្តការសមស្រប និងការបណ្តុះបណ្តាលគ្រប់គ្រាន់ ដោយអនុញ្ញាតឱ្យមានការចូលរួមពីក្រុមប្រជាពលរដ្ឋដែលពុំមានលទ្ធភាពគ្រប់គ្រាន់ខាងហិរញ្ញវត្ថុ ទៅក្នុងកិច្ចប្រឹងប្រែងអគ្គិសនីកម្មជនបទ ។

### ៤.៣.៥ ការអភិវឌ្ឍវិស័យអប់រំ

ការកសាងសមត្ថភាព និងការអភិវឌ្ឍធនធានមនុស្ស ស្ថិតក្នុងចំណោមយុទ្ធសាស្ត្រអភិវឌ្ឍន៍ចំបង១របស់រដ្ឋាភិបាល ។ សព្វថ្ងៃនេះ ក្រសួងអប់រំ យុវជន និងកីឡា កំពុងផ្តោតការយកចិត្តទុកដាក់លើកំណែលម្អគុណភាពនៃការអប់រំនៅគ្រប់លំដាប់ថ្នាក់ ទាំងនៅថ្នាក់ចំណេះទូទៅ ក្រោយចំណេះទូទៅ និងឧត្តមសិក្សា និងបានផ្តោតការយកចិត្តទុកដាក់លើការពង្រឹងភាពជាដៃគូ រវាងវិស័យសាធារណៈ និងវិស័យឯកជន ដើម្បីកៀងគរ និងប្រើប្រាស់ធនធានឱ្យកាន់តែមានប្រសិទ្ធិភាព ។ ទោះជាយ៉ាងណាក៏ដោយ ក្រសួងអប់រំ យុវជន និងកីឡា គួរតែធានាថាកុមារកម្ពុជា និងយុវជនគ្រប់រូប មានលទ្ធភាពស្មើគ្នា ក្នុងការទទួលបានការអប់រំប្រកបដោយគុណភាព ដោយមិនគិតអំពីស្ថានភាពនៅក្នុងសង្គម ភូមិសាស្ត្រ ជនជាតិ សាសនា ភាសា ភេទ និងកាយសម្បទាឡើយ ។ ក្រៅពីនេះ ក៏ត្រូវផ្តោតការយកចិត្តទុកដាក់លើកម្រិតផ្សេងទៀត ដែលរួមទាំងការបណ្តុះបណ្តាលវិជ្ជាជីវៈ និងការអប់រំជាន់ខ្ពស់ ដើម្បីចាប់ផ្តើមកសាង "ឱ្យបានច្រើន"នូវប្រជាពលរដ្ឋដែលមានចំណេះដឹង ជំនាញ ទេពកោសល្យ និងសមត្ថភាពលើវិស័យខុស១គ្នា ដើម្បីបំពេញតម្រូវការអភិវឌ្ឍន៍របស់ប្រទេស (ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈទទួលទទួលខុសត្រូវ) ។ ការអប់រំត្រូវតែស្របតាម ស្តង់ដារអន្តរជាតិ និងតំបន់ ដើម្បីបង្កើនភាពប្រកួតប្រជែងរបស់កម្ពុជា នៅក្នុងទីផ្សារការងារលើពិភពលោក ។

### ៤.៣.៦ ការកែលម្អសុខភាព

បញ្ហាគន្លឹះសម្រាប់កែលម្អវិស័យសុខាភិបាល នឹងពឹងផ្អែកជាសំខាន់ ១) លើកំណើនធនធានដែលមាន ( ទាំងធនធានហិរញ្ញវត្ថុ និងវិជ្ជាជីវៈ និង ២) លើការពង្រឹងនូវការផ្តល់សេវា ដែលរួមទាំងការត្រួតពិនិត្យលើបទប្បញ្ញត្តិ និងវិជ្ជាជីវៈ ។ លើសពីនេះ នៅក្នុងការដោះស្រាយគុណភាពសុខាភិបាល ទាមទារឱ្យមានការផ្លាស់ប្តូរលើការថែទាំសុខភាព ដើម្បីឱ្យមានការលើកទឹកចិត្តដល់អ្នកជំនាញថែទាំ សុខភាព និងប្រព័ន្ធគ្រប់គ្រងទាំងនៅក្នុងការថែទាំសុខភាពក្នុងវិស័យឯកជន និងសាធារណៈ ។ គួរកត់សំគាល់ដែរថា វិស័យថែទាំសុខភាព បានរីកចម្រើនគួរឱ្យកត់សំគាល់ ប៉ុន្តែសូចនាករខ្លះ១ខាងសុខភាពនៅតែមានកម្រិតទាបនៅឡើយ ។ ដើម្បីកែលម្អការថែទាំសុខភាព គេត្រូវគិតគូរលើកិច្ចការជាច្រើនដូចខាងក្រោមនេះ :

- ពង្រីកវត្តមានគ្រឹះស្ថានថែទាំសុខភាព ដោយសាងសង់ និង/ឬ ជួសជុលមន្ទីរពេទ្យ មណ្ឌលសុខភាព ។ល ។ នៅទីជនបទ
- ពង្រីក និងពង្រឹងវិធីដែលមាននិរន្តរភាពសម្រាប់ការផ្តល់សេវា ដើម្បីជួយដល់អ្នកក្រក្នុងការទទួលបានសេវាសុខភាព ដូចជាការធានារ៉ាប់រងដោយយកកម្រៃទាប
- បង្កើតប្រសិទ្ធិភាព លើកទឹកចិត្តនិងធ្វើឱ្យវិស័យឯកជនពាក់ព័ន្ធនៅក្នុងការផ្តល់សេវាថែទាំសុខភាព ទាំងនៅទីក្រុងនិងជនបទ

- យកចិត្តទុកដាក់ជាពិសេសក្នុងការលុបបំបាត់ការរាតត្បាតនៃមេរោគអេដស៍/ជម្ងឺអេដស៍ និងជម្ងឺផ្សេងទៀត ជាពិសេសចំពោះគ្រួសារនានា តាមរយៈការផ្តល់ព័ត៌មាន និងកិច្ចប្រឹងប្រែងក្នុងវិស័យអប់រំ ។

### ៤.៣.៧ ការបញ្ចូលសមធម៌យេនឌ័រទៅក្នុងការអភិវឌ្ឍបៃតង

ដើម្បីកែលម្អសមធម៌នៃការអភិវឌ្ឍ ការបញ្ជ្រាបកិច្ចការសមធម៌យេនឌ័រទៅក្នុងកិច្ចផ្តួចផ្តើមអភិវឌ្ឍន៍បៃតង មានសារៈសំខាន់ណាស់ ដោយសារសមធម៌យេនឌ័រ គឺជាកិច្ចការសំខាន់មួយ ដែលត្រូវដោះស្រាយ ។ សព្វថ្ងៃនេះ សមធម៌យេនឌ័រ ត្រូវបានដាក់បញ្ចូលទៅក្នុងវិស័យសុខាភិបាល អប់រំ ការត្រួតពិនិត្យធនធានកសិកម្ម ការពង្រឹងអំណាចខាងសេដ្ឋកិច្ច-សង្គម និងនយោបាយ និងកិច្ចការពារខាងផ្លូវច្បាប់ ។ លើសពីនេះ គេគួរតែបញ្ចូលវិធានការជាក់លាក់ ទៅក្នុងកិច្ចសហការរវាងក្រសួងកិច្ចការនារី ជាមួយក្រសួងសុខាភិបាល សម្រាប់កិច្ចការសុខាភិបាល ជាមួយអប់រំយុវជន និងកីឡា សម្រាប់ការអប់រំ និងជាមួយ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងធនធានទឹក និងឧតុនិយម និងក្រសួងអភិវឌ្ឍន៍ជនបទ សម្រាប់កសិកម្ម និងការបង្កើនប្រាក់ចំណូល ដើម្បីកំណើនសេដ្ឋកិច្ច និងបង្កើតការងារធ្វើ ។

### ៤.៣.៨ ការប្រើប្រាស់ដី និងបរិស្ថានទីក្រុងដែលសមស្របតាមលក្ខខ័ណ្ឌធម្មជាតិ និង ផ្តល់សុខភាពល្អ

ការគ្រប់គ្រងសមស្របនូវធនធានដីធ្លី មានសារៈសំខាន់ណាស់ទាំងខាងផ្នែកសេដ្ឋកិច្ច និងបរិស្ថាន។ រដ្ឋាភិបាល គួរតែពិនិត្យមើលការប្រែប្រួលលើការប្រើប្រាស់ដី (ដោយគិតចាប់ពីការប្រែប្រួលពីដីព្រៃទៅជាដីកសិកម្ម ឬ ពីកសិដ្ឋានទៅជាទីក្រុង និងភាពមិនច្បាស់លាស់នៃកម្មសិទ្ធិ និងការអនុវត្តច្បាប់)។ ក្នុងបរិបទនេះ រាជរដ្ឋាភិបាល គួរផ្តោតការយកចិត្តទុកដាក់បន្ថែមទៀតលើការអនុវត្តច្បាប់ភូមិបាល អនុក្រឹត្យ និងយុទ្ធសាស្ត្រគ្រប់គ្រងដីធ្លីឱ្យមានប្រសិទ្ធិភាព ។ ជាក់ស្តែង កំណើនការលូតលាស់នៃទីក្រុង ដូចជាការអភិវឌ្ឍទីក្រុងយ៉ាងឆាប់រហ័ស និងកំណើនចំនួនទីក្រុង រួមចំណែកធ្វើឱ្យខូចខាតសេវាកម្មបរិស្ថាន។ ក្នុងន័យនេះ គួរតែពង្រីក និងជម្រុញឱ្យមានតំបន់ធម្មជាតិនៅចន្លោះទីក្រុងនៅតាមខេត្ត និងរាជធានីភ្នំពេញ ហើយប្រព័ន្ធគ្រប់គ្រងបរិស្ថានគួរតែពង្រឹងបន្ថែម (MoP, 2008)។ លើសពីនេះ ប្រព័ន្ធគ្រប់គ្រងសម្រាប់និរន្តរភាពបរិស្ថានទីក្រុង គួរត្រូវបានបង្កើតឡើង ដោយធ្វើការពិចារណាលើការប្រើប្រាស់ដីធ្លី ដែលជាចំណុចអាទិភាព។ យុទ្ធសាស្ត្រនៃការអភិវឌ្ឍនគួរតែត្រូវបានថែទាំ និងលើកទឹកចិត្ត ដើម្បីជម្រុញលទ្ធភាពទទួលបានទឹកស្អាត កសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត បង្កើតទីលានចាក់សម្រាមដែលមានលក្ខណៈសមស្របខាងបរិស្ថាន ជម្រុញការដឹកជញ្ជូនសាធារណៈ និងជម្រុញការដាំដើមឈើ រួមទាំងការពង្រីក និងការបង្កើនគុណភាពសួនច្បារ ព្រមទាំងមធ្យោបាយសម្រាប់ការលំហែកាយ ផ្សេងទៀត ។

លើសពីនេះ គួរឱ្យមានការដាក់កំហិតលើការបញ្ចេញឧស្ម័នពុលនៅតាមរោងចក្រធំៗ ដើម្បីកាត់បន្ថយការបញ្ចេញឧស្ម័នពុល ដូចជា ធូលី ស៊ុលហ្វួរ និងនីត្រូហ្សែនអុកស៊ីត ទន្ទឹមនឹងពាណិជ្ជកម្មខាងផ្នែកកាត់បន្ថយការបញ្ចេញផ្សែងពុលគួរតែត្រូវបានដាក់ឱ្យប្រើប្រាស់សម្រាប់ក្រុមហ៊ុនធំៗ ដើម្បីជម្រុញកិច្ចប្រឹងប្រែងដោយស្ម័គ្រចិត្ត ក្នុងការកាត់បន្ថយការបញ្ចេញកាបូន។ ទន្ទឹមនឹងនេះ រដ្ឋាភិបាល គួរពិចារណាដាក់ឱ្យប្រើប្រាស់យានយន្តដែលបញ្ចេញផ្សែងពុលតិច ដូចជា រថយន្តអ៊ីប្រ៊ីដ និងយានយន្តប្រើប្រាស់ឧស្ម័នធម្មជាតិ ទន្ទឹមនឹងការដាក់ឱ្យប្រើប្រាស់ទោចក្រយានយន្តអគ្គិសនី និងលើកទឹកចិត្តឱ្យអភិវឌ្ឍន៍មធ្យោបាយដឹកជញ្ជូន ដែលកាន់តែមានប្រសិទ្ធិភាព ថាមពល និង ដែលមិនសូវបញ្ចេញផ្សែងពុល។ នៅក្នុងកិច្ចផ្តួចផ្តើមទាំងនេះ ត្រូវផ្តល់អាទិភាពដល់ការជម្រុញឧស្សាហកម្ម ការងារ និង កំណើនសេដ្ឋកិច្ចនៅមូលដ្ឋាន។ រដ្ឋាភិបាលគួរលើកទឹកចិត្ត និងជម្រុញឱ្យមានការរៀបចំផែនការមេ សម្រាប់ការគ្រប់គ្រងបរិស្ថាន ដែលត្រូវអនុវត្តនៅទូទាំងប្រទេស សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចដោយចីរភាព។ គួរពិចារណាអំពីការដាក់ឱ្យប្រើប្រាស់ និងអនុវត្តបណ្តាញអេកូឡូស៊ី ដើម្បីដាក់តាំងពីប្រភេទសត្វ និងរុក្ខជាតិមកពីទីជនបទ ឬ តំបន់ជិតៗក្រុង ទៅតំបន់ទីក្រុងជាពិសេស នៅទីក្រុងភ្នំពេញ។ លើសពីនេះ គួរប្រើប្រាស់បណ្តាញតំបន់អេកូឡូស៊ីខុសៗគ្នា សម្រាប់ធ្វើការបកស្រាយ និងប្រៀបធៀបរវាងរចនាសម្ព័ន្ធជាក់ស្តែង នៃប្រព័ន្ធអេកូឡូស៊ីនៅនឹងកន្លែងណាមួយ ទន្ទឹមនឹងការប្រើប្រាស់ម៉ូដែល នៃបណ្តាញអេកូឡូស៊ីទាំងនោះ ដើម្បីពិនិត្យមើលឥទ្ធិពលនានានៃបណ្តាញនេះ។

### ៤.៣.៩ ការអភិវឌ្ឍសេដ្ឋកិច្ចបៃតង

ក្រុមហ៊ុននាំចេញនៅក្នុងប្រទេសកម្ពុជា ប្រឈមនឹងការលំបាកមួយចំនួន ក្នុងចំណោមវិស័យពីរនៃបរិស្ថានៈ

**១_និរន្តរភាពនៃផលិតផល ដែលបានពីធនធានធម្មជាតិ**

សហគ្រាសខ្នាតតូច និងមធ្យម ក្រុមផលិតករ និងអង្គការពាណិជ្ជកម្មសហគមន៍នៅកម្ពុជា ប្រឈមនឹងការលំបាកមួយចំនួននៅក្នុងការនាំចេញទៅផ្គត់ផ្គង់ទីផ្សារសេវាកម្មបរិស្ថាន។ ការលំបាកទាំងនោះរួមមាន កង្វះចំណេះដឹងអំពីផលិតកម្ម និងការចាត់ចែងខាងទីផ្សារ តម្លៃខ្ពស់សម្រាប់ការចំណាយអន្តរការនៅក្នុងការចាត់ចែងខាងទីផ្សារ ការចំណាយលើការគោរពតាមស្តង់ដារគុណភាព និងការធានាឱ្យមានការចូលរួមពីប្រទេសនានានៅក្នុងដំណើរការកំណត់ស្តង់ដារ។ ការប្រឈមទាំងនោះរួមមាន :

- ការផ្គត់ផ្គង់ដែលគ្មាននិរន្តរភាព និង/ឬ គ្មានភាពប្រកួតប្រជែង
- សមត្ថភាពទន់ខ្សោយក្នុងការកែច្នៃ និងការលក់ផលិតផល
- ការចំណាយខ្ពស់ក្នុងការពង្រឹងឱ្យមានការគោរពតាមស្តង់ដារគុណភាព
- ភាពទន់ខ្សោយនៃគោលនយោបាយ ក្នុងការទ្រទ្រង់វិស័យបរិស្ថាន
- កង្វះសម្លេងពីក្នុងចំណោមប្រទេសកំពុងអភិវឌ្ឍន៍ នៅក្នុងការកំណត់ស្តង់ដារបរិស្ថាន។

## ២.បច្ចេកវិទ្យា និងសេវាកម្មបរិស្ថាន

ទីផ្សារបច្ចេកវិទ្យា និងសេវាកម្មបរិស្ថាន ប្រឈមនឹងការលំបាកប្រហាក់ប្រហែលគ្នា ជាពិសេស ការលំបាកក្នុងការគោរពតាមស្តង់ដារអន្តរជាតិ ឧបសគ្គខាងផ្នែកពន្ធ និងផ្នែកមិនមែនពន្ធ ដូចជា ការចងក្រងជាឯកសារ និងការដាក់ស្លាកសញ្ញា ។

ក្រុមហ៊ុននាំចេញរបស់កម្ពុជាប្រឈមនឹងឧបសគ្គនានានៅក្នុងការធ្វើពាណិជ្ជកម្មខាងផ្នែកសេវាកម្ម ដូចមានចែងដោយGATS ដូចជា ការកំហិតលើភាគហ៊ុនសម្រាប់ការវិនិយោគដោយផ្ទាល់ពីបរទេស លក្ខខណ្ឌអំពីរយៈពេលស្នាក់នៅក្នុងប្រទេស និងលក្ខខណ្ឌនៃការចូលសញ្ជាតិ។ វិធានការទាំងនេះអាចជាឧបសគ្គ ចំពោះសមត្ថភាពរបស់អ្នកជំនាញវិជ្ជាជីវៈពីកម្ពុជា ក្នុងការផ្គត់ផ្គង់សេវាកម្មរបស់ខ្លួន។

ផែនទីបង្ហាញផ្លូវអភិវឌ្ឍន៍បៃតង នឹងធ្វើការដើម្បីសម្រេចគោលបំណងយុទ្ធសាស្ត្រនានា ពោលគឺ :

- ពង្រឹងភាពប្រកួតប្រជែងអន្តរជាតិ របស់សហគ្រាសកម្ពុជា ( នៅកម្រិតមីក្រូ)
- អភិវឌ្ឍន៍សមត្ថភាពរបស់អ្នកផ្តល់សេវាកម្មពាណិជ្ជកម្ម ដើម្បីគាំទ្រមុខជំនួញនានា ( នៅកម្រិតមធ្យម-មេសូ)
- គាំទ្រអ្នកកសាងគោលនយោបាយ នៅក្នុងការបញ្ចូលវិស័យជំនួញនៅក្នុងសេដ្ឋកិច្ចបៃតងពិភពលោក ( កម្រិតម៉ាក្រូ) ។

ដូច្នេះ គោលបំណងបឋមនៃផែនទីបង្ហាញផ្លូវនេះ នៅក្នុងវិស័យអភិវឌ្ឍន៍ពាណិជ្ជកម្ម គឺពង្រឹងភាពប្រកួតប្រជែងរបស់សហគ្រាសខ្នាតតូច និងមធ្យមនៅក្នុងប្រទេស ក្នុងការនាំចេញទំនិញ និងសេវាបរិស្ថានពីកម្ពុជា ។

កំណើនយ៉ាងឆាប់រហ័សនៃបរិមាណ និងប្រភេទសំណល់ ដែលរួមទាំង សំណល់ឧស្សាហកម្ម សំណល់អេឡិចត្រូនិក និងសំណល់ពីទីក្រុង ភាគច្រើនគឺដោយសារកំណើនសេដ្ឋកិច្ច ឧស្សាហូបនីយកម្ម និងកម្រិតកំណត់នៃការគ្រប់គ្រងសំណល់ ដែលតំណាងឱ្យកំណើនបញ្ហាទាំងសម្រាប់រដ្ឋាភិបាលនៅថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន។ កំណើនបរិមាណសំណល់ និងកំណើនគ្រោះថ្នាក់ ដែលបង្កដោយសំណល់ កំពុងបង្កគ្រោះថ្នាក់ធ្ងន់ធ្ងរមកលើបរិស្ថាន ធនធានធម្មជាតិ សុខភាពសាធារណៈ សេដ្ឋកិច្ចនៅមូលដ្ឋាន និង លក្ខខណ្ឌនៃការរស់នៅផងដែរ (UNEP, 2009)។ ដើម្បីលើកទឹកចិត្តឱ្យមានការអភិវឌ្ឍន៍សមស្រប រាជរដ្ឋាភិបាលកម្ពុជា អាចបញ្ចុះបញ្ចូលឱ្យមានប្រព័ន្ធទូទាត់បំណុល ដែលបំណុលអន្តរជាតិអាចនឹងទុកជានិរាករណ៍ ជាការដោះដូរជាមួយការអភិវឌ្ឍបៃតង។

រាជរដ្ឋាភិបាល គួរលើកទឹកចិត្ត និងសម្រួលឱ្យមានការអនុវត្តគម្រោងថាមពលស្អាត វិនិយោគលើបណ្តាញ "ឆ្លាតវៃ" និងគួរបន្តគាំទ្រដល់ការចែកចាយបច្ចេកវិទ្យាខ្នាតតូច សម្រាប់តំបន់គ្មានបណ្តាញអគ្គិសនី ជាពិសេស បច្ចេកវិទ្យាដែលបង្កើតការងារធ្វើ និងឱកាសសម្រាប់សេដ្ឋកិច្ចនៅមូលដ្ឋាន។ ការអនុវត្តបច្ចេកវិទ្យាផលិតកម្មស្អាត មានសារៈសំខាន់ជាទីបំផុត និងជាវិធីថ្មី១ ប្រកបដោយភាពឆ្នៃប្រឌិតក្នុងការគិតគូរអំពីផលិតផល និងដំណើរការទាក់ទងនឹងការរួមបញ្ចូលការវាយតម្លៃវដ្តផលិតផលទាំងមូល និងលំហូរសារធាតុសម្រាប់បង្កើតផលិតផល និងសេវាកម្មទាំងនោះ។ រដ្ឋាភិបាល គួរលើកទឹកចិត្តឱ្យមានឧស្សាកម្មបៃតង និងឧស្សាហកម្មតាមគោលការណ៍ធម្មជាតិ ដូចជាឧទ្យានបៃតង-ឧស្សាហកម្មដែលប្រើប្រាស់បច្ចេកវិទ្យាបៃតង និងជាពិសេស ថាមពលបៃតងដើម្បីកាត់បន្ថយឥទ្ធិពល អវិជ្ជមានមកលើបរិស្ថាន ជីវៈចម្រុះ និងសុខភាពប្រជាជន។ ផែនទីបង្ហាញផ្លូវនេះ នឹងធ្វើការដោះស្រាយ

គោលបំណងយុទ្ធសាស្ត្រនានា ដូចជា ការពង្រឹងភាពប្រកួតប្រជែងជាអន្តរជាតិរបស់សហគ្រាសកម្ពុជា អភិវឌ្ឍន៍សមត្ថភាព របស់ក្រុមហ៊ុនសេវាកម្មពាណិជ្ជកម្មដើម្បីគាំទ្រជំនួញ និងគាំទ្រអ្នកកសាងគោលនយោបាយនៅក្នុងការបញ្ចូលវិស័យជំនួញ ទៅក្នុងសេដ្ឋកិច្ចបៃតងពិភពលោក។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាល គួរតែបន្តជម្រុញ និង បញ្ចូលគោលនយោបាយស្តីពី ឧស្សាហកម្មបៃតង ទៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និង លើកទឹកចិត្តឱ្យមានការអនុវត្តគោលនយោបាយនេះ។ ប្រសិទ្ធិភាព នៃកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិគឺជាកង្វល់រួម ដូច្នេះ រដ្ឋាភិបាល គួរចាត់បញ្ចូលកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងហេតុប៉ះពាល់បរិស្ថាន ជាអាទិភាពមួយនៅក្នុងនៃការវិនិយោគ និងគោលនយោបាយរបស់រដ្ឋាភិបាល។ ការវាយតម្លៃ អំពីឥទ្ធិពលនៃនិរន្តរភាព និងនីតិវិធីសម្រាប់ពង្រឹងការគោរពច្បាប់ ក៏គួរត្រូវបានដាក់បញ្ចូលទៅក្នុងលក្ខខណ្ឌនៃការជ្រើសរើសគម្រោងដែរ។ អាស្រ័យហេតុនេះ ក្រសួងបរិស្ថាន គួរបន្តពង្រឹងបន្ថែមក្នុងការលើកផែនការ និងអនុវត្តគម្រោងនានា រួមទាំងការតាមដាន ពង្រឹងការអនុវត្ត និងជំរុញឱ្យមានការគោរពតាមច្បាប់បរិស្ថានដែលមានស្រាប់។

រដ្ឋាភិបាលក៏គួរតែពិចារណា និងជម្រុញឱ្យមានការអនុវត្តប្រព័ន្ធលើកទឹកចិត្តនៃការឧបត្ថម្ភធន ពន្ធ និងបទប្បញ្ញត្តិនានា ដែលលើកទឹកចិត្តឱ្យមានការអនុវត្តប្រកបដោយការទទួលខុសត្រូវតាមបទដ្ឋានបរិស្ថាន។ នៅក្នុងការដោះស្រាយបញ្ហានេះ រដ្ឋាភិបាល គួរតែលើកទឹកចិត្តឱ្យចេញច្បាប់ដែលតម្រូវឱ្យមានការគិតបញ្ចូលនូវផលប៉ះពាល់ ដែលបណ្តាលពីការខូចខាតខាងបរិស្ថាននៅក្នុងកិច្ចការទាំងនេះ។ ការធ្វើបែបនេះ នឹងជួយពង្រឹងការគ្រប់គ្រងសំណល់ និងវិស័យកែច្នៃសំណល់ឡើងវិញ ដើម្បីប្រែក្លាយទៅជាវិស័យជំនួញដែលផ្តល់ផលចំណេញខ្ពស់និងផ្តល់ការងារធ្វើយ៉ាងច្រើន ផ្តល់សេវាកម្មដែលអាចទុកចិត្តបាននិងមានសមត្ថភាពខ្ពស់ ក៏ដូចជា ផ្តល់លក្ខខណ្ឌការងារសមស្របដល់ប្រជាជន។ នៅក្នុងវិស័យនេះ គេគួរតែចែងឱ្យមានការចាត់ចែង ការផ្ទេរ ការរក្សាទុក និងការចោលសំណល់ដោយសុវត្ថិភាពនិងស្អាត និងជម្រុញគោលការណ៍ 3R ពោលគឺ កាត់បន្ថយ ប្រើប្រាស់ឡើងវិញនិងកែច្នៃឡើងវិញ។ នៅក្នុងការអនុវត្តគោលការណ៍ 3Rឱ្យមានប្រសិទ្ធិភាព នោះគឺមានយុទ្ធសាស្ត្រចំនួនបួនដែលត្រូវអនុវត្តន៍ រួមមាន ៖ កាត់បន្ថយបរិមាណសំណល់តាមរយៈការបង្កើតស្ថានីយ៍ដុតសម្រាម កាត់បន្ថយបរិមាណសំណល់ ដែលបញ្ជូនទៅស្ថានីយ៍ដុតសម្រាមតាមរយៈការកែច្នៃឡើងវិញ កាត់បន្ថយបរិមាណសំណល់ដែលបញ្ជូនទៅទីលានចោលសម្រាម និងការបន្ថយបរិមាណសំណល់ តាមរយៈការកាត់បន្ថយវត្ថុដែលត្រូវបោះចោល។ នៅក្នុងការចំណាយវិស័យសាធារណៈ ដើម្បីទទួលបានបច្ចេកវិទ្យាថាមពលកកើតឡើងវិញ ប្រព័ន្ធដឹកជញ្ជូនបៃតង(ស្អាត)និងអាគារដែលមានប្រសិទ្ធិភាពថាមពល រដ្ឋាភិបាល គួរតែលើកទឹកចិត្តឱ្យប្រើប្រាស់សម្ភារៈដែលបានពីការកែច្នៃឡើងវិញ និងថាមពលកកើតឡើងវិញ។ ជាងនេះទៅទៀត រដ្ឋាភិបាល គួរតែយកចិត្តទុកដាក់ឱ្យបានដូចគ្នា ទាក់ទងនឹងពន្ធអាករ លើសម្ភារៈ និងផលិតផល ដែលបានពីការផលិតដើមដំបូង និងពន្ធអាករប្រព្រឹត្តកម្មលើសម្ភារៈ និងផលិតផលដែលបានពីការកែច្នៃសំណល់។ លើសពីនេះ រដ្ឋាភិបាល គួរតែពិចារណាអំពីការអភិវឌ្ឍវិធានចម្រុះសម្រាប់កសាងផែនការ និងហិរញ្ញប្បទានសម្រាប់ការដឹកជញ្ជូន ជាពិសេស នៅតាមទីក្រុង ដោយផ្តល់អាទិភាពលើការវិនិយោគក្នុងវិស័យប្រសិទ្ធិភាពថាមពល និងការដឹកជញ្ជូន ដែលបញ្ចេញកាបូនតិចប្រកបដោយប្រសិទ្ធិភាពខ្ពស់លើការចំណាយ ដូចជា ផ្លូវដែក ប្រព័ន្ធរថយន្តក្រុងដែលធ្វើចរាចរបានឆាប់រហ័ស ប្រព័ន្ធដឹកជញ្ជូនសាធារណៈចម្រុះ និងមធ្យោបាយដឹកជញ្ជូនដែលមិនប្រើប្រាស់ម៉ាស៊ីន។

## ៤.៤. កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

ក្របខ័ណ្ឌយុទ្ធសាស្ត្រកំណែទម្រង់សម្រាប់វិមជ្ឈការ និងវិសហមជ្ឈការ (D&D) ត្រូវបានបង្កើតឡើងដោយរាជរដ្ឋាភិបាលកម្ពុជា។ ក្របខ័ណ្ឌនេះមានគោលដៅសម្រេចឱ្យបាននូវការអភិវឌ្ឍដោយចីរភាពនិងផ្អែកលើមូលដ្ឋានសេដ្ឋកិច្ចចម្រុះ និងពង្រឹងមូលដ្ឋានគ្រឹះសេដ្ឋកិច្ចរស់រវើកនៅមូលដ្ឋាន សម្រាប់ពលរដ្ឋគ្រប់រូប ដើម្បីផ្តល់ឱកាសស្មើគ្នាក្នុងការចូលរួមការអភិវឌ្ឍនៅមូលដ្ឋាន ការគ្រប់គ្រងធនធានធម្មជាតិដោយប្រសិទ្ធិភាព និងផ្តល់សេវាកម្មសាធារណ ដែលមានគុណភាពក្នុងការបំពេញតាមតម្រូវការរបស់ពលរដ្ឋ និងកែលម្អការចិញ្ចឹមជីវិតរបស់ពួកគេ (MoI, 2005)។ កំណែទម្រង់នេះផ្តល់ឱ្យក្រុមប្រឹក្សាឃុំ-សង្កាត់ ក្នុងការកសាងផែនការអភិវឌ្ឍន៍ និងគ្រប់គ្រងលើការសាងសង់ផ្លូវ ការជួសជុលសាលារៀន និងការបង្កើតហេដ្ឋារចនាសម្ព័ន្ធអនាម័យ។ នៅក្នុងមុខនាទីនេះ ក្រសួងមហាផ្ទៃ បានបង្កើតផែនការសកម្មភាព ដែលណែនាំដល់អាជ្ញាធរខេត្ត-ក្រុង បញ្ឈប់ការទន្ទ្រានយកដី ការរានឆ្ការព្រៃឈើ និងការបំពុល។ យុទ្ធសាស្ត្រចំបង៧ និងកម្មវិធីកែទម្រង់ រួមមាន កម្មវិធីវិនិយោគសាធារណៈ (PIP) ដែលនឹងបន្សុីថវិកាជាតិប្រចាំឆ្នាំដើម្បីសម្រេចបានចំណុចដៅនានា ដែលមានចែងនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (NSDP) ដើម្បីបង្កើនការទទួលខុសត្រូវលើការអភិវឌ្ឍសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ។ កម្មវិធីកំណែទម្រង់លើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ អាចកែលម្អចំណងទាក់ទងរវាងគោលនយោបាយអាទិភាពនានា ការកសាង និងអនុវត្តផែនការថវិកា ការបញ្ចូលគណនេយ្យភាព និងពិនិត្យមើលដំណើរការទាំងខាងហិរញ្ញវត្ថុ និងការអនុវត្ត ក៏ដូចជា កែលម្អការបង់ថ្លៃ និងការគ្រប់គ្រងសេវាកម្មស៊ីវិលផងដែរ (MoI, 2005)។

ក្នុងន័យនេះ ក្របខ័ណ្ឌយុទ្ធសាស្ត្រកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ មានសារៈសំខាន់ណាស់សម្រាប់លើកកំពស់ និងបែងចែកការអភិវឌ្ឍបៃតងដល់ថ្នាក់ខេត្ត។ ទោះជាយ៉ាងណាក៏ដោយ ការបង្កើត និងអនុវត្តគោលនយោបាយប្រកបដោយប្រសិទ្ធិភាព ទាមទារឱ្យមានការពិចារណាដោយប្រុងប្រយ័ត្នលើបរិយាកាសនៃការអនុវត្តនៅគ្រប់លំដាប់ថ្នាក់នៃអភិបាលកិច្ច។ តួនាទីនិងការទទួលខុសត្រូវនៅថ្នាក់កណ្តាល ខេត្ត ស្រុក ឃុំ គឺការផ្តល់សេវាកម្មដល់ប្រជាពលរដ្ឋ និងផ្តល់សិទ្ធិ និងតួនាទីដល់សហគមន៍ជនជាតិដើមភាគតិច លើការគ្រប់គ្រងព្រៃឈើ (DANIDA, 2006)។ ក្រៅពីនេះ កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ របស់រាជរដ្ឋាភិបាលកម្ពុជា គូសបញ្ជាក់អំពីមូលដ្ឋានគ្រឹះនៃរដ្ឋាភិបាលតាមបែបប្រជាធិបតេយ្យ កំណែទម្រង់ស្ថាប័ន និងកែលម្អការផ្តល់សេវា។ ដូច្នេះ កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ អាចមាននាទីជាកត្តាជម្រុញឱ្យមាន ការបញ្ជ្រាបនូវការអភិវឌ្ឍបៃតងដោយនិរន្តរភាពនៅថ្នាក់ក្រោមជាតិ សម្រាប់កាត់បន្ថយភាពក្រីក្រ និងការចិញ្ចឹមជីវិត។ អាស្រ័យហេតុនេះ ដំណើរការល្អខាងស្ថាប័ន និងការអនុវត្តបទប្បញ្ញត្តិឱ្យមានប្រសិទ្ធិភាព គឺជាកត្តាសំខាន់ និងចាំបាច់ក្នុងការសម្រេចបាននូវគោលដៅ និង លទ្ធផលនៃការអភិវឌ្ឍបៃតង។

# ៥. យន្តការអនុវត្តសម្រាប់ការអភិវឌ្ឍបៃតង

## ៥.១ បរិយាកាសអំណោយផលសម្រាប់ផែនទីបង្ហាញផ្លូវអភិវឌ្ឍន៍បៃតងជាតិ

ក្រោយពីការពិគ្រោះយោបល់ជាមួយក្រសួងពាក់ព័ន្ធនានា សំណើជាច្រើនត្រូវបានលើកឡើង ដូចជា៖ ១) ឯកសារណែនាំសម្រាប់ការបណ្តុះបណ្តាលអំពីការអភិវឌ្ឍបៃតង សម្រាប់ដាក់ស្នើជូនប្រធានក្រសួងស្ថាប័ន ដើម្បីគូសបញ្ជាក់អំពីសារៈសំខាន់នៃការអភិវឌ្ឍបៃតង និងដើម្បីបង្កើនការយកចិត្តទុកដាក់ពីថ្នាក់ដឹកនាំដែលជាអ្នកសម្រេច។ ២) យុទ្ធនាការបង្កើនការយល់ដឹង និងការអភិវឌ្ឍសមត្ថភាពនៅថ្នាក់ក្រោមជាតិ ដែលត្រូវអនុវត្តជាប្រចាំ និងជាបន្តបន្ទាប់ដើម្បីបង្កើនការយល់ដឹងអំពីបញ្ហានានា ដែលទាក់ទងជាមួយការអភិវឌ្ឍបៃតង។ ជាងនេះទៅទៀត គួរតែរៀបចំអនុក្រឹត្យស្តីពីការអភិវឌ្ឍបៃតង ដើម្បីឱ្យមានក្របខ័ណ្ឌច្បាប់រួមមួយ។

## ៥.២ កិច្ចសហប្រតិបត្តិការរវាងអ្នកពាក់ព័ន្ធនានា

ក្រសួងបរិស្ថាន និងក្រសួងពាក់ព័ន្ធ មានតួនាទីសម្របសម្រួល និងតួនាទីអនុវត្តផែនទីបង្ហាញផ្លូវអភិវឌ្ឍន៍បៃតងនេះ។ លេខាធិការដ្ឋានអភិវឌ្ឍន៍បៃតង ដែលមានទីតាំងនៅក្នុងទីស្តីការក្រសួងបរិស្ថាន គួរធ្វើការឱ្យបានជិតស្និទ្ធជាមួយក្រសួងពាក់ព័ន្ធអាស្រ័យតាមកិច្ចការដែលពាក់ព័ន្ធជាអន្តរវិស័យនៅក្នុងគម្រោងនានា ដូចមានចែងក្នុងផែនទីបង្ហាញផ្លូវនេះ និងដើម្បីធានាឱ្យមានការអភិវឌ្ឍនៅទីជនបទមានដំណើរការល្អ ក្រសួងមហាផ្ទៃ គួរចូលរួមក្នុងការបញ្ជ្រាប និងត្រួតពិនិត្យការអនុវត្តកិច្ចការ/គម្រោងនៅថ្នាក់ក្រោមជាតិ តាមរយៈការបង្កើតមណ្ឌលអភិវឌ្ឍន៍បៃតងនៅថ្នាក់ក្រោមជាតិ។

លើសពីនេះ ម្ចាស់ជំនួយ/ស្ថាប័នអន្តរជាតិនានា ក៏មានសក្តានុពលក្នុងតួនាទីផ្តល់ជំនួយហិរញ្ញវត្ថុ នៅពេលដែលគម្រោង និងសកម្មភាពជាក់ស្តែងត្រូវបានលើកស្នើឡើង ដូចមាននៅក្នុងផែនទីបង្ហាញផ្លូវនេះ(ឧបសម្ព័ន្ធ១)។ ក្នុងបរិបទនេះ រាជរដ្ឋាភិបាលកម្ពុជាត្រូវផ្សព្វផ្សាយគោលគំនិតអំពីការអភិវឌ្ឍបៃតងដល់ម្ចាស់ជំនួយនានា ដើម្បីលើកទឹកចិត្តឱ្យមានការចូលរួមពីអ្នកពាក់ព័ន្ធលើកិច្ចសហប្រតិបត្តិការ និងការសហការគ្នា។ ប្រការសំខាន់គឺត្រូវធ្វើអត្តសញ្ញាណអ្នកពាក់ព័ន្ធនានា ដែលរួមទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សហគមន៍អ្នកវិទ្យាសាស្ត្រ អង្គការមិនមែនរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល ដើម្បីបង្កើតការគាំទ្ររឹងមាំ និងទូលំទូលាយ។ លើសពីនេះ គេចាំបាច់ត្រូវតែផ្សព្វផ្សាយព័ត៌មាន ដែលអាចបង្កើតឱ្យមានការគាំទ្រ និងដើម្បីអនុវត្តដំណើរការ ដែលមានតម្លាភាពសម្រាប់ការចូលរួមពីសាធារណជន។ នៅទីបំផុត ការពិនិត្យតាមដាន និងវាយតម្លៃលើការគ្រប់គ្រងការអភិវឌ្ឍបៃតង ក៏ជាកិច្ចការសំខាន់មួយ ដែលអាចធ្វើឡើងតាមរយៈស្ថាប័ននានា ដោយត្រូវកំណត់ចំណុចដៅ និងគោលដៅជាក់លាក់ទាក់ទងនឹងសកម្មភាពអភិវឌ្ឍន៍បៃតង។

## ៥.៣ ការសម្របសម្រួលលើការអភិវឌ្ឍបៃតង ដោយប្រើប្រាស់ក្របខ័ណ្ឌវាយតម្លៃនិរន្តរភាពចម្រុះ

ការធ្វើអត្ថសញ្ញាណថាតើ "ការអភិវឌ្ឍបៃតង" មានន័យបែបណាសម្រាប់អ្នកពាក់ព័ន្ធនៅកម្ពុជា គឺទាមទារឱ្យមានដំណើរការទូលំទូលាយ រយៈពេលវែង និងកាន់តែមានលក្ខណៈជាយុទ្ធសាស្ត្រ ដែលគូសបញ្ជាក់អំពីការរៀនសូត្រ អំពីទស្សនទាន និងលទ្ធផលជាបន្តបន្ទាប់។ កង្វះការសម្របសម្រួលរវាងគោលនយោបាយតាមវិស័យ ក៏ដូចជាគោលនយោបាយដែលពុំបានចែងសមស្របតាមលំដាប់លំដោយត្រឹមត្រូវ និងពុំទាក់ទងគ្នា អាចធ្វើឱ្យការអភិវឌ្ឍសេដ្ឋកិច្ចបៃតងមិនអាចសម្រេចទៅបានឡើយ។ អាស្រ័យហេតុនេះ ប្រការសំខាន់គឺផែនទីបង្ហាញផ្លូវនេះត្រូវមានការបន្សុីជាមួយផែនការ និងអាទិភាព ដែលបានលើកឡើងពីខាងដើម ដូចជាយុទ្ធសាស្ត្រចតុកោណ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងគោលដៅរួមនៃគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា។ ដើម្បីធានាឱ្យមានការបញ្ចូលផែនទីបង្ហាញផ្លូវជាមួយផែនការអភិវឌ្ឍន៍រួម ប្រការសំខាន់បំផុតគឺត្រូវតែមានគោលដៅបន្សុីគ្នាជាមួយប្រការនានា ដែលមានចែងនៅក្នុងយុទ្ធសាស្ត្រចតុកោណ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងការប្រឈមនានា ដែលទាក់ទងនឹងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា។ លើសពីនេះ ផែនទីបង្ហាញផ្លូវនេះមានគោលដៅបង្រួមគ្នានូវអាទិភាពនានាសម្រាប់អភិវឌ្ឍន៍ និង ការលូតលាស់ជាមួយអាទិភាពនានា ដែលធានានិរន្តរភាពបរិស្ថាន។ ប្រការនេះនឹងរួមចំណែកជាវិជ្ជមាននៅក្នុងការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ដោយសារការអនុវត្តឧបករណ៍ និងគម្រោងអភិវឌ្ឍន៍បៃតងអាចជួយគាំពារមូលធនមនុស្ស និងធនធានធម្មជាតិ និងបង្កើនភាពធន់ទល់នឹងឥទ្ធិពលអវិជ្ជមាននានាពីការប្រែប្រួលអាកាសធាតុ និង វិបត្តិសេដ្ឋកិច្ចពិភពលោក។ អន្តរាគមន៍មួយចំនួនដែលមានចែងនៅក្នុងផែនទីបង្ហាញផ្លូវនេះ ដែលរួមទាំងភូមិបៃតង និរន្តរភាពធនធានទឹក និងព្រៃឈើ និងថាមពលកកើតឡើងវិញ សុទ្ធតែមានសក្តានុពលដើម្បីកែលម្អជម្រើសសម្រាប់ការចិញ្ចឹមជីវិតរបស់ជនក្រីក្រ តាមរយៈការរួមចំណែកក្នុងការបង្កើតឱកាស ដូចជា តាមរយៈការជម្រុញលក្ខណៈអន្តរវិស័យនៅក្នុងការអនុវត្តកសិកម្មសរីរាង្គ និងការផលិតជីវឧស្ម័ន។

វិស័យជាគោលដៅនៃយុទ្ធសាស្ត្រចតុកោណ មានបង្ហាញនៅក្នុងការបង្កើតសកម្មភាពដែលមាននិរន្តរភាពបរិស្ថាន និងអន្តរាគមន៍នានាក្រោមរូបភាពដូចតទៅ : ផលិតភាពកសិកម្ម អាចជម្រុញ និងរក្សាបាននៅក្នុងរយៈពេលវែង ប្រសិនបើមានការជម្រុញកសិកម្មសរីរាង្គ ដើម្បីរារាំងការខ្សោះជីជាតិដីដាំដំណាំ។ ការបង្កើនភាពចម្រុះវិស័យនានានៅក្នុងសេដ្ឋកិច្ច អាចធ្វើទៅបានតាមរយៈកំណើនការកសាងសមត្ថភាព ការអប់រំនិងបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ និងកិច្ចផ្តួចផ្តើមនានាផ្សេងទៀតដែលអនុវត្តដោយក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងអប់រំយុវជន និងកីឡា។ល។ ប្រសិនបើមានការជម្រុញកសិកម្មសរីរាង្គនៅតាមជនបទ និងអាចភ្ជាប់ការជម្រុញជាមួយទីផ្សារធំៗ កម្ពុជាអាចមានសក្តានុពលក្នុងការក្លាយជាមជ្ឈមណ្ឌលផលិតស្រូវសរីរាង្គនៅអាស៊ីអាគ្នេយ៍។ លំហូរមូលធនបែបនេះ អាចជម្រុញឱ្យមានកំណើនវិស័យឯកជន បង្កើតឱកាសសម្រាប់ការងារធ្វើជាបន្ថែម និងផលប្រយោជន៍ទាំងមូលពីការដាក់លក់នៅក្នុងទីផ្សារអន្តរជាតិ និងភាពប្រកួតប្រជែងនៃផលិតផលពីកម្ពុជា។ ជាទូទៅ ផែនទីបង្ហាញផ្លូវនេះ មិនលើកស្នើឱ្យមានគោលដៅអភិវឌ្ឍន៍ផ្សេងទៀតនោះទេ ក្រៅពីអ្វីដែលមានចែងនៅក្នុងយុទ្ធសាស្ត្រចតុកោណ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ប៉ុន្តែជាការព្យាយាមដើម្បីគូសបញ្ជាក់អំពីទិដ្ឋភាពបរិស្ថាននិងសង្គម នៅក្នុងវិស័យគោលដៅនានា ជាមួយនឹងការបន្ថែមនូវគោលការណ៍ណែនាំ និងអន្តរាគមន៍ជាក់ស្តែងពីអ្នកពាក់ពន្ធ័ទាំងអស់។ នៅទីបំផុត ផែនទីបង្ហាញផ្លូវនេះ ប្រើប្រាស់វិធាន

គ្រប់ជ្រុងជ្រោយនៃការអភិវឌ្ឍបៃតង សម្រាប់វិស័យជាគោលដៅទាំងនេះ ដើម្បីដោះស្រាយការប្រឈមនានាជាលក្ខណៈអន្តរវិស័យ ឆ្ពោះទៅកែលម្អលទ្ធភាពក្នុងការទទួលបានសេវាកម្មចាំបាច់នានា។

នៅក្នុងករណីណាក៏ដោយ ការអភិវឌ្ឍសេដ្ឋកិច្ចបៃតង នឹងទាមទារឱ្យមានភាពម្ចាស់ការរឹងមាំលើគោលនយោបាយកំណែទម្រង់ និងកិច្ចសហប្រតិបត្តិការជាប់ជាប្រចាំរវាងក្រសួងនានា នៅទូទាំងដំណាក់កាលនានានៃវដ្តកំណែទម្រង់នេះ ដែលនេះជាកិច្ចការដ៏លំបាក។ ដើម្បីជួយសម្រួលដល់កិច្ចប្រឹងប្រែងទាំងនេះ ក្រុមការងារបច្ចេកទេសអន្តរក្រសួងស្តីពីការអភិវឌ្ឍបៃតង ត្រូវបានបង្កើតឡើង ដោយមានការទទួលខុសត្រូវចំបងៗនៅក្នុងដំណើរការរៀបចំនិងត្រួតពិនិត្យការបង្កើតគម្រោង គោលនយោបាយនិងអន្តរាគមន៍អភិវឌ្ឍន៍បៃតង។ ផែនទីបង្ហាញផ្លូវនេះ គឺជាឯកសារមួយដែលគូសបញ្ជាក់អំពីលទ្ធភាពដំបូងៗសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចបៃតង។ វិធី និង ឧបករណ៍នានាសម្រាប់គម្រោងវាយតម្លៃនិរន្តរភាពចម្រុះ (MATISSE) "ការវាយតម្លៃនិរន្តរភាពចម្រុះ (ISA) គឺជាដំណើរការកំណត់វិសាលភាព ការបង្កើតចក្ខុវិស័យ ការដកស្រង់បទពិសោធន៍ និងការរៀនសូត្រ តាមបែបផែននៃការចូលរួម ដែលមានលក្ខណៈជាវង្វិលជុំ ដែលនឹងនាំឱ្យមានការបង្កើត និងអនុវត្តគោលដៅរួមនៃនិរន្តរភាព សម្រាប់បរិបទជាក់លាក់មួយតាមវិធីចម្រុះ ដើម្បីស្វែងរកដំណោះស្រាយចំពោះបញ្ហាលំបាកៗនៅក្នុងការអភិវឌ្ឍដោយចីរភាព"[5] ។ ការវាយតម្លៃនិរន្តរភាពចម្រុះ អាចមាននាទីជាបរិធានដ៏មានតម្លៃសម្រាប់រដ្ឋាភិបាល និងអ្នកកសាងគោលនយោបាយនានា នៅក្នុងការប្រឹងប្រែងអនុវត្តនិងសម្របសម្រួលគោលនយោបាយអភិវឌ្ឍន៍បៃតងឱ្យមានប្រសិទ្ធិភាព ហើយដំណើរការនេះបានគូសបញ្ជាក់អំពីជំហានចំបងៗ ដែលភាគច្រើនត្រូវអនុវត្តជាប់ជាបន្តពីសកម្មភាពមួយទៅសកម្មភាពមួយទៀត។

### ៥.៣.១ ដំណាក់កាលកំណត់វិសាលភាព

គោលបំណងគន្លឹះនៅក្នុងជំហាននេះគឺមានបំណងដើម្បីធ្វើអត្តសញ្ញាណ កំណត់និយមន័យ និងស្វែងយល់ឱ្យបានច្បាស់លាស់អំពីបញ្ហាលំបាកៗ ដែលជាផ្នែកធ្វើមិនឱ្យមាននិរន្តរភាព ដូចជា ការបាត់បង់ធនធានធម្មជាតិ បញ្ហានៃភាពគ្មានការងារធ្វើ និងដំណើរការមិនល្អនៃសេដ្ឋកិច្ច ហើយការទទួលស្គាល់អំពីប្រភពដើមនៃបញ្ហា ដូចជាផ្លាកសញ្ញាមិនត្រឹមត្រូវ អំពីតម្លៃទំនិញដោយសារការឧបត្ថម្ភធនមិនត្រឹមត្រូវ ឬភាពទន់ខ្សោយនៃការញ្ញា និងការត្រួតពិនិត្យ ក៏មានសារៈសំខាន់ដែរនៅក្នុងដំណាក់កាលនេះ។ ទន្ទឹមនឹងនេះ គេត្រូវធ្វើអត្តសញ្ញាណអ្នកពាក់ព័ន្ធនានា និងត្រូវធ្វើឱ្យអ្នកទាំងនោះបានចូលរួម ហើយគេត្រូវបង្កើត និងឯកភាពគ្នាលើផែនទីបង្ហាញផ្លូវមួយសម្រាប់ការអភិវឌ្ឍបៃតង ដែលផ្អែកលើបញ្ហាជាក់លាក់នៅក្នុងប្រទេស។ ការប្រមូលទិន្នន័យសមស្របអំពីបញ្ហានានា និងឥទ្ធិពលនៃបញ្ហាទាំងនោះមកលើអ្នកពាក់ព័ន្ធនានា នឹងមានសារៈសំខាន់ណាស់សម្រាប់ទៅអនាគត នៅពេលដែលមានការកៀងគរឱ្យមានការគាំទ្រពីសាធារណជន។ នៅក្រោយបញ្ចប់វដ្តនៃការវាយតម្លៃនិរន្តរភាពចម្រុះ គេត្រូវពិនិត្យមើលបញ្ហា និងការប្រឈមនានាឡើងវិញ ដើម្បីបង្ហាញអំពីស្ថានភាពនៃការរីកចម្រើន និង ធ្វើអត្តសញ្ញាណអ្នកពាក់ព័ន្ធនានា ដើម្បីធ្វើឱ្យសមស្របនៅក្នុងបរិបទថ្មីមួយ។

[5] http://www.matisse-project.net/projectcomm/index.php?id=833

### ៥.៣.២ ដំណាក់កាលបង្កើតចក្ខុវិស័យ

ការឈានចូលក្នុងដំណាក់កាលនេះ ជាដំបូងអ្នកពាក់ព័ន្ធនានាត្រូវបង្កើតចក្ខុវិស័យអំពីថាតើការអភិវឌ្ឍបៃតង និងនិរន្តរភាពមានន័យបែបណានៅក្នុងបរិបទជាក់លាក់សម្រាប់ប្រទេសរបស់ខ្លួន។ ការធ្វើអត្តសញ្ញាណចក្ខុវិស័យនៃការប្រឈមនានា ចំពោះនិរន្តរភាព និងការអភិវឌ្ឍបៃតង ទាមទារឱ្យមានការវាយតម្លៃតាមបែបផែននៃការចូលរួមខុស១គ្នា។ ស្របជាមួយវិធានអំពីការចិញ្ចឹមជីវិតដោយនិរន្តរភាព(SLA) ដូចដែល ESCAP បានផ្សព្វផ្សាយ កង្វល់អំពីភាពងាយរងគ្រោះរបស់ស្ត្រី និងបុរស (រួមទាំងជនក្រីក្រផងនោះ) ក៏គួរតែត្រូវបានដាក់បញ្ចូល។ ដោយផ្អែកលើកិច្ចព្រមព្រៀងទាំងនេះ ដំណាក់កាលបង្កើតចក្ខុវិស័យ ពាក់ព័ន្ធនឹងការបង្កើតផែនទីបង្ហាញផ្លូវ ដែលមានយុទ្ធសាស្ត្រសម្រាប់រយៈពេលវែង និងគ្រប់ជ្រុងជ្រោយ ដើម្បីសម្រេចគោលដៅអភិវឌ្ឍន៍បៃតង និងនិរន្តរភាព ព្រមទាំងជម្រើសនានាសម្រាប់ការដាក់ឱ្យអនុវត្តជាបណ្តើរនូវពន្ធបៃតង និងកំណែទម្រង់ថវិកា(GTBR) និងបរិធានផ្សេងទៀត ដែលមិនផ្អែកលើទីផ្សារ(ដូចជាការដាក់ស្លាកសញ្ញាបៃតង) គួរត្រូវបានយកចិត្តទុកដាក់។ ចក្ខុវិស័យនេះ គួរតែគ្របដណ្តប់កត្តាជាច្រើនទៀត រួមទាំង សេណារីយ៉ូ "អនុវត្តតាមធម្មតា" និងការអភិវឌ្ឍបៃតង ហើយនៅក្នុងសំណើគោលនយោបាយរយៈពេលខ្លី គេគួរតែធ្វើឱ្យមាន តុល្យភាពរវាងប្រសិទ្ធិភាពខ្ពស់ខាងការចំណាយ សមធម៌ និងលទ្ធភាពក្នុងការអនុវត្តគោលនយោបាយ។

### ៥.៣.៣ ដំណាក់កាលដកស្រង់បទពិសោធន៍

ជំហាននេះផ្តោតលើការប្រើប្រាស់គោលការណ៍"ការវាយតម្លៃនិរន្តរភាពចម្រុះ"ដើម្បីវិភាគលទ្ធភាព សង្គតិភាពនិងនិរន្តរភាពនៅក្នុងចក្ខុវិស័យ ជាពិសេសកត្តានានា ដែលជម្រុញឱ្យមានការអភិវឌ្ឍជាក់ស្តែងទៅតាមលំនាំខុស១គ្នា។ នេះជាដំណាក់កាល ដែលត្រូវអនុវត្តគោលនយោបាយនានា ដើម្បីឈានទៅសម្រេចគោលដៅដែលបានកំណត់នៅក្នុងដំណាក់កាលកំណត់ចក្ខុវិស័យពីខាងដើម។ វិភាគទានពីអ្នកពាក់ព័ន្ធនានា អាចជាលក្ខណៈវិនិច្ឆ័យមួយសម្រាប់កំណត់អំពីថាតើ គោលការណ៍ណាមួយដែលមានលក្ខណៈសមស្របជាងគេបំផុត។ ទោះជាយ៉ាងណាក៏ដោយ ដំណើរការដែលបង្ហាញពីគុណភាព និងគោលការណ៍ដែលបង្ហាញពីបរិមាណ (ដូចជាម៉ូដែលនៃប្រព័ន្ធ និងប្រព័ន្ធរងនៃការអភិវឌ្ឍន៍) អាចមានលក្ខណៈសមស្របសម្រាប់ប្រើប្រាស់ជាលក្ខណៈវិនិច្ឆ័យ។ សមាសភាគខាងបរិមាណមានសារៈសំខាន់ ជាពិសេស សម្រាប់វាយតម្លៃប្រព័ន្ធអេកូឡូស៊ី ក៏ដូចជាសម្រាប់វាយតម្លៃអំពីបន្ទុកពន្ធ និងបន្ទុកនៃការឧបត្ថម្ភធនមកលើជនក្រីក្រ។

### ៥.៣.៤ ដំណាក់កាលសិក្សាស្វែងយល់

ការចងក្រងជា "មេរៀន" ដែលជាបទពិសោធន៍ពីមុនមក ពីសកម្មភាពតាមដាន និងវាយតម្លៃ មានសារៈសំខាន់ណាស់សម្រាប់កែតម្រូវ និងកែលម្អចក្ខុវិស័យសម្រាប់ការអភិវឌ្ឍបៃតង។ ប្រការទាំងនេះនឹងបញ្ចូលទៅក្នុងដំណាក់កាលដំបូង (ដំណាក់កាលកំណត់វិសាលភាព) នៅក្នុងវដ្ត "ការវាយតម្លៃនិរន្តរភាពចម្រុះ" ខាងមុខ។ មេរៀនទាំងនោះក៏មានសារៈសំខាន់សម្រាប់គូសបញ្ជាក់អំពីថាតើ ការអនុវត្តគោលនយោបាយនានា នាំទៅរកការសម្រេចគោលដៅ និងគោលបំណង ដែលបានគ្រោងទុកដែរឬទេ

នៅក្នុងអន្តរកាលឈានទៅរកនិរន្តរភាពនៃការអភិវឌ្ឍ ហើយគោលនយោបាយទាំងនេះអាចបានបង្កឱ្យមានលទ្ធផល ដែលមិនបានគ្រោងទុក និងដែលត្រូវតែកែតម្រូវឱ្យបានល្អក្នុងពេលនោះ។ ការបង្ហាញព័ត៌មានបានទូលំទូលាយ អំពីលទ្ធផលវិជ្ជមាន ដែលទទួលបាននៅក្នុងវដ្ត"ការវាយតម្លៃនិរន្តរភាពចម្រុះ" ដំបូងដូចជា កំណែលម្អគុណភាពបរិស្ថាន ឬ ការបង្កើតវិស័យការងារបៃតង) គឺជាវិធីមួយសម្រាប់គៀងគរឱ្យមានការគាំទ្រដល់ដំណើរការនេះសម្រាប់រយៈពេលវែង។




## ៥.៣.៥ ក្របខ័ណ្ឌអនុវត្តន៍ផែនទីបង្ហាញផ្លូវការអភិវឌ្ឍបៃតងនាពេលអនាគត

ក្របខ័ណ្ឌគោលនយោបាយ ផែនការ និងការអនុវត្ត (PPIF) អាចជួយរៀបចំផែនការ និងកំណត់វិសាលភាពនៃគំរោង និងកម្មវិធី និងតាមដានទូវភាពរីកចំរើននៃសំណើបទអន្តរាគមន៍នៅតាមបណ្តាញវិបសាយ ។ ក្របខ័ណ្ឌគោលនយោបាយ ផែនការ និងការអនុវត្តអាចជាដ្យាក្រាម និងចក្ខុវិស័យដើម្បីបង្ហាញទំនាក់ទំនងរវាងគោលនយោបាយ គោលបំណង និង គំរោង ។ ប្រការនេះអាចបង្ហាញនូវអន្តរទំនាក់ទំនង និងជំនួយក្នុងការកំណត់បង្ហាញភ្នាក់ងារអនុវត្ត និងការផ្តល់អាទិភាពលើគំរោង ឬកម្មវិធី ។ ជាងនេះទៅទៀតក្របខ័ណ្ឌនេះនឹងបញ្ជាក់ច្បាស់នូវការផ្សារភ្ជាប់គ្នាទៅនឹងផែនការអភិវឌ្ឍន៍ជាតិ (២០០៦-២០១០) និងបច្ចុប្បន្នភាព (២០០៩ - ២០១៣) យុទ្ធសាស្ត្រចតុកោណដំណាក់ទី២ ផែនទីបង្ហាញផ្លូវអភិវឌ្ឍន៍បៃតងជាតិ ចំណុចសំខាន់ទាំង៧នៃផែនទីបង្ហាញផ្លូវ និង គំនិតផ្តួចផ្តើមដែលមានស្រាប់ និងការតាមដានការរីកចំរើននានា ព្រមទាំងសមិទ្ធិផលផ្សេងៗទៀត ។

ការអនុវត្តរួមមានៈ

១. អាចធ្វើអោយមានការផ្លាស់ប្តូរគោលនយោបាយ រឺគោលបំណង ដែលត្រូវបានវាយតំលៃផលប៉ះពាល់គំរោង ( ផលប៉ះពាល់គំរោងលើការផ្លាស់ប្តូរគោលនយោបាយ រឺគោលបំណងចំពោះសមិទ្ធិផលគំរោង)

២. ផ្តល់ការគ្រប់គ្រង និងផែនការគំរោង និងសមិទ្ធិផល ដែលត្រូវតាមដាន និងរក្សាទុក ដូចមានចែងក្នុងការវាយតម្លៃនិរន្តរភាពចម្រុះ (វិសាលភាពការបង្កើតចក្ខុវិស័យ ការដកស្រង់បទពិសោធន៍ និងការរៀនសូត្រ)

៣. អាចរៀនសូត្រពីបណ្តាប្រទេសជុំវិញពិភពលោក ដែលអាចយកមកអនុវត្តន៏បាន

៤.បញ្ចូលក្របខ័ណ្ឌការគ្រប់គ្រងគំរោង ដើម្បីអាចអោយប្រើប្រាស់បានល្អបំផុតនូវធនធាន ដែលមានកំរិត ដើម្បីសំរេចបាន

គោលដៅសំខាន់ៗ **(Seed objectives)** និង

៥. កំណត់កម្រិតម៉ាក្រូ-មីក្រូនូវធនធានចាំបាច់ (រួមមានធនធានមនុស្ស និងហិរញ្ញវត្ថុ) ការរីកចំរើននៃគំរោង គោលដៅ និងសមិទ្ធិផលនៃគោលនយោបាយ ។

## ក្របខ័ណ្ឌគោលនយោបាយ ផែនការ និងការអនុវត្តន៍



## ៦. សេចក្តីសន្និដ្ឋាន និងអនុសាសន៍

ផែនទីបង្ហាញផ្លូវការអភិវឌ្ឍបៃតង ដែលបង្ហាញជូននេះ មានគោលបំណងធំទូលាយចំនួនបី ដែលនៅក្នុងរយៈពេលខ្លី (២-៥ ឆ្នាំ) វានឹងផ្តល់វិភាគទានសំខាន់ៗដល់ការជម្រុញសេដ្ឋកិច្ច សន្សំសំចៃ និងបង្កើតការងារធ្វើ និងការពារក្រុមជនងាយរងគ្រោះ និងការធានានិរន្តរភាពបរិស្ថាន។ នៅក្នុងរយៈពេលមធ្យម (៥-១០ ឆ្នាំ) វានឹងជួយជម្រុញជាបន្ថែមនូវការអភិវឌ្ឍដោយនិរន្តរភាព និង ពេញលេញ និងការសម្រេចគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច និងស្ថិរភាពសង្គម និងបរិស្ថាន។ នៅក្នុងរយៈពេលវែង (១០-២០ ឆ្នាំ) វានឹងរួមចំណែកកាត់បន្ថយការពឹងផ្អែកលើកាបូន និងការវេចរឹលប្រព័ន្ធអេកូឡូស៊ី របស់កម្ពុជា ដែលមានអំណោយផលល្អ សម្រាប់កំណើនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ។

រាជរដ្ឋាភិបាលកម្ពុជា បានអនុម័តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (២០០៦-២០១០) និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម (២០០៩-២០១៣) ដើម្បីធានាថា ដីធ្លី និង ធនធានធម្មជាតិ ត្រូវបានប្រើប្រាស់ប្រកបដោយប្រសិទ្ធិភាព ដើម្បីគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គមប្រកបដោយនិរន្តរភាព និង សមធម៌ សម្រាប់ពលរដ្ឋកម្ពុជាគ្រប់រូប។ លើសពីនេះ នៅចុងឆ្នាំ ២០០៨ របៀបវារៈនយោបាយថ្មីមួយរបស់រាជរដ្ឋាភិបាលកម្ពុជា នៅក្នុងអាណត្តិទីបួននៃរដ្ឋសភាជាតិបានផ្សព្វផ្សាយ ដោយបង្ហាញពីគោលដៅពង្រឹងគុណភាពនៃអភិបាលកិច្ចនៅគ្រប់លំដាប់ថ្នាក់នៃគ្រឹះស្ថានរដ្ឋាភិបាល ដើម្បីធានាថារាល់សេវាកម្មសាធារណៈត្រូវបានផ្តល់ ប្រកបដោយតម្លាភាព ប្រសិទ្ធិភាព និងគណនេយ្យភាព ក៏ដូចជា ពង្រឹងនីតិរដ្ឋ យុត្តិធម៌ និងសមធម៌សង្គម។ របៀបវារៈនយោបាយនេះ ក៏រាប់បញ្ចូលការផ្តោតលើការពង្រឹងការងារគ្រប់គ្រង ការថែរក្សា និងការធ្វើអាជីវកម្មធនធានព្រៃឈើ និងជលផលដោយនិរន្តរភាព ស្របតាមច្បាប់ និងបទប្បញ្ញត្តិនានា ដើម្បីការពារផលប្រយោជន៍ របស់សាធារណៈជនទូទៅ និងសហគមន៍។

ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលកម្ពុជាកំពុងស្ថិតក្នុងដំណើរការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដែលស្ថិតក្រោមការដឹកនាំដោយគណៈកម្មាធិការជាតិគ្រប់គ្រងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដែលនៅក្នុងនេះ ការបង្កើតច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត-ក្រុង ស្រុក-ខណ្ឌ មានសារៈសំខាន់ណាស់ សម្រាប់ការផ្ទេរជាបន្ថែមទៀតនូវមុខនាទី និងធនធានទៅថ្នាក់ក្រោមជាតិ។ ទោះជាយ៉ាងណាក៏ដោយ វិមជ្ឈការ និងវិសហមជ្ឈការ រួមផ្សំជាមួយកំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍ នឹងបង្កើនភាពធន់ទ្រាំរបស់កម្ពុជា ទល់នឹងការប្រែប្រួលអាកាសធាតុ និងចំពោះផលប៉ះពាល់ផ្សេងទៀត ដែលរំពឹងថានឹងកើតមានឡើងទៅអនាគត។ ដើម្បីឱ្យផែនការទាំងនេះអនុវត្តទៅបានដោយភាពរលូន ប្រការសំខាន់គឺត្រូវ បង្កើតបរិយាកាសអំណោយផល សម្រាប់ការវិនិយោគបៃតង ដើម្បីពង្រីកកំណើនការងារបៃតងថ្មីៗ។ ក្នុងន័យនេះ រាជរដ្ឋាភិបាល គួរតែបន្តធ្វើឱ្យសហគ្រាសឯកជន ចូលរួមយ៉ាងសកម្មក្នុងការធ្វើឱ្យវិស័យអភិវឌ្ឍន៍មានលក្ខណៈបៃតង ដែលជាប្រការសំខាន់សម្រាប់កំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍ នៅកម្ពុជា សម្រាប់ រយៈពេលវែង។

ដើម្បីឱ្យស្របតាមយុទ្ធសាស្ត្រចតុកោណ រាល់សកម្មភាពគម្រោង គួរតែផ្តោតលើការពង្រឹងការអនុវត្តច្បាប់ និងដើម្បីធានាឱ្យមានការពង្រឹងនូវការរីកចម្រើនជារួម ឆ្ពោះទៅរកអាទិភាពនៃការអភិវឌ្ឍ។ លើសពីនេះ ផែនទីបង្ហាញផ្លូវនេះមានលក្ខណៈ

អន្តរវិស័យ ដែលបង្ហាញពីបញ្ហាអភិវឌ្ឍន៍សព្វថ្ងៃ និងជាប្រចាំ និងការអនុវត្តវិធានគ្រប់ជ្រុងជ្រោយ ព្រមទាំងកិច្ចសហប្រតិបត្តិការអន្តរវិស័យ។ នៅក្នុងការអនុវត្តនេះ រាជរដ្ឋាភិបាល មានឱកាសដើម្បីបង្កើនឥទ្ធិពលជាប់ជាប្រចាំមកលើកំណើនសេដ្ឋកិច្ចរបស់ខ្លួន ឆ្ពោះទៅរកនិរន្តរភាពបរិស្ថាន កាត់បន្ថយភាពក្រីក្រ និងកំណែលម្អការចិញ្ចឹមជីវិត។ រដ្ឋាភិបាល អាចបង្កើនឥទ្ធិពលធ្វើឱ្យការអភិវឌ្ឍសេដ្ឋកិច្ចមាននិរន្តរភាព ដោយធានាឱ្យមានការយកចិត្តទុកដាក់បានគ្រប់គ្រាន់លើគុណភាពនៃធនធានមនុស្ស និងធនធានធម្មជាតិ។ នៅក្នុងការអនុវត្តក្របខ័ណ្ឌទូលំទូលាយនេះ ក្រុមការងារបច្ចេកទេសអន្តរក្រសួងស្តីពីការអភិវឌ្ឍបៃតង អាចចាប់ផ្តើមដំណើរការរបស់ខ្លួន ដើម្បីឈានទៅអនុវត្តសកម្មភាពអភិវឌ្ឍន៍បៃតង ដោយបង្កើតផែនការការងារកាន់តែលំអិត សម្រាប់គម្រោងដំបូងៗ ដូចដែលមានអធិប្បាយនៅក្នុងផ្នែកនានា ក្នុងឯកសារនេះ (បទអន្តរាគមន៍)។ គេអាចផ្តួចផ្តើមឱ្យមានសកម្មភាព និងគម្រោងជាច្រើន ដើម្បីទទួលបានបទពិសោធន៍ជាក់ស្តែង នៅក្នុងការអនុវត្តគម្រោងអភិវឌ្ឍន៍បៃតង និងដើម្បីទទួលបានការគាំទ្រពីម្ចាស់ជំនួយនានា។

រាជរដ្ឋាភិបាលកម្ពុជា គួរធ្វើឱ្យសហគ្រាសឯកជន និងអង្គការមិនមែនរដ្ឋាភិបាល បានចូលរួមយ៉ាងសកម្មនៅក្នុងការអភិវឌ្ឍបៃតង និងបញ្ជ្រាបកិច្ចផ្តួចផ្តើមអភិវឌ្ឍន៍បៃតងតាមរយៈបង្កើនការយល់ដឹង ការអភិវឌ្ឍសមត្ថភាពនៅក្នុងវិស័យជាក់លាក់ ដើម្បីបង្កើនប្រសិទ្ធិភាពអេកូឡូស៊ីនៃផលិតកម្ម និងការប្រើប្រាស់ និងការអនុវត្តកាន់តែច្រើនឡើងនូវឧបករណ៍គោលនយោបាយអភិវឌ្ឍន៍បៃតង ដែលបានលើកស្នើឡើងដោយគណៈកម្មការសេដ្ឋកិច្ចនិងសង្គម សម្រាប់តំបន់អាស៊ី និង ប៉ាស៊ីហ្វិកនៃអង្គការសហប្រជាជាតិ ដើម្បីជម្រុញសកម្មភាពសេដ្ឋកិច្ចបៃតងនៅតាមវិស័យនានា។ ការបន្តបង្កើតគម្រោង និងការពិភាក្សាជាមួយអ្នកពាក់ព័ន្ធនានានៅថ្នាក់មូលដ្ឋានមានសារៈសំខាន់ណាស់ ដើម្បីធានានិរន្តរភាពនៃគម្រោងនានា។ ទីបំផុត រាជរដ្ឋាភិបាល គួរពិចារណាឱ្យបានហ្មត់ចត់អំពីការបញ្ជ្រាបគោលគំនិតអំពីការអភិវឌ្ឍបៃតងទៅក្នុងយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ដើម្បីអាចធានាឱ្យមានកំណើនសេដ្ឋកិច្ចពេញលេញ និងនិរន្តរភាពបរិស្ថាន សម្រាប់រយៈពេលយូរអង្វែងដើម្បីសង្គមកម្ពុជា។ ផែនទីបង្ហាញផ្លូវអភិវឌ្ឍន៍បៃតងរបស់ជាតិ មានន័យថាជាការបណ្តុះកម្ពុជា តាមវិធីមួយដែលមានប្រសិទ្ធិភាពខ្ពស់ ដោយប្រើប្រាស់ធនធានតិចតួច និងបញ្ចេញសំណល់តិចជាងមុន ដើម្បីឱ្យស្អាតដោយគ្មានការបំពុលបរិស្ថាន និងដើម្បីឱ្យមានលក្ខណៈបៃតង ដោយថែរក្សាភាពបៃតង រក្សាផ្លូវទឹក និងបេតិកភណ្ឌធម្មជាតិ។

ទាំងអស់នេះបង្ហាញឱ្យឃើញពីបំណងនៃរាជរដ្ឋាភិបាលកម្ពុជា ក្នុងការអភិវឌ្ឍន៍សង្គមឱ្យមានចីរភាព ដើម្បីឱ្យកូនចៅជំនាន់ក្រោយអាចទទួលបាន ទាំងកំណើនសេដ្ឋកិច្ច និងបរិស្ថានល្អ សម្រាប់ការរស់នៅប្រកបដោយភាពរុងរឿង។

## ៧. ឯកសារយោង


**Asian Development Bank (ADB). (2007).** Country Strategy and Program Midterm-Review: 2005-2009. Phnom Penh, Cambodia. Author

**Cambodia – European (Cam-EU):** Community Strategy Paper for the period 2007- 2013, Phnom Penh, Cambodia

**Cambodia's Leading Independent Development Policy Research Institute (CDRI). (2008).** Impact of High Food Prices in Cambodia. Phnom Penh, Cambodia

**Community-Based Natural Resource Management(CBNRM). (2009).** Emerging Trends, Challenges and Innovations: Learning Symposiums and the Development of Selected Papers. Vol. II. Phnom Penh, Cambodia

**DANIDA (2006).** Natural Resource Management in Decentralization and Deconcentration Component. Phnom Penh, Cambodia

**Ministry of Public Works and Transportation (MPWT). (2009).** National Policy on Transportation. Phnom Penh, Cambodia

**Ministry of Planning (MoP) and United Nations Development Programme (UNDP). (2007).** Cambodia Human Development Report 2007: *Expanding Choices For Rural People. Phnom Penh Cambodia*

**Ministry of Planning ,(MoP).(2008).** Statistic Year Book 2008. Phnom Penh, Cambodia

**Ministry of Planning (MoP). (2006).** Comprehensive Mid-term review of the implementation of the programme of action for LDCs, 2001-2010. Cambodia: National Review. Phnom Penh, Cambodia

**Ministry of Tourism (MoT).( 2008).** Tourism Statistical Report 2008. Phnom Penh, Cambodia

**Ministry of Agriculture Forestry and Fisheries (MAFF).** Agricultural Sector: Strategic Development Plan 2006-2010. Phnom Penh, Cambodia

**Ministry of Interior (MoI). (2005).** Strategic Framework for Decentralization and Deconcentration 2005. Phnom Penh, Cambodia

**Ministry of Industry, Mines and Energy (MIME).(2008).** Strategic Plan For Rural Electrification Fund Project and Beyond based on adoption in 11th REF Board Meeting dated 13th August 2008. Phnom Penh, Cambodia

**Ministry of Industry, Mines and Energy (MIME).(2006).** The Master Plan Study on Rural Electrification by Renewable Energy in the Kingdom of Cambodia, Final Report: Master Plan. Phnom Penh, Cambodia.

**National Strategic Development Plan (NSDP).(2008).** Mid-term on National Strategic Development Plan 2006-2010. Phnom Penh, Cambodia

**National Institute of Statistics (NIS).** (2008).

**Ministry of Planning (MoP). (2003).** Cambodia Millennium Development Goals Report 2003. Phnom Penh, Cambodia.

**Ministry of Economy and Finance (MoEF).(2007).** Cambodia's economic update 2007

**Royal Government of Cambodia (RGC).(2002).** Statement of the Royal Government on National Forest Sector Policy. Phnom Penh, Cambodia

**Royal Government of Cambodia (RGC) .(2003).** National Population Policy. Phnom Penh, Cambodia

**Royal Government of Cambodia (RGC).(2008).** The Rectangular Strategy for Growth, Employment, Equity, and Efficiency in Cambodia. Royal Government of Cambodia, Phnom Penh.

**Royal Government of Cambodia (RGC).(2008a).** Mid-term Review 2008 On National Strategic Development Plan 2006-2010. Phnom Penh, Cambodia.

**Sidet, M. ( 2008).** Human Resource Assessment and Institutional Framework Review For Environmental Management In Cambodia. Phnom Penh, Cambodia

**United Nations Environment Programme (UNEP).( 2009).** Global Green New Deal: Policy Brief.

**United Nations Development Programme (UNDP). (2006).** Preparatory Activities for Rural Energy Development Programme. Phnom Penh, Cambodia

**National Strategic Development Plan (NSDP) of Cambodia.**

http://siteresources.worldbank.org/INTEASTASIAPACIFIC/Resources/226262-1143156545724/Cambodia_brief.pdfhttp://www.undg.org/archive_docs/3634-Cambodian_tailored_MDG_Report.pdf

**The Rectangular Strategy** for Growth, Employment, Equity and Efficiency in Cambodia

http://www.cdc-crdb.gov.kh/cdc/aid_management/RGC_Rectangular_Strategy_2004.pdf

**ESCAP/EDD/EDPS (2009).** Green growth - Training of Trainers Toolkit. www.greengrowth.org.

# ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធ១:

### រចនាសម្ព័ន្ធនៃអ្នកពាក់ព័ន្ធ ក្នុងការរៀបចំ និងអនុវត្តផែនទីបង្ហាញផ្លូវ



## ឧបសម្ព័ន្ធ ២: តារាងគម្រោងអាទិភាព

លំដាប់ជាអាទិភាពនៃគម្រោងអភិវឌ្ឍបៃតងនៅកម្ពុជា នឹងត្រូវកែសម្រួលឡើងវិញ តាមរយៈសិក្ខាសាលា និងវគ្គបណ្តុះបណ្តាលនានា។ ការចាត់ជាអាទិភាពបែបនេះមានគោលដៅជ្រើសរើសយកគម្រោងដែលសំខាន់ៗ ដើម្បីទទួលការគាំទ្រមូលនិធិ នៅក្រោមកាលៈទេសៈដែលធនធានហិរញ្ញវត្ថុសម្រាប់ការអនុវត្តគម្រោងមានក្នុងកម្រិតកំណត់ ដោយជ្រើសយកតែគម្រោង ដែលអាចគាំទ្រដល់គោលដៅនៃការអភិវឌ្ឍកម្ពុជាដោយនិរន្តរភាព។ លក្ខខណ្ឌវិនិច្ឆ័យសម្រាប់គម្រោងទាំងនេះនឹងត្រូវកំណត់ ដោយផ្អែកលើអាទិភាពអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាលកម្ពុជានៅក្នុងយុទ្ធសាស្ត្រចតុកោណ ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធិភាព គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ និងច្បាប់ បទប្បញ្ញត្តិ គោលនយោបាយ សេចក្តីថ្លែងការណ៍ និងការប្តេជ្ញានានាដែលមានស្រាប់របស់កម្ពុជាចំពោះអនុសញ្ញាអន្តរជាតិ។ លក្ខណៈវិនិច្ឆ័យទាំងនេះ គ្របដណ្តប់ទិដ្ឋភាពនានានៃការអភិវឌ្ឍសេដ្ឋកិច្ចដែលធានានិរន្តរភាពបរិស្ថាន។ គម្រោងនានាដែលបានលើកស្នើមានដូចខាងក្រោមនេះ :

**<u>បញ្ជីគម្រោងដែលបានលើកស្នើ</u>**

| ល.រ | ឈ្មោះគម្រោង | រយៈពេលខ្លី (២-៥ ឆ្នាំ) | រយៈពេលមធ្យម (៥-១០ ឆ្នាំ) | រយៈពេលវែង (១០-២០ ឆ្នាំ) | ក្រសួងទទួលខុសត្រូវ | ស្ថាប័នពាក់ព័ន្ធ |
|---|---|---|---|---|---|---|
| ១ | បង្កើតក្រុមប្រឹក្សាជាតិស្តីពីការអភិវឌ្ឍន៍បៃតង | ✓ | | | ក្រសួងបរិស្ថាន | ទីស្តីការគណៈរដ្ឋមន្ត្រី និងអន្តរក្រសួង |
| ២ | កសាងសមត្ថភាព និងបង្កើនការយល់ដឹងអំពីការអភិវឌ្ឍបៃតង ដល់មន្ត្រី វិស័យឯកជន គ្រឹះស្ថានអប់រំ និង សហគមន៍មូលដ្ឋាន | ✓ | | | ក្រសួងបរិស្ថាន | អន្តរក្រសួង និងអ្នកពាក់ព័ន្ធ |
| ៣ | បង្កើតការយល់ដឹង និង ដំណើរការពិគ្រោះយោបល់ ក្នុងចំណោមអ្នកដទៃទៀត តាមរយៈការផ្សព្វផ្សាយ សម្ភារៈអប់រំ និង សន្លឹកព័ត៌មាន អំពី "កន្លែងធ្វើការ បៃតង" និង "លំនៅស្ថានបៃតង" | ✓ | | | ក្រសួងបរិស្ថាន | អ្នកពាក់ព័ន្ធ |

| | | | | | | |
|---|---|---|---|---|---|---|
| ៤ | នាំយកបច្ចេកវិទ្យាបរិស្ថាន ដល់ជនក្រីក្រ ដើម្បីសម្រួលការប្រើប្រាស់ និង ពង្រឹងសមត្ថភាពការនាំចេញថ្នាក់ជាតិ អំពីបច្ចេកវិទ្យាបរិស្ថាន (បន្ទះទទួល ពន្លឺព្រះអាទិត្យ ប្រសិទ្ធិភាពថាមពល ។ល ។)<br>(ភ្នំពេញ អាស្រ័យលើម្ចាស់ជំនួយ ពីវិស័យឯកជន) | ✓ | | | ក្រសួងបរិស្ថាន | ក្រសួងឧស្សាហកម្មរ៉ែ និងថាមពល ផ្នែកឯកជន អង្គការក្រៅ រដ្ឋាភិបាល ក្រសួងមហាផ្ទៃ ក្រសួងទេសចរណ៍ |
| ៥ | កសាងយុទ្ធសាស្ត្រជាតិសម្រាប់ឧស្សាហកម្មបៃតង ដោយផ្អែកលើប្រសិទ្ធិភាពធនធាន និងយុទ្ធសាស្ត្រ 3R (កាត់បន្ថយ ប្រើប្រាស់ឡើងវិញ និងកែច្នៃឡើងវិញ) | ✓ | ✓ | ✓ | ក្រសួងបរិស្ថាន | ក្រសួងឧស្សាហកម្មរ៉ែ និងថាមពល ផ្នែកឯកជន អង្គការក្រៅ រដ្ឋាភិបាល |
| ៦ | បង្កើតវិធានការជម្រុញការលើកកំពស់និរន្តរភាពកសិកម្ម ដែលរួមទាំងប្រព័ន្ធធានារ៉ាប់រង ដែលផ្អែកលើសន្ទស្សន៍ និង/ឬ មីក្រូហិរញ្ញប្បទាន | ✓ | ✓ | ✓ | ក្រសួងបរិស្ថាន | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងពាណិជ្ជកម្ម និងក្រសួងសេដ្ឋកិច្ច |
| ៧ | បង្កើតប្រព័ន្ធសម្រាប់ការវិនិយោគថ្លៃប្រឹតដើម្បី ធានាឱ្យការគ្រប់គ្រងធនធាន មាននិរន្តរភាព | ✓ | ✓ | ✓ | ក្រសួងផែនការ | ក្រសួងសេដ្ឋកិច្ច និងក្រសួងពាណិជ្ជ កម្ម |
| ៨ | បង្កើតភូមិបៃតងសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច ដោយនិរន្តរភាព និងនិរន្តរភាពបរិស្ថាន | | ✓ | ✓ | ក្រសួងបរិស្ថាន | អន្តរក្រសួង និងអ្នកពាក់ព័ន្ធ |

| | | | | | | |
|---|---|---|---|---|---|---|
| ៩ | និរន្តរភាពធនធានទឹកសម្រាប់ការប្រើប្រាស់ (បរិភោគ) និងការស្រោចស្រព | | ✓ | ✓ | ក្រសួង ធនធានទឹក និង ឧតុនិយម | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងអភិវឌ្ឍន៍ ជនបទ ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្រសួងបរិស្ថាន ក្រសួង រៀបចំដែនដី នគរូប នីយកម្ម និងសំណង់ ក្រសួង កិច្ចការនារី ក្រសួងមហាផ្ទៃ ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងទេចរណ៍ |
| ១០ | បង្កើតនិរន្តរភាពនៃផែនការយុទ្ធសាស្ត្រ កសិកម្ម និង ជម្រុញការមិនប្រើប្រាស់ ជីធម្មជាតិ | | ✓ | ✓ | ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និង នេសាទ | សភាពាណិជ្ជកម្មកម្ពុជា និងក្រសួងពាណិជ្ជកម្ម ក្រសួងធនធានទឹក និងឧតុនិយម ក្រសួងបរិស្ថាន ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួង កិច្ចការនារី ក្រសួងមហាផ្ទៃ ក្រសួងសុខាភិបាល ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងទេចរណ៍ |
| ១១ | ការបង្កើត និងអនុវត្តការគ្រប់គ្រងព្រៃឈើ ដោយនិរន្តរភាព | | ✓ | ✓ | ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និង នេសាទ | ក្រសួងធនធានទឹក និងឧតុនិយម ក្រសួងបរិស្ថាន ក្រសួង ឧស្សាហកម្ម រ៉ែ និងថាមពល ក្រសួង រៀបចំដែនដី នគរូប នីយកម្ម និងសំណង់ ក្រសួង អភិវឌ្ឍន៍ជនបទ ក្រសួង កិច្ចការនារី ក្រសួងមហាផ្ទៃ ក្រសួងសុខាភិបាល ក្រសួង ពាណិជ្ជកម្ម ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សភាពាណិជ្ជ កម្មនៃកម្ពុជា ក្រសួងទេចរណ៍ និង អាជ្ញាធរមូលដ្ឋាន |

| | | | | | | |
|---|---|---|---|---|---|---|
| ១២ | បង្កើតផែនការយុទ្ធសាស្ត្រជាតិ សម្រាប់ការប្រើប្រាស់ ថាមពលដោយនិរន្តរភាព | | ✓ | ✓ | ក្រសួង ឧស្សាហកម្ម រ៉ែ និង ថាមពល | ក្រសួងធនធានទឹក និងឧតុនិយម ក្រសួងបរិស្ថាន ក្រសួងផែនការ ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្រសួង រៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួង កិច្ចការនារី ក្រសួងមហាផ្ទៃ ក្រសួងសុខាភិបាល ក្រសួងពាណិជ្ជកម្ម ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សភាពាណិជ្ជកម្ម នៃកម្ពុជា ក្រសួងទេចរណ៍ |
| ១៣ | បង្កើត និងអនុវត្ត ដោយប្រសិទ្ធិភាពនូវផែនការយុទ្ធសាស្ត្រជាតិ សម្រាប់ការគ្រប់គ្រងសំណល់ក្នុងប្រទេសឱ្យមាន និរន្តរភាព | | ✓ | ✓ | ក្រសួងបរិស្ថាន | ក្រសួងបរិស្ថាន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួង ឧស្សាហកម្ម រ៉ែ និងថាមពល ក្រសួងធ នធានទឹក និង ឧតុនិយម ក្រសួងសាធារណការ និង ដឹកជញ្ជូន ក្រសួងពាណិជ្ជកម្ម ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងសុខាភិបាល ក្រសួងផែន ការ ក្រសួងអប់រំ យុវជន និងកីឡា សាលាក្រុងភ្នំពេញ ក្រសួងកិច្ចការនារី និងក្រសួងទេសចរណ៍ និងអាជ្ញាធរ ក្រុងភ្នំពេញ និងគ្រប់ខេត្ត |
| ១៤ | និរន្តរភាពនៃការដឹកជញ្ជូន និងការអភិវឌ្ឍហេដ្ឋារចនា សម្ព័ន្ធ | | ✓ | ✓ | ក្រសួង សាធារណៈការ និង ដឹកជញ្ជូន | ក្រសួងរៀបចំដែនដី នគរូប នីយកម្ម និងសំណង់ ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងបរិស្ថាន ក្រសួង ឧស្សាហកម្ម រ៉ែ និងថាមពល ក្រសួងធនធានទឹក និងឧតុនិយម ក្រសួងអប់រំ យុវជន និងកីឡា ក្រសួង ពាណិជ្ជកម្ម ក្រសួងសុខាភិបាល ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ អាជ្ញាធររាជ ធានីភ្នំពេញ និង ក្រសួង ទេសចរណ៍ និងអាជ្ញាធរ ក្រុងភ្នំពេញ |

| | | | | | | |
|---|---|---|---|---|---|---|
| ១៥ | ការអភិវឌ្ឍ និងអនុវត្ត តួនាទីយេនឌ័រ នៅក្នុងការអភិវឌ្ឍ បៃតង | | ✓ | ✓ | ក្រសួងកិច្ចការនារី | អង្គការក្រៅ រដ្ឋាភិបាល និង អ្នកពាក់ព័ន្ធ |
| ១៦ | កែលម្អវិស័យសុខាភិបាល ដើម្បីពង្រឹង ការអនុវត្តលើ ការអភិវឌ្ឍបៃតង | | ✓ | ✓ | ក្រសួងសុខាភិបាល | អង្គការក្រៅ រដ្ឋាភិបាល និង អ្នកពាក់ព័ន្ធ |
| ១៧ | ការគ្រប់គ្រងលើការប្រើប្រាស់ដី តាមបែប ផែននៃការចូលរួម និង ពង្រឹងប្រសិទ្ធិភាព នៃការកសាងផែនការប្រើប្រាស់ដីសម្រាប់ ជនជាតិដើមភាគតិច | | ✓ | ✓ | ក្រសួង ដែនដីនគរូបនីយកម្ម និងសំណង់ | ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងមហាផ្ទៃ និងអ្នកពាក់ព័ន្ធ |
| ១៨ | ការអភិវឌ្ឍ និងគ្រប់គ្រងតំបន់ឆ្នេរ ដោយ និរន្តរភាព និង ការស្រាវជ្រាវអំពីប្រព័ន្ធ អេកូឡូស៊ីសមុទ្រ និងការអភិវឌ្ឍ ដើម្បី ការអភិវឌ្ឍបៃតង | | ✓ | ✓ | ក្រសួងបរិស្ថាន និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ក្រសួង មហាផ្ទៃ និង អាជ្ញាធរមូល ដ្ឋាន ក្រសួងដែនដី នគរូបណីយកម្ម និងសំណង់ |
| ១៩ | កែលម្អ និងអនុវត្តវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា សម្រាប់ ផែនការសកម្មភាពជាតិបន្សាំ ទៅនឹងការប្រែប្រួលអាកាសធាតុ ដើម្បីធានាការអភិវឌ្ឍដោយចីរភាព | ✓ | ✓ | ✓ | ក្រសួងបរិស្ថាន | ក្រសួង សាធារណៈការ និង ដឹកជញ្ជូន ក្រសួងឧស្សាហកម្មរ៉ែ និងថាមពល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អង្គការក្រៅ រដ្ឋាភិបាល និងអ្នកពាក់ព័ន្ធ ផ្នែកឯកជន និងស្ថាប័នសិក្សា |
| ២០ | កែលម្អ និង អនុវត្តការគ្រប់គ្រងសំណល់រាវ ដោយប្រសិទ្ធិភាព | | ✓ | ✓ | ក្រសួងបរិស្ថាន និងអាជ្ញាធរក្រុង | និងអាជ្ញាធរក្រុងភ្នំពេញ និង អ្នកពាក់ព័ន្ធ ក្រសួងឧស្សាហកម្មរ៉ែ និងថាមពល ក្រសួងសុខាភិបាល |

| | | | | | | |
|---|---|---|---|---|---|---|
| ២១ | ការប្រើប្រាស់ដី និងបរិស្ថានទីក្រុង ដែលសមស្របនឹងបរិស្ថាន និងផ្តល់សុខភាពល្អ និងការដាក់ឱ្យអនុវត្តគោលការណ៍សម្រាប់ការអភិវឌ្ឍទីក្រុងដោយចីរភាព | | ✓ | ✓ | ក្រសួងបរិស្ថាន | ក្រសួងដែនដីនគរូប នីយកម្ម និងសំណង់ |
| ២២ | វាយតម្លៃប្រពលភាពការប្រែប្រួលអាកាសធាតុ និង បង្កើតសេណារីយ៉ូការប្រែប្រួលអាកាសធាតុ និង កំណើនកំពស់ទឹក សមុទ្រ | | ✓ | ✓ | ក្រសួងបរិស្ថាន | ក្រសួងធនធានទឹក និងឧត្តុនិយម និង អាជ្ញាធរក្រុង អ្នកពាក់ព័ន្ធ សំខាន់ៗ និង អង្គការក្រៅ រដ្ឋាភិបាល |
| ២៣ | ការផ្គត់ផ្គង់ទឹកស្អាត និង អនាម័យសម្រាប់សហគមន៍ ជនបទ និងការអភិវឌ្ឍមុខរបរជំនួស សម្រាប់ការចិញ្ចឹមជីវិត | | ✓ | ✓ | ក្រសួងអភិវឌ្ឍន៍ជនបទ | ក្រសួងធនធានទឹក និងឧត្តុនិយម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងបរិស្ថាន ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល |
| ២៤ | បង្កើត/បញ្ចូលកម្មវិធីបន្ថែមសម្រាប់សាលារៀន ស្តីពីការអភិវឌ្ឍបៃតង | | ✓ | ✓ | ក្រសួងអប់រំ យុវជន និងកីឡា | អ្នកពាក់ព័ន្ធ |
| ២៥ | ការអភិវឌ្ឍឧស្សាហកម្មសហគ្រាសខ្នាតតូច និងមធ្យម សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចដោយចីរភាព | | ✓ | ✓ | ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | សភាពាណិជ្ជកម្មកម្ពុជា និងក្រសួង ពាណិជ្ជកម្ម និងអ្នកពាក់ព័ន្ធ |
| ២៦ | ពង្រឹងការអនុវត្ត និងបង្កើនការយល់ដឹងអំពីផលិតផលស្អាត និងការអនុវត្តដោយប្រសិទ្ធិភាពតាមស្តង់ដារច្បាប់ | | ✓ | ✓ | ក្រសួងឧស្សាហ - កម្មរ៉ែ និងថាមពល | និងក្រសួងពាណិជ្ជកម្ម និង ផ្នែកឯកជន |
| ២៧ | ការបង្កើតឧស្សាហកម្មបៃតង និងការបញ្ចូលទៅក្នុងយុទ្ធសាស្ត្រ អភិវឌ្ឍន៍ជាតិ | | ✓ | ✓ | ក្រសួងឧស្សាហ-កម្មរ៉ែ និងថាមពល | ក្រសួងផែនការ និងក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ |

| | | | | | | |
|---|---|---|---|---|---|---|
| ២៨ | ការបញ្ចូលគោលគំនិត អំពីការអភិវឌ្ឍន៍បៃតង ទៅក្នុង : 1. វិស័យការងារ ; 2. ការបណ្តុះបណ្តាលវិជ្ជាជីវៈ | | ✓ | ✓ | ក្រសួង ការងារ និងបណ្តុះបណ្តាល វិជ្ជាជីវៈ | |
| ២៩ | ការអភិវឌ្ឍទេសចរណ៍ដោយផ្អែកលើសហគមន៍សម្រាប់ កែលម្អការអភិវឌ្ឍសេដ្ឋកិច្ច និងបង្កើនឱកាសខាងការងារ | | ✓ | ✓ | ក្រសួងទេសចរណ៍ | អាជ្ញាធរមូលដ្ឋាន និង អង្គការ ក្រៅ រដ្ឋាភិបាល |
| ៣០ | ការកសាងសមត្ថភាពនៅថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ ដើម្បីបង្កើនគំនិត និង ព័ត៌មានស្តីពីបញ្ហាពាណិជ្ជកម្ម ឧស្សាហកម្ម កសិកម្ម សិប្បកម្ម និង សេវាកម្ម | | ✓ | ✓ | ក្រសួងមហាផ្ទៃ | ក្រសួងពាណិជ្ជកម្ម ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងសភាពាណិជ្ជកម្ម |
| ៣១ | បង្កើតផែនការអភិវឌ្ឍន៍ ដើម្បីកាត់បន្ថយការស្ទះចរាចរ និង គ្រោះថ្នាក់ តាមរយៈការសាងសង់ចិញ្ចើមផ្លូវ | | ✓ | ✓ | អាជ្ញាធរក្រុង | ក្រសួងសាធារណៈការ និងដឹកជញ្ជូន ក្រសួងមហាផ្ទៃ |
| ៣២ | កាត់បន្ថយការបញ្ចេញឧស្ម័នពីការបាត់បង់ព្រៃឈើ និង ការរេចរឹលព្រៃឈើ (REDD) | | ✓ | ✓ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ<br>ក្រសួងបរិស្ថាន និង អាជ្ញាធរខេត្ត-ក្រុង | ផ្នែកឯកជន និង អង្គការក្រៅ រដ្ឋាភិបាល |
| ៣៣ | ការស្រាវជ្រាវ និង បង្កើតកម្មវិធីឆ្លើយតបទៅនឹងភាពងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុ | | ✓ | ✓ | ក្រសួងបរិស្ថាន | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ<br>ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល<br>ក្រសួងធនធានទឹក និងឧត្តុនិយម និងស្ថាប័នសិក្សា |

| | | | | | | |
|---|---|---|---|---|---|---|
| ៣៤ | បង្កើត និងផ្សព្វផ្សាយព័ត៌មាន សម្រាប់អប់រំ និង កូនសៀវភៅណែនាំ ស្តីពីការអភិវឌ្ឍបៃតង ដល់អ្នកពាក់ ព័ន្ធទាំងអស់ | | ✓ | ✓ | ក្រសួងបរិស្ថាន | អ្នកពាក់ព័ន្ធមកពីក្រសួងពាក់ព័ន្ធ និង អង្គការក្រៅរដ្ឋាភិបាល |
| ៣៥ | បង្កើតយុទ្ធសាស្ត្រ និងផែនការ សកម្មភាព ដើម្បីលើកទឹក ចិត្តឱ្យប្រើប្រាស់ថាមពលកកើតឡើងវិញ | | ✓ | ✓ | ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | ក្រសួងបរិស្ថាន និងផ្នែកឯកជន |
| ៣៦ | ការបង្កើតផែនការយុទ្ធសាស្ត្រជាតិ ដើម្បីធានាការគ្រប់ គ្រងដោយនិរន្តរភាពនូវធនធានក្នុងតំបន់ការពារធម្មជាតិ | | ✓ | ✓ | ក្រសួងបរិស្ថាន | ក្រសួងមហាផ្ទៃ និងអជ្ញាធរ មូលដ្ឋាន |
| ៣៧ | ការនាំយកបច្ចេកវិទ្យាដែលមិនខូចខាតបរិស្ថាន ដល់អ្នកក្រីក្រប្រើប្រាស់ | | ✓ | ✓ | ក្រសួង ឧស្សាហកម្ម រ៉ែ និងថាមពល | ក្រសួងបរិស្ថាន និង អ្នកពាក់ព័ន្ធ ទាំងអស់ និងផ្នែកឯកជន |
| ៣៨ | ការដាំដើមឈើ និងការស្តារព្រៃឈើ សម្រាប់គម្រោង យន្តការអភិវឌ្ឍស្អាត ដើម្បីធានាការពារគម្របព្រៃ និងដើម្បីកាត់បន្ថយការប្រែប្រួលអាកាសធាតុ | ✓ | ✓ | ✓ | ក្រសួងបរិស្ថាននិង ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ | អ្នកពាក់ព័ន្ធទាំងអស់ និងផ្នែក ឯកជន ស្ថាប័នសិក្សា ក្រសួងឧស្សា ហកម្មរ៉ែ និងថាមពល |
| ៣៩ | រៀបចំផែនការយុទ្ធសាស្ត្រ និង/ឬផែនការ សកម្មភាព ស្តីពីការអប់រំបរិស្ថាន ដើម្បីការអភិវឌ្ឍដោយចីរភាព | ✓ | ✓ | ✓ | ក្រសួងបរិស្ថាន | ក្រសួងអប់រំយុវជន និងកីឡា និង អ្នកពាក់ព័ន្ធទាំងអស់ |
| ៤០ | បង្កើតគណៈកម្មាធិការជាតិ អនុវត្ត ការអប់រំបរិស្ថាន ដើម្បីការអភិវឌ្ឍ ដោយចីរភាព | | ✓ | ✓ | ក្រសួងបរិស្ថាន | ទីស្តីការគណៈរដ្ឋមន្ត្រី និងអន្តរក្រសួង |